# ក្រសួងបរិស្ថាន
MINISTRY OF ENVIRONMENT

ឆ្នាំទី 3
លេខ 2

អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន

# ទស្សនាវដ្តី បរិស្ថាន
# ENVIRONMENTAL MAGAZINE



អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន
អាគារមរតកតេជោ ដីឡូតិ៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
© ២០១៧

ចេញផ្សាយប្រចាំខែ កក្កដា-ធ្នូ ឆ្នាំ២០១៧
VOLUME 3

## មាតិកា


អារម្ភកថា ........................................ ១

អំពីក្រសួងបរិស្ថាន ........................................ ២

ផ្នែកអគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព........................................ ៣

ផ្នែកអភិបាលកិច្ចក្រសួងបរិស្ថាន........................................ ២៦

ផ្នែកគាំពារបរិស្ថាន........................................ ៣៥

ផ្នែកកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ........................................ ៤៥

ផ្នែកចំណេះដឹង និងព័ត៌មានបរិស្ថាន........................................ ៥៧

ផ្នែកបេតិកភណ្ឌ និងសហគមន៍មូលដ្ឋាន........................................ ៧៥

# អារម្ភកថា

ទស្សនាវដ្ដីបរិស្ថានដែលឯកឧត្ដម លោកជំទាវ លោក លោកស្រី កំពុងអាននេះ គឺជាឯកសារសម្រាប់ផ្សព្វផ្សាយជាសាធារណៈជូនដល់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ក៏ដូចជាគ្រឹះស្ថានសិក្សានានា។ ទស្សនាវដ្ដីបរិស្ថាននេះ ត្រូវបានរៀបចំឡើងដោយក្រុមការងាររៀបចំទស្សនាវដ្ដីបរិស្ថានក្រសួងបរិស្ថាន ដែលមាននាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន របស់ក្រសួងបរិស្ថាន ដែលជាអង្គភាពបង្គោលទទួលរៀបចំផលិតនិងបោះពុម្ពផ្សាយ។

ក្រុមការងាររៀបចំទស្សនាវដ្ដីបរិស្ថានក្រសួងបរិស្ថាន បានរៀបចំឯកសារនេះដើម្បីផ្ដល់ជាព័ត៌មានមូលដ្ឋាននៃសកម្មភាពបរិស្ថានដែលបានអនុវត្តដោយជំនាញនានានៅក្រោមឱវាទក្រសួងបរិស្ថាន ជូនដល់ប្រិយមិត្តអ្នកអាន និងអ្នកសិក្សាទាំងអស់ដែលស្រឡាញ់វិស័យបរិស្ថាន។ វត្ថុបំណងនៃឯកសារនេះ គឺផ្សព្វផ្សាយព័ត៌មានបរិស្ថាន និងលើកកម្ពស់ការយល់ដឹងបរិស្ថានតាមរយៈអំណាន ព្រមទាំងមានគោលបំណងផ្ដល់នូវព័ត៌មានសង្ខេបខ្លីៗស្ដីពីសកម្មភាពបរិស្ថាន ដល់ឯកឧត្ដម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ដើម្បីឱ្យគេរីករាយ និងបញ្ចេញនូវគំនិតល្អៗ ព្រមទាំងស្ម័គ្រចិត្តចូលរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។

យើងខ្ញុំជឿជាក់ថា ទស្សនាវដ្ដីបរិស្ថាន នឹងក្លាយទៅជាឧបករណ៍ផ្សព្វផ្សាយមួយប្រកបដោយប្រសិទ្ធភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាជំនួយព័ត៌មានដល់ឯកឧត្ដម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ក្នុងការស្វែងយល់ពីបរិស្ថាន និងការអប់រំបរិស្ថាន។ យើងសង្ឃឹមថាទស្សនាវដ្ដីបរិស្ថាន នេះ នឹងជួយលើកកម្ពស់ដល់វិស័យផ្សព្វផ្សាយព័ត៌មានបរិស្ថាន និងលើកកម្ពស់ការយល់ដឹងពីបរិស្ថានរបស់ប្រជាពលរដ្ឋគ្រប់ៗរូបជាមិនខាន៕

# កិច្ចគាំពារបរិស្ថាន

## ប្រតិភូជាន់ខ្ពស់ក្រសួងបរិស្ថាន ចូលរួមកិច្ចប្រជុំលើកទី១នៃបណ្តាប្រទេសហត្ថលេខី អនុសញ្ញាទីក្រុងមីណាម៉ាតាស្តីពីសារធាតុបារ៉ត នៅប្រទេសស្វីស






នារសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧នៅមជ្ឈមណ្ឌលសន្និសីទអន្តរជាតិ ទីក្រុងហ្សឺណែវ សហព័ន្ធស្វីស ឯកឧត្តម អ៊ាង សុផល្លែត អនុរដ្ឋលេខាធិការ តំណាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន អមដំណើរដោយឯកឧត្តមឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសហព័ន្ធស្វីស និងអង្គការសហប្រជាជាតិ បានដឹកនាំគណៈប្រតិភូក្រសួងបរិស្ថានចូលរួមពិធីបើកជាផ្លូវការកិច្ចប្រជុំលើកទី១នៃបណ្តាប្រទេសភាគីហត្ថលេខីអនុសញ្ញាទីក្រុងមីណាម៉ាតាស្តីពីសារធាតុបារ៉ត (COP1) ក្រោមអធិបតីភាពលោកជំទាវប្រធានាធិបតីសហព័ន្ធស្វីស។ កិច្ចប្រជុំនេះរៀបចំដោយអង្គការ UNEP ប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានវត្តមានរដ្ឋមន្ត្រីមកពី៨០ប្រទេសក្នុងចំណោមប្រទេសចំនួន១៧៦ ដែលបានចូលរួម។

បន្ទាប់កម្មវិធីបើកផ្លូវការ **ឯកឧត្តម អ៊ាង សុផល្លែត** និងប្រតិភូបានអញ្ជើញចូលរួមកិច្ចពិភាក្សាតុមូលថ្នាក់រដ្ឋមន្ត្រីដែលផ្តោតទៅលើការបំពុលរបស់បារ៉តសាយភាយ ទៅក្នុងខ្យល់ ទឹក និងក្នុងដី ហើយត្រូវមានវិធានការទប់ស្កាត់បែបណាដើម្បីកុំឱ្យមានសោធនាដកម្មពី សារធាតុបារ៉តទាំងទិដ្ឋភាពនយោបាយរួមទាំងបច្ចេកទេស។ថ្លែងក្នុងកិច្ចពិភាក្សាតុមូលនេះ ឯកឧត្តមប្រធានប្រតិភូក្រសួងបរិស្ថាន បានលើកអំពីបញ្ហាបច្ចេកវិទ្យាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងសំណល់បារ៉ត ក៏ដូចជាការដកបារ៉តពីតំបន់ដែលរងការបំពុល និងការគ្រប់គ្រងបារ៉តដែលបានដកចេញពីសំណល់។ **ឯកឧត្តម អ៊ាង សុផល្លែត** បានបញ្ជាក់ថា ដើម្បីសម្រេចបានជោគជ័យត្រូវមានការទទួលខុសត្រូវដោយមានការចូលរួមកម្រិតអន្តរជាតិ ជាតិ និងពីបុគ្គលម្នាក់ៗ៕

# ក្រសួងធនធានធម្មជាតិនិងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា
# បានផ្តល់រថយន្តបំពាក់ឧបករណ៍ត្រួតពិនិត្យគុណភាពខ្យល់ និងផ្សែងអ័ព្ទឆ្លងដែន

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ **ឯកឧត្តម ស៊ី សុវុធ** អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន បានអញ្ជើញចូលរួមក្នុងពិធីប្រគល់ និងទទួលរថយន្តបំពាក់ឧបករណ៍ត្រួតពិនិត្យគុណភាពខ្យល់ និងផ្សែងអ័ព្ទឆ្លងដែន គ្រាដែលកម្មវិធីក៏មានការចូលរួមពី**លោក Jatupom Buruspant** តំណាងក្រសួងធនធានធម្មជាតិនិងបរិស្ថាន នៃព្រះរាជាណាចក្រថៃ រួមទាំងអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន និងមន្ត្រីពាក់ព័ន្ធប្រមាណ៣០ នាក់ នៅខេត្តស្រះកែវ ប្រទេសថៃ ។




គោលបំណងនៃពិធីនេះគឺ ភាគីថៃ និងបញ្ជូនរថយន្តត្រួតពិនិត្យគុណភាពគុណភាពខ្យល់មកធ្វើការបណ្តុះបណ្តាលមន្ត្រី នៃនាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង ដល់មន្ត្រីនៃមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ពីរបៀបប្រើប្រាស់ឧបករណ៍ក្នុងការតាមដានគុណភាពខ្យល់និងផ្សែងអ័ព្ទឆ្លងដែន ដែលមានរយៈពេលពីរខែ៕





## តើអ្វីទៅជាពិធីសារម៉ុងរ៉េអាល់? តើកម្ពុជាបានធ្វើអ្វីខ្លះបន្ទាប់ពីចូលជាសមាជិក?

ក្រសួងបរិស្ថាននៅថ្ងៃទី១៥ ខែកញ្ញានឹងធ្វើសន្និសីទសារព័ត៌មានក្រោមប្រធានបទ៣០ឆ្នាំនៃពិធីសារ ម៉ុងរ៉េអាល់ ដើម្បីអបអរសាទរទិវាអូហ្សូនអន្តរជាតិ។ តើកម្ពុជាបានចូលជាសមាជិកនៃពិធីសារម៉ុងរ៉េអាល់តាំងពីពេលណា ហើយអ្វីទៅជាពិធីសារម៉ុងរ៉េអាល់?

ជាប្រទេសមួយក្នុងចំណោមប្រជាជាតិក្នុងលោក កម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាវីយ៉ែន ស្តីពី កិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១។ ពិធីសារម៉ុងរ៉េអាល់ត្រូវបានអនុម័តជាផ្លូវការនៅឆ្នាំ១៩៨៩ក្នុងប្រទេសកាណាដា ដើម្បីឱ្យសហគមន៍អន្តរជាតិទាំងអស់ចូលរួមទប់ស្កាត់កុំឱ្យមានការ ប្រើសារធាតុបំផ្លាញស្រទាប់អូហ្សូន(*ODS*)។

ការលុបបំបាត់សារធាតុបំផ្លាញស្រទាប់អូហ្សូននេះគឺរួមចំណែកយ៉ាងសំខាន់ ក្នុងការទប់ស្កាត់ការកើនកំដៅលើកពផែនដីដោយសារសារធាតុបំផ្លាញស្រទាប់អូហ្សូនជាសារធាតុដែលមានសក្តានុពលនៃការកើនកំដៅខ្ពស់ជាងឧស្ម័នកាបូនិករាប់ពាន់ដង។ សកម្មភាពដែលនាំឱ្យមានការបំផ្លាញស្រទាប់ អូហ្សូន គឺបង្កឡើងដោយការបញ្ចេញ ការលេចធ្លាយសារធាតុបំផ្លាញស្រទាប់អូហ្សូន ទៅក្នុងបរិយាកាស។ សារធាតុទាំងនេះមានផ្ទុកអាតូមក្លរ និងប្រូមដែលនាំឱ្យមានការបំផ្លាញស្រទាប់អូហ្សូន។សម្រាប់កម្ពុជា ៤ឆ្នាំក្រោយការចូលជាសមាជិក(ឆ្នាំ២០០៥) អនុក្រឹត្យមួយស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូនត្រូវបានអនុម័តដើម្បីគ្រប់គ្រងការនាំចូលនាំចេញ និងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន ដោយកំណត់កាលបរិច្ឆេទបញ្ឈប់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូននៅក្នុងប្រទេសកម្ពុជាស្របទៅតាមកម្មវិធីលុបបំបាត់សារធាតុបំផ្លាញ ស្រទាប់អូហ្សូន នៃពិធីសារម៉ុងរ៉េអាល់។

ក្រសួងបរិស្ថានបានឱ្យដឹងថាសារធាតុCFCដែលជាសារធាតុបំផ្លាញស្រទាប់ អូហ្សូនត្រូវបានលុបបំបាត់ទាំងស្រុងតាំងពីឆ្នាំ២០១០មកម្លេះ ហើយបាន និង កំពុងអនុវត្តផែនការលុបបំបាត់សារធាតុHCFCឱ្យបាននៅឆ្នាំ២០៤០។ ក្នុងការអនុវត្តកម្មវិធីនិងផែនការជាតិ និងអនុក្រឹត្យនេះ ក្រសួងបរិស្ថានដែលជាស្ថាប័នបង្គោលក្នុងការអនុវត្តពិធីសារម៉ុងរ៉េអាល់ បានសហការយ៉ាងជិតស្និតជាមួយស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងការកាត់បន្ថយនិងលុបបំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់ អូហ្សូន។ នេះបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត អំពីជំហរយ៉ាងម៉ឺងម៉ាត់បំផុតរបស់រាជរដ្ឋាភិបាល នៅក្នុងការអនុវត្តគោលនយោបាយ បរិស្ថានជាតិ និងការគាំទ្រសកម្មភាពការពារបរិស្ថានពិភពលោករបស់មនុស្សជាតិ។ សារធាតុ CFC រួមមាន៖

- សារធាតុCFCមានប្រើប្រាស់ក្នុងទូទឹកកក ម៉ាស៊ីនត្រជាក់រថយន្ត ម៉ាស៊ីនត្រជាក់ ដែលផលិតមុនឆ្នាំ១៩៩៦ ប្រើប្រាស់សម្រាប់សម្អាតបន្ទះអេឡិចត្រូនិច ជាសារធាតុជម្រុញសម្ពាធក្នុងកំប៉ុងស្រ្បេ ទឹកអប់ ហ្វូមកោពុកមាត់ ។ល។
- សារធាតុHCFC មានប្រើប្រាស់ក្នុងម៉ាស៊ីនត្រជាក់ ទូបង្កក ទូក្លាសេ បន្ទប់ត្រជាក់និងបន្ទប់ត្រជាក់ចល័ត៕

## សិក្ខាសាលាស្តីពី ការរៀបចំចងក្រងសំណើគម្រោងថ្នាក់តំបន់ ស្តីពីការកាត់បន្ថយការបំពុល និងការថែរក្សាលំហូរបរិស្ថានទឹកក្នុងតំបន់សមុទ្រ អាស៊ីបូព៌ាតាមរយៈការអនុវត្តសមាហរណកម្មការគ្រប់គ្រងអាងទន្លេនៃប្រទេស ក្នុងតំបន់អាស៊ីអាគ្នេយ៍

កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ នៅសណ្ឋាគារ Kampot Diamond Hotel ទីរួមខេត្តកំពត **ឯកឧត្តម ហេង ណារ៉េត** អគ្គនាយក នៃអគ្គនាយកដ្ឋានគាំពារបរិស្ថានបានចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិស្តីពី "ការរៀបចំចងក្រងសំណើគម្រោងថ្នាក់តំបន់ស្តីពីការកាត់បន្ថយការបំពុល និងការថែរក្សាលំហូរបរិស្ថានទឹកក្នុងតំបន់សមុទ្រអាស៊ីបូព៌ាតាមរយៈការអនុវត្ត សមាហរណកម្មការគ្រប់គ្រងអាងទន្លេ នៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍" ពិធីបើកសិក្ខាសាលាថ្នាក់ជាតិនេះ មានការចូលរួមពី**ឯកឧត្តមបណ្ឌិត វ៉ាន់ ម៉ូនីនាថ** ប្រធានឧត្តមមន្ត្រីបរិស្ថានអាស៊ាន កម្ពុជា និង**លោកបណ្ឌិត Dr. Won-Tae Shin** តំណាងអង្គការភាពជាដៃគូក្នុងការគ្រប់គ្រងបរិស្ថានសម្រាប់សមុទ្រអាស៊ីបូព៌ា (PEMSEA)។





សិក្ខាសាលានេះមានគោលបំណងប្រមូលទិន្នន័យស្តីពីធនធានសេដ្ឋកិច្ចសង្គម បរិស្ថាន ការប្រើប្រាស់ ការគ្រប់គ្រង និងបញ្ហាប្រឈម នានាក្នុងអាងទន្លេនៃព្រែកកំពង់បាយ និងតំបន់សមុទ្រពាក់ព័ន្ធ ដើម្បីកសាង និងដាក់ស្នើគម្រោងថ្នាក់តំបន់នេះ ទៅកាន់អង្គការមូលនិធិបរិស្ថានសកល(GEF)។

សិក្ខាសាលាថ្នាក់ជាតិនេះមានការចូលរួមពីសិក្ខាកាមចំនួន ៣៣នាក់ ដែលបានអញ្ជើញមកពីក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧតុនិយម សាលាខេត្តកំពត និងមន្ទីរបរិស្ថាន ទេសចរណ៍ ផែនការ និងមន្ទីរពាក់ព័ន្ធមួយចំនួនទៀតក្នុងខេត្តកំពត។ សិក្ខាសាលានេះរៀបចំដោយនាយកដ្ឋានគ្រប់គ្រងគុណភាពទឹក អគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន សហការជាមួយអង្គការ PEMSEA ក្រោមជំនួយឧបត្ថម្ភពីអង្គការមូលនិធិបរិស្ថានសាកល (GEF)៕

# ការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកសាធារណៈ

**ក. ការតាមដានគុណភាពទឹកសាធារណៈ**

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៧ បានចុះយកសំណាកទឹកមកវិភាគនៅមន្ទីរពិសោធន៍នៃ ក្រសួងបរិស្ថានចំនួន២៥សំណាក ដែលក្នុងនោះសំណាកទឹកសាធារណៈមានចំនួន១៥សំណាក ដែលនៅ ចំណុចគោលដៅមានចំនុចជ្រោយចង្វារ (ទន្លេមេគង្គ) ចំណុចវត្តក្តីតាកុយ(កៀនស្វាយ) ចំណុចកំពង់ ចម្លង តាខ្មៅ (ទន្លេបាសាក់) ចំណុចកំពង់ផែភ្នំពេញ (ទន្លេសាប) ចំណុចទឹកទន្លេមេគង្គលើ ខេត្តកំពង់ចាម (ស្ពាន គីហ្សូណា) ចំណុចទន្លេសាបខេត្តកំពង់ឆ្នាំង(ផ្សារក្រោម) ចំណុចបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង) ចំណុច ស្ទឹងជីនិត (ខេត្តកំពង់ធំ) ចំណុចស្ទឹងសែន (ខេត្តកំពង់ធំ) ចំណុចទឹកសាបពាជាន់(ខេត្តព្រះសីហនុ) ចំណុច ស្ទឹងសៀមរាប(ខេត្តសៀមរាប) ចំណុចកំពង់ហ្លួង (ខេត្តពោធិសាត់) ចំណុចស្ទឹងពោធិសាត់ (ខេត្តពោធិ សាត់) ចំណុចស្ទឹងសង្កែ (ខេត្តបាត់ដំបង) ហើយការពិនិត្យជាលទ្ធផលប៉ារ៉ាម៉ែត្រTN និងTP លើសស្តង់ដា ដោយសារស្ថានភាពទឹកទន្លេស្រកខ្លាំង ពិសេសបណ្តាលមកពីការបង្ហូរសំណល់រាវចេញពីទីក្រុង លំនៅឋាន កសិដ្ឋាន និងដី កសិកម្មចូលទៅទន្លេ។

ដោយឡែកយោងតាមលទ្ធផលវិភាគសំណាកទឹកសាធារណៈប្រចាំខែមេសា យើងឃើញថាមានការ ប្រែប្រួលនៅចំណុចមួយចំនួន ដូចខាងក្រោម៖

តារាង៖ លទ្ធផលវិភាគគុណភាពទឹកសាធារណៈប្រចាំខែមេសា ឆ្នាំ២០១៧

| ល.រ | ចំណុចយកសំណាក | PH | TSS (mg/l) | BOD5 (mg/l) | CODMn (mg/l) | Cr+6 (mg/l) | T-N (mg/l) | T-P (mg/l) |
|---|---|---|---|---|---|---|---|---|
| 1 | ជ្រោយចង្វារ (ទន្លេមេគង្គ) | 6.81 | 27.00 | 0.88 | 2.36 | ND | 0.55 | 0.04 |
| 2 | វត្តក្តីតាកុយ កៀនស្វាយ | 7.04 | 52.00 | 1.95 | 4.70 | ND | 0.94 | 0.13 |
| 3 | កំពង់ចម្លងតាខ្មៅ (ទន្លេបាសាក់) | 6.78 | 68.00 | 2.69 | 5.88 | 0.006 | 0.89 | 0.11 |
| 4 | កំពង់ផែភ្នំពេញ (ទន្លេសាប) | 6.59 | 68.00 | 1.96 | 4.17 | ND | 1.59 | 0.12 |
| 5 | ទឹកទន្លេមេគង្គលើ ខេត្តកំពង់ចាម (ស្ពានគីហ្សូណា) | 7.23 | 39.00 | 0.92 | 2.35 | ND | 0.55 | 0.11 |
| 6 | ទន្លេសាបខេត្តកំពង់ឆ្នាំង(ផ្សារក្រោម) | 6.90 | 66.00 | 1.97 | 4.52 | ND | 0.86 | 0.18 |
| 7 | បឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង) | 7.29 | 85.00 | 3.95 | 8.92 | 0.009 | 1.13 | 0.09 |
| 8 | ស្ទឹងជីនិត (ខេត្តកំពង់ធំ) | 7.20 | 48.00 | 1.89 | 5.09 | 0.007 | 0.62 | 0.08 |
| 9 | ស្ទឹងសែន (ខេត្តកំពង់ធំ) | 7.34 | 48.00 | 1.99 | 5.48 | ND | 0.59 | 0.16 |
| 10 | ទឹកសាបពាជាន់(ខេត្តព្រះសីហនុ) | 7.33 | 108.00 | 1.00 | 0.14 | ND | 0.15 | 0.02 |
| 11 | ស្ទឹងសៀមរាប(ខេត្តសៀមរាប) | 6.68 | 59.00 | 1.79 | 4.56 | ND | 1.13 | 0.15 |
| 12 | កំពង់ហ្លួង (ខេត្តពោធិសាត់) | 6.67 | 76.00 | 5.50 | 12.15 | ND | 1.57 | 0.39 |
| 13 | ស្ទឹងពោធិសាត់ (ខេត្តពោធិសាត់) | 7.02 | 47.00 | 1.36 | 3.72 | ND | 0.58 | 0.10 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 14 | ស្ទឹងសង្កែ (ខេត្តបាត់ដំបង) | 7.27 | 60.00 | 1.52 | 3.81 | ND | 0.48 | 0.18 |
| កម្រិតកំណត់ស្តង់ដារ | | 6.5-8.5 | 25-100 | 1-10 | <8.0 | 0.005-0.05 | 0.1-0.6 | <0.05 |

## ខ. ការតាមដានគុណភាពទឹកកល្វ

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៧ បានចុះយកសំណាកទឹកកល្វលើទីតាំង ៩ចំណុច ក្នុងនោះ មានចំណុចស្ពានព្រែកព្នៅគីឡូម៉ែត្រលេខ៩ ចំណុចស្ពានថ្មថ្មីគីឡូម៉ែត្រលេខ ១១ ចំណុចស្ថានីយ៍ទឹកស្អុយ បឹងត្របែក ចំណុចស្ថានីយ៍ទឹកស្អុយបឹងទំពុន ចំណុចស្ទឹងព្រែកត្នោត (ស្ពានថ្មតាខ្មៅ) ចំណុចស្ថានីយ សំអាតទឹកចំការសំពោង (ខេត្តបាត់ដំបង) មុនពេលឆ្លងកាត់ប្រព័ន្ធសំអាត ចំណុចស្ថានីយសំអាតទឹកចំការ សំពោង (ខេត្តបាត់ដំបង) ក្រោយពេលឆ្លងកាត់ប្រព័ន្ធសំអាត ហើយការពិនិត្យជាលទ្ធផលប៉ារ៉ាម៉ែត្រ TN និង TP មានការកើនលើសស្តង់ដារដែរ ដោយសារនៅរាជធានីភ្នំពេញពុំមានអាងប្រព្រឹត្តកម្មសម្រាប់សម្អាត។

តារាង៖ លទ្ធផលវិភាគទឹកកល្វប្រចាំខែមេសា ឆ្នាំ២០១៧

| ល.រ | ទឹកកល្វចេញពីស្ថានីយ៍សម្អាតទឹកកល្វក្រុង | PH | TSS (mg/l) | BOD5 (mg/l) | CODMn (mg/l) | Cr+6 (mg/l) | T-N (mg/l) | T-P (mg/l) |
|---|---|---|---|---|---|---|---|---|
| 1 | ស្ពានព្រែកព្នៅគីឡូម៉ែត្រលេខ៩ | 7.47 | 75.00 | 18.90 | 46.00 | ND | 1.53 | 0.62 |
| 2 | ស្ពានថ្មថ្មីគីឡូម៉ែត្រលេខ១១ | 6.59 | 74.00 | 58.30 | 131.00 | ND | 10.94 | 0.76 |
| 3 | ស្ថានីយ៍ទឹកស្អុយបឹងត្របែក | 6.68 | 105.00 | 118.95 | 223.00 | ND | 17.12 | 7.91 |
| 4 | ស្ថានីយ៍ទឹកស្អុយបឹងទំពុន | 6.75 | 126.00 | 106.80 | 220.00 | ND | 14.51 | 3.78 |
| 5 | ស្ទឹងព្រែកត្នោត (ស្ពានថ្មតាខ្មៅ) | 6.40 | 74.00 | 42.06 | 126.00 | 0.009 | 6.64 | 1.41 |
| 6 | ស្ថានីយសំអាតទឹកចំការសំពោង (ខេត្តបាត់ដំបង)មុនពេលឆ្លងកាត់ប្រព័ន្ធសំអាត | 6.77 | 92.00 | 126.40 | 200.00 | 0.01 | 8.85 | 3.59 |
| 7 | ស្ថានីយសំអាតទឹកចំការសំពោង (ខេត្តបាត់ដំបង) ក្រោយពេលឆ្លងកាត់ប្រព័ន្ធសំអាត | 7.45 | 53.00 | 84.00 | 121.00 | ND | 4.92 | 2.04 |
| 8 | ប្រឡាយខាងកើតស្ទឹង (ខេត្តបាត់ដំបង) | 7.27 | 60.00 | 1.52 | 3.81 | ND | 0.48 | 0.18 |
| 9 | ចំណុចសណ្ឋាគារ និងកាស៊ីណូ Queenco (ខេត្តព្រះសីហនុ) | 7.34 | 36.00 | 69.50 | 140.00 | ND | 2.73 | 0.17 |
| 10 | ផ្លូវអូរឈើទាល (មុនពេលឆ្លងកាត់អាងសម្អាត) | 7.70 | 94.00 | 104.30 | 280.00 | ND | 18.31 | 10.37 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 11 | ឆ្នេរអូរឈើទាល(ក្រោយពេលឆ្លងកាត់អាងសម្អាត) | 7.68 | 42.00 | 58.92 | 147.00 | ND | 6.88 | 5.76 |
| កម្រិតកំណត់ស្តង់ដារ | | 5-9 | <120 | <80 | <100 | <5 | <20 | <0.6 |

## គ- ការចុះតាមដានគុណភាពទឹកសមុទ្រ

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៧ បានចុះយកសំណាកទឹកសមុទ្រមានចំនួន២សំណាក ដែលមានទីតាំងនៅចំណុចឆ្នេរកែប និងចំណុចមុខសាលាខេត្តកំពត ដោយធ្វើឡើង២ដងក្នុងមួយឆ្នាំ។ ក្នុងនោះលទ្ធផលបង្ហាញថាស្ទើរគ្រប់ប៉ារ៉ាម៉ែត្រគឺស្ថិតនៅក្រោមកម្រិតស្តង់ដារកំណត់លើកលែងតែប៉ារ៉ាម៉ែត្រសារ ជាតុរឹងអណ្តែតក្នុងទឹក (TSS) មានការកើនឡើងបរិមាណ ដែលបណ្តាលមកពីការហូរច្រោះសារជាតុផ្សេងៗ តាមរយៈទឹកភ្លៀងចូលមកកាន់សមុទ្រជាពិសេសកករដី និងរុក្ខជាតិពុកផុយហើយវាក៏បណ្តាលឱ្យកាត់បន្ថយ ពន្លឺថ្ងៃចូលទៅក្នុងសមុទ្រធ្វើឱ្យសារពាង្គកាយមានជីវិតពិបាកក្នុងការធ្វើរស្មីសំយោគដើម្បីចិញ្ចឹមជីវិត។

តារាង៖ លទ្ធផលវិភាគទឹកសមុទ្រខែមីនា ឆ្នាំ២០១៧

| ល.រ | ចំណុចយកសំណាក | DO | TSS (mg/l) | NH3 (mg/l) | NO2 (mg/l) | NO2- (mg/l) | PO4 (mg/l) | Cr6 (mg/l) |
|---|---|---|---|---|---|---|---|---|
| 1 | ទីតាំងមុខសាលាខេត្តកំពត | 5.8 | 137.00 | 0.04 | ND | 0.28 | ND | ND |
| 2 | ទីតាំងឆ្នេរកែប | 6.49 | 180.00 | 0.03 | ND | 0.19 | ND | ND |
| កម្រិតកំណត់ស្តង់ដារ | | 2.0-7.5 | 25-100 | NV | NV | NV | NV | NV |

# ការការពារតំបន់ធម្មជាតិ និងអភិរក្សជីវៈចម្រុះ

## ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ ក្រសួងបរិស្ថាន ក្រោមការដឹកនាំរបស់ឯកឧត្តមសាយ សំអាល់បានបង្កើតតំបន់ការពារធម្មជាតិ ចំនួនពីចំនួន២៣កន្លែងទៅដល់៤៩កន្លែង ដែលគ្របដណ្តប់ផ្ទៃដីសរុបប្រមាណ ៧,៥លានហិកតា ហើយបច្ចុប្បន្នក្រសួងបរិស្ថានបាននឹងកំពុងដំណើរការដាក់តំបន់មួយចំនួនទៀតជាតំបន់ការពារនិងអភិរក្សធនធានធម្មជាតិ។

**១. សេវាគាំទ្រការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ**

- ចុះពង្រឹងការងារគ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ បានចំនួន ៩ លើក
- សម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រផែនការយុទ្ធសាស្ត្រថវិកា ២០១៨-២០២០ និងផែនការថវិកា ឆ្នាំ២០១៨
- រៀបចំ និងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋក្នុងអគ្គនាយកដ្ឋាន សម្រាប់ឆ្នាំ២០១៦

**២. ការអភិរក្សតំបន់ការពារធម្មជាតិដីគោក**

**អប់រំផ្សព្វផ្សាយ ពង្រឹងសមត្ថភាព ពីការគ្រប់គ្រងធនធានធម្មជាតិ និង សេវាគាំទ្រការងារនាយកដ្ឋាន**

- បានចុះសិក្សាស្រាវជ្រាវនិងប្រមូលសំណាករុក្ខជាតិនៅភ្នំខាស់ ស្រុកកំពង់ត្រាច ខេត្តកំពត
- បានចុះពិនិត្យវាយតម្លៃតំបន់ទេសចរណ៍ធម្មជាតិតេទឹកពុះដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ភូមិសាស្ត្រខេត្តកំពង់ស្ពឺ
- បានចូលរួមពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិចំនួន ០៤ (បឹងកាឆាង ពាមក្រសោប អណ្តូងទឹក និងជីខលើ) នៃតំបន់ការពារធម្មជាតិ ខេត្តកោះកុង
- បានចូលរួមពិនិត្យវាយតម្លៃផ្ទៀងផ្ទាត់វឌ្ឍភាព នៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ ស្ថិតក្នុងតំបន់ ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារធម្មជាតិខេត្តពោធិ៍សាត់ និងខេត្តឧត្តរមានជ័យ
- បានចូលរួមពិនិត្យវាយតម្លៃ ផ្ទៀងផ្ទាត់វឌ្ឍភាព នៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ ស្ថិតក្នុងតំបន់ ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារធម្មជាតិខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ
- បានចូលរួមពិនិត្យវាយតម្លៃផ្ទៀងផ្ទាត់វឌ្ឍភាព នៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ ស្ថិតក្នុងតំបន់ ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារធម្មជាតិខេត្តកោះកុង ខេត្តកំពត និងខេត្តព្រះសីហនុ
- បានចុះត្រួតពិនិត្យជាក់ស្តែងលើទីតាំងស្នើសុំជួលដីទំហំ ៨,៦០ហិកតា ស្ថិតនៅភូមិស្ទឹងប្រាំពីរ ឃុំម៉ាក់ ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត សម្រាប់ធ្វើការវិនិយោគមណ្ឌលទេសចរណ៍ធម្មជាតិ
- បានចុះសិក្សាវាយតម្លៃតំបន់ដែលមានសក្តានុពលក្នុងការបង្កើតទេសចរណ៍ធម្មជាតិក្នុងដែនជម្រក សត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងខេត្តពោធិ៍សាត់
- បានចុះត្រួតពិនិត្យ និងវាយតម្លៃសក្តានុពលក្នុងការដាក់តំបន់ភ្នំនាងកង្រីទៅជាតំបន់ការពារធម្មជាតិ
- បានចូលរួមកំណត់ហេតុទទួលស្នាក់ការរបស់ខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ មកអោយមន្ទីរ បរិស្ថានខេត្តព្រះសីហនុ

- បានរៀបចំវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ដល់មន្រ្តីឧទ្យានុរក្ស អ្នកពាក់ ព័ន្ធ ជាពិសេសសហគមន៍មូលដ្ឋាន ក្នុងការពង្រឹងសមត្ថភាព និងលើកកំពស់ការយល់ គាត់យល់ដើម្បី ចូលរួមគ្រប់គ្រងធនធានធម្មជាតិ តាមរយៈការចូលរួម ទប់ស្កាត់ ការពារអភិរក្ស និងការប្រើប្រាស់ធន ធានធម្មជាតិក្នុងតំបន់ឱ្យមាននិរន្តរភាព នៅខេត្តព្រះវិហារ។
- បានរៀបចំសិក្ខាសាលាស្តីពីការពង្រឹងការអនុវត្តច្បាប់ និងនិតិវិធីដោះស្រាយបទល្មើស ដោយ អនុវត្ត ទៅតាមជំពូកទី៩ នៃច្បាប់តំបន់ការពារធម្មជាតិក្នុងការបំពេញភារកិច្ចជាមន្រ្តីនគរបាល យុត្តធម៌ និងជា ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត ស្រាវជ្រាវ ទប់ស្កាត់បទល្មើស ធនធានធម្មជាតិនៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដែល ត្រូវអនុវត្តស្របតាមនិតិវិធីក្រម ព្រហ្មទណ្ឌ។
- នាយកដ្ឋានបានចុះពិនិត្យស្ថានភាពទីតាំងជាក់ស្តែង ដើម្បីធ្វើការដាំស្តារព្រៃឈើឡើងវិញក្នុង ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ខេត្តសៀមរាប ដែលមានទីតាំងស្តារព្រៃឈើមាន ០៤កន្លែង សរុបផ្ទៃដី ១៦,៣ ហិកតា។ ក្នុងនោះយើងពិនិត្យឃើញថា ផ្ទៃដីដែលត្រូវដាំ និងស្តារ កូនឈើឡើងវិញចំនួន ៤០០០០ ដើម៕

# ក្រសួងបរិស្ថានបើកវគ្គបណ្តុះបណ្តាលឧទ្យាននុរក្សលើកទី២





ក្រសួងបរិស្ថានបានសហការជាមួយយោធភូមិភាគទី១ បើកវគ្គបណ្តុះបណ្តាលមន្ត្រីឧទ្យាននុរក្សជំនាន់ទី២ មកពីខេត្តចំនួន៥ដែលមានចំនួន៨៥នាក់នៅបញ្ជាការដ្ឋានយោធភូមិភាគទី១ នៅខេត្តស្ទឹងត្រែង ក្រោមអធិបតីភាព**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាននៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៧។ មន្ត្រីឧទ្យាននុរក្សទាំងអស់មកពីខេត្តចំនួន៥ដែលមានខេត្ត ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី ក្រចេះ និងត្បូងឃ្មុំដែលនឹងត្រូវចាប់ផ្តើមហ្វឹកហ្វឺនរយៈពេល២សប្តាហ៍។ សិក្ខាកាម **លោក ផាន សុវណ្ណដែក** មន្ត្រីឧទ្យានុរក្សខេត្តក្រចេះ បានឱ្យដឹងថាវគ្គនេះសំខាន់ណាស់ព្រោះបានបង្កើនសមត្ថភាពមន្ត្រីឧទ្យាននុរក្សគ្រប់រូបឱ្យស្វែងយល់ពីយុទ្ធសាស្ត្រការពារផ្ទាល់ខ្លួន និងវិធីសាស្ត្រការពារធនធានធម្មជាតិ រួមទាំងការតស៊ូរស់នៅជាមួយបងប្អូនកងទ័ពជាដើម។

ក្រោយបញ្ចប់វគ្គនេះ **លោក ផាន សុវណ្ណដែក** ជឿជាក់ថាបទពិសោធន៍និង ចំណេះដឹងចេញពីវគ្គបណ្តុះបណ្តាលនេះនឹងអាចបម្រើការងារក្នុងនាមជាមន្ត្រីឧទ្យានុរក្សឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ថ្លែងក្នុងពិធីបើក ឯកឧត្តមរដ្ឋមន្ត្រី បានណែនាំឲ្យសិក្ខាកាមទាំងអស់ត្រូវប្រឹងប្រែងរៀនសូត្រនិងត្រូវរក្សាសុខភាពឲ្យបានល្អដោយជៀសវាងបរិភោគអាហារដែលមិនបានចម្អិនល្អជាដើម។ ឯកឧត្តមបានសង្កត់ធ្ងន់ថា មន្ត្រីឧទ្យាននុរក្សគឺជាឆ្មាំចាំយាមសម្បត្តិធម្មជាតិរបស់កម្ពុជាហើយជាពិសេស គឺជាប្អូនប្រុសរបស់កងយោធពលខេមរភូមិន្ទក្នុងការការពារបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា៕





## ទស្សនកិច្ចសិក្សាយុវជនបរិស្ថាន ជំរុញការផ្សព្វផ្សាយចំណេះដឹងលើការចូលរួមការពារនិងអភិរក្សធនធានធម្មជាតិ





ក្រុមយុវជនជាង២០នាក់ បានទទួលព័ត៌មាន និងចំណេះដឹងពីសក្តានុពល រួមទាំងការពារ និងអភិរក្សធនធានធម្មជាតិ នៅដែនជម្រកសត្វព្រៃសៀមប៉ាងខាងលិច ក្នុងខេត្តស្ទឹងត្រែង។ លោក កៀង កេសរបេរកុណា ប្រធានយុវជនវិស័យបរិស្ថាន បានអោយដឹងថា យុវជននៃក្រសួងបរិស្ថាន សហភាពសព័ន្ធ យុវជនកម្ពុជា រួមជាមួយសិល្បករ ចំនួនជាង២០នាក់ បានធ្វើទស្សនកិច្ចសិក្សា នៅក្នុងតំបន់ដែនជម្រកសត្វព្រៃសៀមប៉ាងខាងលិច ខេត្តស្ទឹងត្រែងរយៈពេល០៣ថ្ងៃចាប់ពីថ្ងៃទី០៨ ដល់ ១០ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីចូលរួមការពារ និងអភិរក្សធនធានធម្មជាតិ។ លោក ដួង ពៅ អភិបាលរងខេត្តស្ទឹងត្រែង បានសំដែងការគាំទ្រចំពោះព្រឹត្តិការណ៍នេះ ដែលរួមចំណែកបណ្តុះចិត្តប្រជាពលរដ្ឋ ជាពិសេសយុវជន អោយស្រឡាញ់បរិស្ថានកាន់តែច្រើន ហើយចូលរួមកាន់តែច្រើនក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ ដើម្បីប្រយោជន៍ប្រជាសហគមន៍មូលដ្ឋាន ជាពិសេសការទាក់ទាញទេសចរណ៍ និងការការពារប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់។ **លោក ដួង ពៅ** បានអះអាងដែរថា អាជ្ញាធរខេត្តស្ទឹងត្រែង នឹងខិតខំចូលរួមការពារ និងអភិរក្សធានធានធម្មជាតិអោយបានល្អប្រសើរ ជាពិសេសតំបន់ដែនជម្រកសត្វព្រៃ ឧទ្យានជាតិវីរៈជ័យ និងតំបន់រ៉ាមសារ ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង ជាតំបន់ស្នូលចុងក្រោយ ដែលសំបូរព្រៃឈើ និងសត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទថនិកសត្វជិតផុតពូជលើពិភពលោក។

**ឯកឧត្តម សូ ខនឬទ្ធិគុណ** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន បានបញ្ជាក់ថា កន្លងមកក្រសួងបរិស្ថានបានសហការជាមួយដៃគូពាក់ព័ន្ធ ប្រឹងប្រែងការពារ និងអភិរក្សធានធានធម្មជាតិ តាមរយៈច្បាប់ស្តីពីការការពារធនធានធម្មជាតិ។ ឯកឧត្តម បានបញ្ជាក់ថា កម្ពុជាឈរលេខរៀងទី២ នៅក្នុងតំបន់អាស៊ីដែលមានព្រៃការពារធំជាងគេ។ តាមទូរលេខនៃក្រសួងបរិស្ថាន កម្ពុជាមានតំបន់ការពារ និងអភិរក្សធានធានធម្មជាតិចំនួនសរុបជាង **៧.៥០០.០០០ ហិចតា ដែលនេះ**ជាការយកចិត្តទុកដាក់បំផុតរបស់រាជរដ្ឋាភិបាល ដែលកំពុងការពារ និងអភិរក្សកេរ្តិ៍ដំណែលរបស់ខ្លួនបានល្អប្រសើរ។ ឯកឧត្តមអនុរដ្ឋលេខាធិការ បានបន្ថែមថា ទស្សនកិច្ចសិក្សាយុវជនបរិស្ថាន បានជំរុញការផ្សព្វផ្សាយពង្រឹងការយល់ដឹងកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ ថែមទៀត តាមរយៈការទទួលបានព័ត៌មាន និងបទពិសោធន៍ពីមន្ត្រីឧទ្យាននុរក្ស តំណាងអង្គការដៃគូរសហការ និងអ្នកពាក់ព័ន្ធលើវិស័យបរិស្ថាន ហើយបន្តផ្សព្វផ្សាយ និងការចែករំលែកចំណេះដឹងបានពីព្រឹត្តិការណ៍ជួបជុំយុវជននាពេលនេះ ដល់មិត្តភ័ក្ត

បងប្អូន ក្រុមគ្រួសាររបស់ខ្លួនថែមទៀត អោយចេះស្រឡាញ់ធនធានធម្មជាតិនិងចូលរួមការពារនិងអភិរក្សផងដែរ។សូមបញ្ជាក់ថា ដោយមានការសហការ គាំទ្រពីអង្គការជីវិតសត្វស្លាបអន្តរជាតិ BirdLife និងអាជ្ញាធរមូលដ្ឋាន ទស្សនកិច្ចសិក្សាយុវជនបរិស្ថានបានធ្វើសកម្មមួយចំនួនរួមមានៈ ១-ការផ្លាស់ប្តូរបទពិសោធន៍ការនៅក្នុងព្រៃ និងការផ្សាភ្ជាប់ទៅនឹងធម្មជាតិ ២-ទទួលបទពិសោធន៍ពីបង១ឧទ្យានុរក្ស និងអង្គការ BirdLife អន្តរជាតិ ៣-សិក្សាពីសត្វត្មាត និងទស្សនាអាហារដ្ឋានសត្វត្មាត ៤-សិក្សានិងទស្សនាអំពីគម្រោងស្រូវមិត្តភាពសង្គ្រោះសត្វព្រៃ ៥-យុទ្ធនាការអប់រំ និងផ្សព្វផ្សាយអំពី ការការពារនិងអភិរក្សធនធានធម្មជាតិ ៦-ការផ្សារភ្ជាប់តន្ត្រីបុរាណ និងសម័យទៅនឹងធម្មជាតិ ៧-ផ្សព្វផ្សាយពីសក្តានុពលរបស់ធនធានធម្មជាតិ។យោងតាមការ អោយដឹងពី មន្ទីរបរិស្ថានខេត្តស្ទឹងត្រែង តំបន់ដែនជម្រកសត្វព្រៃសៀមប៉ាងខាងលិច មានផ្ទៃដីចំនួន៦៥.៣៨៩ ហិចតា ស្ថិតក្នុងស្រុងសៀមប៉ាង ខេត្តស្ទឹងត្រែង។ មន្ត្រីឧទ្យានុរក្សចំនួន១៦នាក់កំពុងការពារដោយយកចិត្តទុកដាក់ទប់ស្កាត់បទល្មើសនានា។ នៅក្នុងដែនជម្រកសត្វព្រៃ មានត្រពាំងទឹកជាង២០០កន្លែងដែលជាប្រភពទឹក និងចំណីអាហារសម្រាប់សត្វបក្សី និងថនិកសត្វគ្រប់ប្រភេទ ជាពិសេសសត្វស្លាបទឹកជិតផុតពូជនៅលើពិភពលោក ដូចជាសត្វត្រយ៉ងយក្ស ត្រយ៉ងចង្កំកស ត្រដក់ធំ ត្រដក់តូច អង្កត់ខ្មៅ សត្វកស និងសត្វក្រៀលជាដើម។ តំបន់ដែនជម្រកសត្វព្រៃសៀមប៉ាងខាងលិច មានសារៈសំខាន់ជាតំបន់ជីវៈចម្រុះ និងជារមណីយដ្ឋានទេសចរណ៍ធម្មជាតិដ៏ល្អ សម្រាប់ជីវភាពប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានផងដែរ៕





យើងមានមន្ត្រីសមភាគីជាមួយអង្គការ WCS ក្នុងការសិក្សាស្រាវជ្រាវអំពីធនធានជីវៈចម្រុះ នៅលើទីវាល ក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ខេត្តព្រះវិហារ ដែលប្រើកម្មវិធី (Spatial Monitoring and Reporting Tool SMART) ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធទៅនឹងសត្វព្រៃ រុក្ខជាតិ និងជីវៈចម្រុះ។ ក្រុម ការងារបានចុះសិក្សានៅតាមដងស្ទឹងមេម៉ាយ ស្ទឹងសំបូរ អូរអំពិល អូរគេគី តំបន់កាខិកចាស់ ភ្នំបាវ៉ាយ ដើម្បីស្រាវជ្រាវនូវប្រភេទសត្វពងកូនសត្វត្មាត និងសត្វស្លាបសំខាន់ៗៈ

- ថនិកសត្វៈ កម្រុកធំ ឈ្លូស ជ្រូកព្រៃ និងស្វាក្តាម
- សត្វស្លាបៈ កុកគ្រោង កុកគ្រោងតូច អកពោះព្រៃ ត្រយ៉ងយក្ស ក្អែកទឹក ពពូលទឹក ត្រដក់តូច ក្រៀល ត្រយ៉ងចំកំកស កុកពាក់អំបោះ ទាព្រៃស្លាបស
- បានធ្វើការជំរឿនក្រៀល ៣៦ក្បាល
- ធ្វើការជំរឿនស្លាបទឹក បានចំនួន ៧៩២ក្បាល

| ល.រ | តំបន់ | ចំនួនសំបុក |
|---|---|---|
| ១. សំបុកសត្វត្រយ៉ងចង្កំស | | |
| | ត្មាតប៉ើយ | ៦ |
| ២. សំបុកសត្វត្រដក់តូច | | |
| | អន្ទិល | ៥ |
| | ពោរាង | ២ |
| ៣. សំបុកសត្វត្រយ៉ងយក្ស | | |
| | កោងយោង | ២ |
| | ត្មាតប៉ើយ | ១ |

ការចុះសិក្សាសត្វកម្រ ដូចជា ពពូលទឹក ទាព្រៃស្លាបស នៅតាមបណ្តោយស្ទឹងមេម៉ាយ និងស្ទឹងសំបូរ។

- បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីផែនការស្តារសត្វខ្លាធំ នៅដែនជម្រកសត្វព្រៃភ្នំព្រេច ខេត្តមណ្ឌលគិរី ដែលមានការចូលរួមពីលោកមាស សុផល អគ្គនាយករងនៃអគ្គរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ, មន្ត្រីនៃនាយកដ្ឋានអភិរក្សតំបន់ដីគោកខាងកើតទន្លេមេគង្គ និង Mr Mark មកពីអង្គការWWF។ កិច្ចប្រជុំនេះបានពិភាក្សា និងពិនិត្យទៅលើផែនការព្រាងស្តារសត្វខ្លាធំ និងការចាត់និតិវិធីបន្តដើម្បី អោយផែនការនេះកាន់តែមានប្រសិទ្ធភាព។
- បានចុះពិនិត្យទីតាំងលើផ្ទៃដីស្នើសុំសាងសង់វត្តទំហំ២ ៨៩២ ៩៤០ម៉ែត្រការ៉េ នៅភូមិឡៅការ ក្នុង ដែនជម្រកសត្វព្រៃកែវសីមា(ខេត្តមណ្ឌលគិរី) ព្រមទាំងសិក្សាពីផលប៉ះពាល់ផ្សេងៗដែលអាចកើត មានទាក់ទងនិងការសាងសង់នេះ៕

## តើតំបន់ប្រើប្រាស់ច្រើនយ៉ាងជាអ្វី?





តំបន់ប្រើប្រាស់ច្រើនយ៉ាង សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬដែនទឹក ដែលក្នុងនោះមានសម្បូរណ៍ដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការប៉ះផ្លិចបំផ្លាញ និងតម្រូវឱ្យមានសកម្មភាពគ្រប់គ្រង ដើម្បីធានាការការពារ ការថែទាំធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសម្រាប់ពេលយូរអង្វែង។ ទន្ទឹមនឹងនេះដែរ អាចផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។ តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៣តំបន់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងទីតាំងចំនួន២តំបន់ទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦។ តំបន់ប្រើប្រាស់ច្រើនយ៉ាងទាំង៥តំបន់ គ្របដណ្តប់នៅលើផ្ទៃដីសរុបចំនួន៤០៩.៦៦៩ហិកតា ដែលស្មើនឹង ២,៣% នៃផ្ទៃដីប្រទេស ស្ថិតនៅក្នុងខេត្តសៀមរាប កោះកុង បាត់ដំបង កំពង់ធំ កំពង់ឆ្នាំ ប៉ៃលិន ពោធិ៍សាត់ ត្បូងឃ្មុំ និងខេត្តព្រះសីហនុ។

តំបន់ប្រើប្រាស់ច្រើនយ៉ាងរួមមាន ១. ដងពែង ស្ថិតនៅក្នុងខេត្តកោះកុង ដែលមានផ្ទៃក្រឡា ២៧.៧០០ហិកតា ចេញដោយព្រះរាជក្រឹត្យ០១ វិច្ឆិកា ១៩៩៣ ២. សំឡូត ស្ថិតនៅក្នុងខេត្តប៉ៃលិន និងបាត់ដំបង ដែលមានផ្ទៃក្រឡា ៦០.០០០ ចេញដោយអនុក្រឹត្យ ០១ វិច្ឆិកា ១៩៩៣ ៣. ទន្លេសាប ស្ថិតក្នុងទីតាំងកំពង់ធំ កំពង់ឆ្នាំ ពោធិ៍សាត់ បាត់ដំបង និងសៀមរាប ដែលមានផ្ទៃក្រឡា៣១៦.២៥០ ចេញដោយព្រះរាជក្រឹត្យ ០១ វិច្ឆិកា ១៩៩៣ ៤. ពញាក្រែក ស្ថិតនៅទីតាំង ខេត្តត្បូងឃ្មុំ ដែលមានផ្ទៃក្រឡា១៩៩ហិកតា ចេញដោយអនុក្រឹត្យ ០៩ ឧសភា ២០១៦ ៥. ព្រែកទឹកសាបក្បាលឆាយ ស្ថិតនៅក្នុងខេត្តព្រះសីហនុ ដែលមានផ្ទៃក្រឡា ៥.៥២០ហិកតា ចេញដោយអនុក្រឹត្យ ០៥ មិថុនា ២០១៦៕

## ឧទ្យានជាតិវីរៈជ័យៈ សក្តានុពលលើសត្វព្រៃ និងសម្រស់ត្រកាលនៃធម្មជាតិ ដែលអ្នកធ្វើដំណើរផ្សងព្រេងគួរសាកល្បង





ឧទ្យានជាតិវីរៈជ័យស្ថិតក្នុងភូមិសាស្ត្រខេត្តរតនៈគីរី និងខេត្តស្ទឹងត្រែងដែលមានផ្ទៃដីចំនួន ៣៣២.៥០០ ហិកតា។ បើយើងនិយាយពីសក្តានុពលក្នុងឧទ្យានជាតិវីរៈជ័យ នៃភូមិសាស្ត្រខេត្តប៉ែកឦសានមួយនេះ ធម្មជាតិក្នុងព្រៃ និងតាមដងអូ រួមទាំងសត្វព្រៃគឺជាអ្វីដែលធ្វើឱ្យឧទ្យានជាតិមួយនេះមានសម្រស់ស្រស់ត្រកាលបង្អួតអ្នកដែលបានទស្សនា និងរង់ចាំភ្ញៀវទេសចរដែលហ៊ានប្រជែងមើលសម្រស់ដ៏ត្រកាល។ ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ សត្វព្រៃជាច្រើនកំពុងសំងំរស់នៅយ៉ាងមានសេចក្តីសុខដែលមានដូចជា សត្វស្វា កន្ទុយសរ ទោច ជ្រូកព្រៃ ឈ្លូស ប្រើស ខ្លាត្រី ខ្លាពពក ខ្ទីង និង ខ្លាឃ្មុំជាដើម។ ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ សត្វព្រៃជាច្រើនកំពុងសំងំរស់នៅយ៉ាងមានសេចក្តីសុខដែលមានដូចជា សត្វស្វា កន្ទុយសរ ទោច ជ្រូកព្រៃ ឈ្លូស ប្រើស ខ្លាត្រី ខ្លាពពក ខ្ទីង និង ខ្លាឃ្មុំជាដើម។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលចូលទៅព្រៃជ្រៅនោះមានទឹកជ្រោះមួយហៅថា (ទឹកជ្រោះយក្សកែ) នៅរដូវវស្សាទឹកធ្លាក់នោះស្អាតណាស់ហើយថ្លាមែនទែនដែលគួរចាប់អារម្មណ៍យ៉ាងខ្លាំង ដែលមានទឹកគ្រប់គ្រាន់សំរាប់ការលេងយ៉ាងសប្បាយ។ ដើម្បីទៅដល់ទីតាំងកំសាន្តនេះ អ្នកទេសចរត្រូវធ្វើដំណើរប្រមាណ១៥គីឡូម៉ែត្រពីស្រុកតាវែងទៅដល់ភូមិមណ្ឌលយ៉ន ដែលអ្នកទេសចរត្រូវឆ្លងកាត់ទន្លេសេសាន និងអូរតាបូកនៅទីនោះហើយដែលអ្នកទេសចរអាចមើលឃើញផ្កាព្រៃ ទេសភាពតាមដងព្រៃជាដើម។ ដោយឡែកនៅក្នុងតំបន់ស្រស់ត្រកាលនេះ ជនជាតិដើមភាគតិចព្រៅ គឺជាម្ចាស់ស្រុកដែលនឹងធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវទេសចរណ៍ដែលផ្តលការស្នាក់នៅដោយផាសុខភាពបែបជនជាតិ និងការរីករាយជាមួយវប្បធម៌ប្រពៃណី ម្ហូបអាហារ និងស្រាពាងរបស់ជនជាតិដើមព្រៅ៕

ប្រភព៖ មន្ទីរបរិស្ថានខេត្តរតនៈគីរី

# ការគ្រប់គ្រងតំបន់ដីសើមទឹកសាប

ព្រះរាជាណាចក្រកម្ពុជា គ្របដណ្តប់ដោយតំបន់ដីសើមច្រើនជាង៣០%នៃផ្ទៃប្រទេស ហើយដែលក្នុងនោះលើសពី២០% នៃដីសើមដែលមានក្នុងផ្ទៃប្រទេស ទាំងនោះគឺមានសារៈសំខាន់ជាអន្តរជាតិ។ តំបន់ដីសើមសំខាន់ៗទាំងនោះមាននៅតាមបណ្តោយទន្លេមេគង្គ បឹងទន្លេសាប នឹងនៅតំបន់ឆ្នេរ។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានយកចិត្តទុកដាក់ក្នុងកិច្ចការពារតំបន់ដីសើម ដែលមានតម្លៃជាសាកលរបស់កម្ពុជា ជាក់ស្តែងក្នុងឆ្នាំ១៩៩៦។ កម្ពុជាបានអនុម័តលើអនុសញ្ញារ៉ាមសារ និងបានចូលជាសមាជិកពេញសិទ្ធនៅថ្ងៃទី២៣ ខែតុលាឆ្នាំ ១៩៩៩ ។អនុសញ្ញារ៉ាមសារ គឺជាអនុសញ្ញាអន្តរជាតិដែលបានបង្កើតឡើងក្នុងគោលបំណង ការពារតំបន់ដីសើមដែលមានសារសំខាន់ជាអន្តរជាតិ។ ករណីកិច្ចដ៏សំខាន់មួយនៃប្រទេសជាសមាជិកអនុសញ្ញារ៉ាមសារ គឺការពារតំបន់ដីសើមដែលមានសារសំខាន់ជាអន្តរជាតិ ដោយដាក់បញ្ចូលតំបន់ដីសើមទាំងនោះ ជាតំបន់រ៉ាមសារ និងវិធានការគ្រប់គ្រង និងប្រើប្រាស់ធនធានដីសើមដោយឈ្លាសវៃ ហេតុនេះហើយ ទើបកម្ពុជាបានដាក់បញ្ចូលតំបន់ដីសើមចំនួន៤រួចមកហើយ ជាតំបន់រ៉ាមសារ ក្នុងនោះមានតំបន់រ៉ាមសារ បឹងឆ្មារ តំបន់រ៉ាមសារព្រែកទាល់ ស្ថិតនៅបឹងទន្លសាប តំបន់រ៉ាមសារ ស្ទឹងត្រែង ស្ថិតនៅតាមដងទន្លេមេគង្គ និងតំបន់រ៉ាមសារកោះកាពិក នៅតំបន់ឆ្នេរ ដែលមានផ្ទៃដីសរុប៧៥,៩៤២ហិកតា។ ហើយកាលពីថ្មីៗនេះ នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នៃអគ្គនាយករដ្ឋបាលការពារធម្មជាតិ ក្រសួងបរិស្ថាន បានរៀបចំបើកសិក្ខាសាលា ពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការដាក់បញ្ចូលតំបន់ស្នូលស្ទឹងសែននិងតំបន់ជុំវិញ ជាតំបន់រ៉ាមសារក្រោមអធិបតីភាព **ឯកឧត្តមស៊ូ សូវុធ** អនុរដ្ឋលេខាក្រសួងបរិស្ថាន ព្រមទាំងវត្តមាន **ឯកឧត្តម ហ្សួន ម៉ានិត** អភិបាលរងខេត្តកំពង់ធំ **ឯកឧត្តម តែ ណាវុធ** អគ្គលេខាគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា **ឯកឧត្តម ជា សំអាង** អគ្គនាយក នៃអគ្គនាយកកដ្ឋានការពារនិងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន លោកបណ្ឌិត **ស៊ូបាសា អ៊ីវ៉ាប៊ូជី** តំណាងឲ្យក្រសួងបរិស្ថានប្រទេជប៉ុន និងចូលរួម ពីសំណាក់ អស់លោក លោកស្រី ប្រធានអនុប្រធានមន្ទីរពាក់ពន្ធ័ អាជ្ញាធរស្រុក ឃុំ តំណាង អង្គការមិនមែនរដ្ឋាភិបាល ប្រមាណជាង៤០នាក់ចូលរួម។ គោបំណងនៃសិក្ខាសាលា ១- ចែករំលែកព័ត៌មានអំពីអនុសញ្ញាអន្តរជាតិ ការការពារតំបន់ដីសើមរ៉ាមសារ និងសក្តានុពលតំបន់ដីសើមក្នុងប្រទេសកម្ពុជា ២- ការរាយការណ៍ពីវឌ្ឍនៈភាពនៃដំណើរការដាក់បញ្ចូល តំបន់ស្នូលស្ទឹងសែនជាតំបន់រ៉ាមសារ ៣- ពិភាក្សាប្រមូលធាតុចូល និងទទួលអនុសាសន៍បន្ថែមពីអ្នកពាក់ពន្ធ័ លើដំណើរកដាក់បញ្ចូលតំបន់ស្នូលស្ទឹងសែននិងតំបន់ជុំវិញ ជាតំបន់រ៉ាមសារ ទីប្រាំ របស់ប្រទេកម្ពុជា។

គួសបញ្ជាក់ថា តំបន់ស្នូលស្ទឹងសែនមានផ្ទៃដីសរុប( ៦ពាន់ ៣រយ៥៥ហិកតា ) ស្ថិនៅឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្ត កំពង់ ធំ។ហើយតំបន់ស្នូលរ៉ាមសារស្ទឹងសែន ជាទីជម្រកដ៏សំខាន់ សម្រាប់មច្ឆាពងកូន ដោយវាគាំទ្រប្រភេទព្រៃលិចទឹកដ៏កម្រ និងតំបន់នេះក៏គាំទ្រដល់ការរស់នៅរបស់ថនិកសត្វយ៉ាងតិច៩ប្រភេទ និងសត្វស្លាបយ៉ាងតិច ៧៩ ប្រការទដែលរស់នៅក្នុងនោះ ដែប្រភេទមួយចំនួនជាប្រភេទជិតផុត ពូជ និងកំពុងរងការគំរាមកំហែងជាសាកល ដូចជាស្វាព្រាម កេរោមប្រមុះ និងត្រដក់តូចជាដើម។



នាយកដ្ឋានចូលរួមប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយលើផលប៉ះពាល់ក្នុងគោលបំណងអភិរក្សផ្ទៃអាងស្តុកទឹកអូរខែជន សម្រាប់ស្តុកទឹកផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាត និងវិស័យកសិកម្មនៅក្រុងប៉ោយប៉ែត ចំនួន០១លើក(ចំនួន០៤រូប)

- ចុះពិនិត្យ និងវាស់វែងលើដីអាស្រ័យផលជាក់ស្តែងនៅក្នុងតំបន់ការពារទេសភាពទំនាបខាងជើងបឹង ទន្លេសាប សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋ១៣គ្រួសារ ស្រុកស្ទោង ខេត្តកំពង់ធំ ចំនួន០១លើក(ចំនួន០៤រូប)
- ចុះសិក្សាលម្អិតលើផ្ទៃដីពង្រីកបន្ថែម និងកំណត់ព្រំប្រទល់ថ្មីរបស់តំបន់ស្នូលស្ទឹងសែនត្រៀមស្នើដាក់ បញ្ចូលជាតំបន់រ៉ាមសារស្ទឹងសែន ខេត្តកំពង់ធំ ចំនួន០១លើក(ចំនួន០២រូប)
- ចុះត្រួតពិនិត្យតំបន់រ៉ាមសារខេត្តស្ទឹងត្រែង និងសួរសុខទុក្ខមន្ត្រីឧទ្យានុរក្ស នៅឃុំអូរស្វាយ ខេត្តស្ទឹង ត្រែងចំនួន០១លើក(ចំនួន០៣រូប)
- ចុះជួយសម្របសម្រួលនិងជូនគណៈប្រតិភូចិនទៅទស្សនកិច្ច នៅតំបន់រ៉ាមសារព្រែកទាល់ចំនួន០១ លើក(ចំនួន០៣រូប)
- ចុះត្រួតពិនិត្យ និងអង្កេតតាមដានអំពីសក្តានុពល តំបន់បឹងពៀរាំង ដែលប្រើប្រាស់ដោយប្រភេទសត្វ ស្លាបទឹកសំខាន់ៗ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាបភូមិសាស្ត្រខេត្តសៀមរាបចំនួន០១ លើក (ចំនួន០៥រូប)
- ចុះពិនិត្យ និងអង្កេតតាមដានបន្ទាយពងកូនរបស់សត្វស្លាប ទឹកសំខាន់ៗនៅតំបន់រ៉ាមសារព្រែកទាល់ ខេត្តបាត់ដំបង ចំនួន០១លើក(ចំនួន០៥រូប)៕

# ការគ្រប់គ្រងធនធានសមុទ្រ និងតំបន់ឆ្នេរ




នាទីក្រុងហាណូយ សាធារណរដ្ឋវៀតណាម ថ្ងៃទី ១៩-២០ ខែកញ្ញា ឆ្នាំ2017 នាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ នៃអគ្គនាយដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោង " ប្រែប្រួលអាកាសធាតុឆ្នេរសមុទ្រតំបន់អាស៊ាន ៖ រួមមាន ភាពងាយរងគ្រោះ ផលប៉ះពាល់ និងការបន្សាំ " (ជំហ៊ាន ១) ដោយមានការចូលរួមពីមន្ត្រីបង្គោលបរិស្ថានសមុទ្រ និងឆ្នេរនៃប្រទេសសមាជិកអាស៊ាន តំណាងកិច្ចសហប្រតិបត្តិការជប៉ុន-អាស៊ាន តំណាងលេខាធិការអាស៊ាន និងថ្នាក់ដឹកនាំ មន្ត្រីជំនាញនៃក្រសួងបរិស្ថាននិងធនធានធម្មជាតិ វៀតណាម សរុប 35 រូប។ កិច្ចប្រជុំនេះ មានគោលបំណងពិនិត្យឡើងវិញនូវការអភិវឌ្ឍគោលនយោបាយ និងផែនការឆ្នេរសមុទ្រថ្នាក់តំបន់ សម្រាប់ប្រទេសសមាជិកអាស៊ាន ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការកើនឡើងកំពស់ទឹកសមុទ្រ។កិច្ចពិភាក្សា និងការចែករំលែកលើសេចក្តីព្រាងចេញជាពីរទី ១ ការចងក្រងរបាយការណ៍ស្តីពី ភាពងាយរងគ្រោះ ការអភិវឌ្ឍគោលនយោបាយ ផែនការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងឆ្នេរសមុទ្របែបសមាហរណកម្មតំបន់អាស៊ាន ទី២ គំនិតផ្តួចផ្តើម ស្តីពី ក្របខ័ណ្ឌគោលនយោបាយសម្រាប់ ការគ្រប់គ្រងតំបន់ឆ្នេរបែបសមាហរណកម្មឆ្លើយតបនិងការប្រែប្រួលអាកាសធាតុ៕

# ទិវាឧទ្យានុរក្សពិភពលោក៖
# ឧទ្យានុរក្សជាឆ្មាំជួរមុខប្រកបដោយវីរភាពការពារធនធានធម្មជាតិ

ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ គឺជាទិវាឧទ្យានុរក្សពិភពលោក (World Ranger Day)។ ទិវានេះឧទ្ទិសដល់កិច្ចខិតខំប្រឹងប្រែងរបស់ឧទ្យានុរក្សដែលបានលះបង់ដោយប្រឈមគ្រោះថ្នាក់គ្រប់បែបយ៉ាងដើម្បីការពារ និងអភិរក្សសត្វព្រៃ និងព្រៃឈើ។ សម្រាប់ថ្ងៃនេះដែរ កម្ពុជាវិញដែលជាដែនដីសម្បូរទៅដោយធនធានធម្មជាតិ ក៏មានវីរៈបុរសរបស់ខ្លួនដែលបានការពារសត្វព្រៃ និងព្រៃឈើ។ ឧទ្យានុរក្សរបស់យើង(កម្ពុជា) បានប្រឹងប្រែងយ៉ាងខ្លាំងយកអស់កម្លាំងកាយចិត្តដើម្បីការពារអភិរក្សប្រព័ន្ធអេកូឡូស៊ីដែលជាតំបន់មានតម្លៃបំផុត។




ក្រសួងបរិស្ថានដែលជាសេនាធិការរបស់រដ្ឋាភិបាលក្នុងកិច្ចការងារការពារអភិរក្សធនធានធម្មជាតិ សូមសំដែងគោរពចំពោះវីរៈភាពរបស់ឧទ្យានុរក្សរបស់កម្ពុជាដែលតែងតែយកចិត្តទុកដាក់លើកិច្ចការងារការពារធនធានធម្មជាតិ។ សូមបញ្ជាក់ថា រហូតមកដល់ពេលនេះ ក្រសួងបរិស្ថានមានឧទ្យានុរក្សប្រមាណជាង១២០០នាក់ ដែលកំពុងគ្រប់គ្រងលើផ្ទៃដីប្រមាណជាង៧លាន៥សែនហិកតានៅទូទាំងប្រទេស។ ក្នុងបេសកកម្មដ៏ធំធេងនេះ ឧទ្យានុរក្សរបស់បរិស្ថាន បានជួយសង្គ្រោះសត្វព្រៃរាប់ពាន់ក្បាលដែលត្រូវជនទុច្ចរិតជួញដូរ និងបានបង្ក្រាបសកម្មភាពបរបាញ់ខុសច្បាប់ និងការកាប់ឈើជាមជាច្រើនករណីទៀតដែរ។ សូមរំលឹកថា ក្នុងកិច្ចការពារធនធានធម្មជាតិ និងសត្វព្រៃ ក្រៅពីកិច្ចការងារដ៏សកម្មរបស់ក្រសួងបរិស្ថាននោះ អាជ្ញាធរមូលដ្ឋាន ប៉ូលិស ប៉េអឹមនិងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀតក៏បានចូលរួមយ៉ាងសកម្ម ដែលអ្នកទាំងនោះ "ឧទ្យានុរក្ស ប៉ូលិស ប៉េអឹម និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀត គឺសុទ្ធសឹងតែជាវីរៈបុរសកម្ពុជាដែលការពារសត្វព្រៃ និងធនធានធម្មជាតិ"៕




# សហគមន៍តំបន់ការពារធម្មជាតិ

## ការលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍មូលដ្ឋាន



នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ របស់គម្រោងរបៀងជីវៈចម្រុះមហាអនុតំបន់មេគង្គនៃក្រសួងបរិស្ថាន បានរៀបចំឡើង ដោយមានការចូលរួមពី **ឯកឧត្តម ប៉េង សម្បត្តិ** អភិបាលរងខេត្តមណ្ឌលគិរី **លោកបណ្ឌិត អ៊ូ រតនៈ** ប្រធានគម្រោងរបៀងជីវៈចម្រុះមហាអនុតំបន់មេគង្គនៃក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី តំណាងមន្ទីរបរិស្ថានខេត្តកោះកុង តំណាងអង្គការ និងសហគមន៍មូលដ្ឋានចំនួន៩៥នាក់។ កិច្ចប្រជុំនេះក្នុងគោលបំណងលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ នៅក្នុងតំបន់គោលដៅរបស់គម្រោង ដើម្បីបង្កើនជីវភាពប្រជាសហគមន៍ ក្នុងតំបន់ការពារធម្មជាតិពិសេសលើកតម្កើនជីវភាពជនជាតិភាគតិច។

ជាមួយគ្នានោះ ឯកឧត្តមអភិបាលរងខេត្ត បានលើកឡើងថា៖ ការកំណត់ និងជ្រើសរើសទីតាំងស្រះទឹក គម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គ នឹងបន្តជួយគាំទ្រសកម្មភាពកែលម្អជីវភាពរស់នៅដល់សហគមន៍តំបន់ការពារធម្មជាតិទាំង៥ ដែលជាផ្នែកមួយនៃការគាំទ្រផ្នែកជីវភាពរស់នៅ និងការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចពិសេសផ្តោតទៅលើស្រះរងទឹកភ្លៀង ដែលមានផលិតភាពក្នុងការស្រោចស្រពដំណាំ ក្នុងការទ្រទ្រង់ ដល់ការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងបង្កើនប្រាក់ចំណូលប្រចាំថ្ងៃដល់ពួកគាត់។

គួបញ្ជាក់ថា ការកំណត់ និងជ្រើសរើសទីតាំងស្រះទឹក សម្រាប់សហគមន៍តំបន់ការពារធម្មជាតិចំនួន៥ គឺសហគមន៍តំបន់ការពារធម្មជាតិរន្ទេសខ្វែង ជីខ្លបភ្នំជួង-ក្តីសង្ឃឹម ស្រែអ៊ី ស្រែធំ-ម្លីង និងសហគមន៍តំបន់ការពារធម្មជាតិពូទង់ពូហ៊្វង ក្នុងខេត្តមណ្ឌលគិរី និងសហគមន៍តំបន់ការពារធម្មជាតិចំនួន៤ សហគមន៍តំបន់ការពារធម្មជាតិ បឹងកាឆាង ដែនជម្រកសត្វព្រៃពាមក្រសោប អណ្តូងទឹក និងសហគមន៍តំបន់ការពារធម្មជាតិ ជីខលើ ក្នុងខេត្តកោះកុង ដោយមានការជួយគាំទ្រពីគម្រោងរបៀង អភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គក្រោមជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៕

## ស្គាល់ខេត្តកោះកុងហើយឬនៅ?
## (សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប រកចំណូលបានជាង២០០លានរៀលក្នុងឆ្នាំ២០១៦)



ក្រៅពីសហគមន៍អេកូទេសចរណ៍ជីផាត់ និងសហគមន៍អេកូទេសចរណ៍អារ៉ែង កោះកុងនៅមានសក្តានុពលធម្មជាតិជាច្រើនកន្លែងទៀតដែលកំពុងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ តំបន់ការពារធម្មជាតិពាមក្រសោប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិប្រមាណ៦៤០០០ នាក់នៅឆ្នាំ២០១៦នេះហើយចំណូលនៅឆ្នាំដដែលនេះគិតជាទឹកប្រាក់ប្រមាណ២០០លានរៀល។

តំបន់សហគមន៍ពាមក្រសោបដែលគ្របដណ្តប់ភូមិ១ និងភូមិ២ ក្នុងឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ខេត្តកោះកុងមានចម្ងាយ៧គីឡូម៉ែត្រពីទីរួមខេត្ត មានសក្តានុពល ឆ្នេរខ្សាច់ស្អាតប្លែក ព្រៃកោងកាង សត្វផ្សោត សត្វស្លាបទឹក ការនេសាទ ភូមិចាស់ និងការកែច្នៃផលនេសាទ។ សូមបញ្ជាក់ថាដែនជម្រកសត្វព្រៃពាមក្រសោបគ្របដណ្តប់សហគមន៍តំបន់ការពារធម្មជាតិចំនួន៥កន្លែង ដែលរួមមានសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប សហគមន៍តំបន់ការពារធម្មជាតិកោះស្រឡៅ សហគមន៍តំបន់ការពារធម្មជាតិកោះការពិ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង សហគមន៍តំបន់ការពារធម្មជាតិទួលគគីរ។ សហគមន៍តំបន់ការពារធម្មជាតិកោះស្រឡៅ ស្ថិតក្នុងភូមិកោះស្រឡៅ ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ដែលមានចម្ងាយ២៣គីឡូម៉ែត្រពីទីរួមខេត្ត មានសក្តានុពលព្រៃកោងកាង សត្វផ្សោត ចំការដំណាំ ការនេសាទ ជិះទូកកំសាន្ត និងឆ្នេរខ្សាច់។ សហគមន៍ តំបន់ការពារធម្មជាតិកោះការពិ ស្ថិតក្នុងភូមិកោះកាពិ ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ដែលមានចម្ងាយ២២គីឡូម៉ែត្រពីទីរួមខេត្ត មានសក្តានុពល កោះមានរាងមូល ព្រៃកោងកាង ឆ្នេរបំការដ្ឋងវត្តសម័យដើមឆ្នេរខ្សាច់និងសត្វស្លាបទឹក។ សហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង ស្ថិតក្នុងភូមិបឹងកាឆាង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដែលមានចម្ងាយពី១១គីឡូម៉ែត្រពីទីរួមខេត្ត មានសក្តានុពល ព្រៃកោងកាង ឆ្នេរខ្សាច់ សត្វផ្សោតជិះទូកកំសាន្តនិងមើលថ្ងៃលិច៕

## ហេតុអ្វីបានជាភ្នំត្បែងគឺជាកន្លែងទាក់ទាញសម្រាប់ការធ្វើដំណើរកំសាន្តចុងសប្តាហ៍?



តំបន់ភ្នំត្បែង គ្រប់ដណ្តប់លើផ្ទៃដីធម្មជាតិប្រមាណជាង ២៥,០០០ហិកតា ភ្នំត្បែង មានសម្រស់ធម្មជាតិស្អាតជាច់គេ មានទឹកធ្លាក់បីតង់តាម៉ា ទឹកធ្លាក់តាំងយូរ ឬចាក់អង្រែ រូងប្រជៀវភ្នំត្បែង និងទីតាំងសក្ការៈថ្មីបីដុំ។ ប៉ុន្តែមុននឹងឡើងដល់ទីតាំងដ៏ស្រស់ស្អាតទាំងនេះ អ្នកធ្វើដំណើរត្រូវឆ្លងកាត់ផ្លូវជម្រេលភ្នំ ដែលអមសងខាងដោយចំការចេកជាក់កន្ទុយក្អែក ហើយអ្វីដែលសំខាន់នោះគឺការឡើងភ្នំដែលមានកម្ពស់ជាង៤០០ម៉ែត្រដែលមានកាំជណ្តើរ១ពាន់៨រយកាំ។ សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាតាមរយៈសំណើររបស់ក្រសួងបរិស្ថាន បានដាក់បញ្ចូលតំបន់ភ្នំត្បែងចូលជាសម្បត្តិបេតិកភណ្ឌធម្មជាតិកាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។ តំបន់បេតិកភណ្ឌភ្នំត្បែងគ្រប់ដណ្តប់ចំនួន៥ស្រុក គឺស្រុក គូលេន សង្គមថ្មី ត្បែងមានជ័យ ក្រុងព្រះវិហារ និងរវៀង។

សូមបញ្ជាក់ថា ចាប់ពីថ្ងៃទី២៨ដល់ថ្ងៃទី៣០ ខែកក្កដានេះ យុវជនកម្ពុជាមួយក្រុមដែលមានគ្នាប្រមាណ៤០នាក់នឹងបោះតង់រយៈពេលបីថ្ងៃនៅតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងដែលស្ថិតក្នុងភូមិសាស្រ្ត ខេត្តព្រះវិហារ។

**លោក សា ឌីណា** ស្ថាបនិកក្រុមដំណើរកំសាន្ត Cambodia Amazing Trip Planner ដែលជាអ្នករៀបចំការបោះតង់នេះ បានបញ្ជាក់ថា ភ្នំត្បែងគឺជាតំបន់ធម្មជាតិដ៏ស្រស់ស្អាតដែលមានទឹកធ្លាក់ ព្រៃធម្មជាតិធំល្វឹងល្វើយ និងសត្វព្រៃ រួមទាំង ជាតំបន់ប្រវត្តិសាស្រ្តដែលព្រះរាជាខ្មែរកាលពីសម័យបូរាណបានធ្វើពិធីផ្សេងៗ។

លោកជឿជាក់ថា ដំណើរកំសាន្តផ្លូវការទី១របស់លោកទៅកាន់ភ្នំត្បែងនឹងទទួលបានជោគជ័យព្រោះថាអ្នកធ្វើដំណើរទាំងអស់នឹងភ្ញាក់ផ្អើលជាមួយនឹងសម្រស់ធម្មជាតិ តាំងពីជើងភ្នំ រហូតដល់កន្លែងកំសាន្តនានា ហើយលោកជឿជាក់ថា អ្នកបោះតង់ទាំងអស់នឹងនិយាយពាក្យមួយថាអស្ចារ្យ៕

## ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលក្នុងខេត្តកោះកុង
## តំបន់ពិសេសដែលអ្នកទេសចរណ៍ផ្សងព្រេងគួរសាកល្បង



*ទេសភាពព្រៃភ្នំនៅឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល។ រូបភាព មន្ទីរបរិស្ថានខេត្តកោះកុង។ ដោយ ស៊ុន មេសា/ប្រភព៖ មន្ទីរខេត្តកោះកុង*

ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលជាតំបន់សក្តានុពល ពិសេសសម្រាប់អ្នកទេសចរណ៍បែបផ្សងព្រេងគួរតែសាកល្បង។ តំបន់ដែលមានចំងាយប្រមាណ២៥គីឡូម៉ែត្រពីទីរួមស្រុកថ្មបាំង មានទឹកធ្លាក់ស្រស់ស្អាត សត្វព្រៃជាច្រើនប្រភេទដែលរួមមានក្រពើភ្នំ ទេសភាពតាមព្រៃភ្នំដ៏គួរឱ្យទាក់ទាញ និងក្រវាញ រួមទាំងការកែច្នៃស្រាចេកជាដើម។ សហគមន៍អេកូទេសចរណ៍តាតៃលើជាអ្នកគ្រប់គ្រងលើតំបន់ទេសចរណ៍ទាំងនេះដែលមានភូមិសាស្ត្រគ្រប ដណ្តប់លើភូមិកណ្តាល ភូមិស្ពានភ្លារ និងភូមិត្រពាំងខ្នារ ឃុំតាទៃលើ ស្រុកថ្មបាំង ខេត្តកោះកុង។ សូមរំលឹកបន្ថែមថាខេត្តកោះកុងគឺជាផ្នែកមួយនៃឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលដែលមានផ្ទៃដីទំហំប្រមាណជាង បួនសែនហិកតា (៤០១.៣១៣) ហិកតា ហើយគ្រប់ដណ្តប់ខេត្តចំនួនបីរបស់កម្ពុជាគឺកោះកុង ពោធិ៍សាត់ និងកំពង់ស្ពឺ។ ឧទ្យានជាតិនេះត្រូវបានទទួលស្គាល់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល កម្ពុជាកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៦ តាមសំណើរបស់ក្រសួងបរិស្ថាន។ ការបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលនេះមានគោលបំណង៥សំខាន់ៗ ទី១ ដើម្បីការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ ដែលបានកំណត់សម្រាប់ជាផលប្រយោជន៍របស់មនុស្សគ្រប់ជំនាន់ ទី២ កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងតួនាទីមុខងារនៃតំបន់ទី៣ ការផ្តល់ជាមូលដ្ឋានសម្រាប់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះពុំបង្កការគំរាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋានទី៤ ការផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងទី៥ ការលើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់៕

# តំបន់ដែនជម្រកសត្វព្រៃមានតួនាទីយ៉ាងដូចម្ដេច ហើយដែនជម្រក នៅកម្ពុជាមានចំនួនប៉ុន្មានដែរ?



តំបន់ដែនជម្រកសត្វព្រៃសំដៅដល់តំបន់ក្នុងដែនដីគោក ឬដែនទឹក ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្ម សម្រាប់បំពេញគោលបំណងគ្រប់គ្រងដើម្បីធានាឱ្យមានការថែទាំទីជម្រកនិង/ឬដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វឬរុក្ខជាតិ។ ដែនជម្រកសត្វព្រៃនៅកម្ពុជាមានចំនួន១០តំបន់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងមានទីតាំងចំនួន៨តំបន់ទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦។ ដែនជម្រកសត្វព្រៃទាំង១៨តំបន់នេះ គ្របដណ្ដប់នៅលើផ្ទៃដីសរុបចំនួណ៣.៦៨៤.៣២៨ ហិកតា ដែលស្មើ២០,៣ភាគរយ នៃផ្ទៃដីប្រទេសស្ថិតក្នុងខេត្តសៀមរាប ព្រះវិហារ កោះកុង ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង កំពង់ធំ រតនគិរី និងខេត្តមណ្ឌលគិរី។ តំបន់ដែនជម្រកសត្វព្រៃទាំងនោះរួមមាន

1. ភ្នំឱរ៉ាល់ ស្ថិតនៅទីតាំងខេត្តកំពង់ស្ពឺ ពោធិ៍សាត់ និងកំពង់ឆ្នាំង ដែលមានផ្ទៃក្រឡា ២៥៣.៧៥០ ហិកតចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
2. ពាមក្រសោប ស្ថិតនៅទីតាំងខេត្តកោះកុង ដែលមានផ្ទៃក្រឡា ២៣.៧៥០ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
3. ភ្នំសំកុស ស្ថិតនៅទីតាំងភូមសាស្ត្រខេត្តពោធិ៍សាត់ បាត់ដំបង និងកោះកុង ដែលមានផ្ទៃក្រឡា៣៣៣.៧៥០ហិកតាចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
4. រនាមដូនសំ ស្ថិតនៅទីតាំងខេត្តបាត់ដំបង ដែលមានផ្ទៃក្រឡា១៧៨.៧៥០ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
5. គូលែន-ព្រហ្មទេព ស្ថិតនៅក្នុងទីតាំងខេត្តសៀមរាប ព្រះវិហារ និងកំពង់ធំ ដែលមានផ្ទៃក្រឡា៤០២.៥០០ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
6. បឹងពែរ ស្ថិតនៅទីតាំងខេត្តសៀមរាប ព្រះវិហារ និងកំពង់ធំ ដែលមានផ្ទៃក្រឡា២៤២.៥០០ ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
7. លំផាត់ ស្ថិតនៅទីតាំងខេត្តរតនៈគិរី និងមណ្ឌលគិរី ដែលមានផ្ទៃក្រឡា២៥០.០០០ហិកតា ចេញដោយអនុក្រឹត្យថ្ងៃទី០៥ មករា ២០១៧

8. ភ្នំព្រេច ស្ថិតនៅទីតាំងខេត្តមណ្ឌលគិរី ដែលមានផ្ទៃក្រឡា២២២.៥០០ហិកតា ចេញដោយអនុក្រឹត្យ០៥ មករា ២០១៧
9. ភ្នំណាមលៀរ ស្ថិតនៅទីតាំងខេត្តមណ្ឌលគិរី ដែលមានផ្ទៃក្រឡា៤៧.៥០០ ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
10. ស្នួល ស្ថិតនៅទីតាំងខេត្តក្រចេះដែលមានផ្ទៃក្រឡា៧៥.០០០ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៩៣
11. ព្រៃឡង់ ស្ថិតនៅទីតាំងខេត្តព្រះវិហារ ស្ទឹងត្រែង កំពង់ធំ និង ក្រចេះ ដែលមានផ្ទៃក្រឡា៤៣១.៦៨៣ ហិកតា ចេញដោយអនុក្រឹត្យ ០៩ ឧសភា ២០១៦
12. ព្រះរការ ស្ថិតនៅទីតាំងខេត្តព្រះវិហារ ដែលមានផ្ទៃក្រឡា៩០.៣៦១ ហិកតា ចេញដោយអនុក្រឹត្យ ០៩ ឧសភា ២០១៦
13. សៀមប៉ាងខាងលិច ស្ថិតនៅទីតាំងខេត្តស្ទឹងត្រែងដែលមានផ្ទៃក្រឡា៦៥.៣៨៩ ហិកតា ចេញដោយអនុក្រឹត្យ០៩ឧសភា ២០១៦
14. ឆែប ស្ថិតនៅទីតាំងខេត្តព្រះវិហារ និងស្ទឹងត្រែង ដែលមានផ្ទៃក្រឡា ១៩០. ០២៧ ហិកតា ចេញដោយអនុក្រឹត្យ០៩ ឧសភា ២០១៦
15. តាតៃ ស្ថិតនៅទីតាំងខេត្តកោះកុង ដែលមានផ្ទៃក្រឡា១៤៤.២៧៥ ហិកតា ចេញដោយអនុក្រឹត្យ០៩ ឧសភា ២០១៦
16. កែវសីមា ស្ថិតនៅទីតាំងខេត្តមណ្ឌលគិរី និងក្រចេះ ដែលមានផ្ទៃក្រឡា ២៩២. ៦៩០ ហិកតា ចេញដោយអនុក្រឹត្យ០៩ ឧសភា ២០១៦
17. ស្រែពក ស្ថិតនៅទីតាំងខេត្តមណ្ឌលគិរី ដែលមានផ្ទៃក្រឡា៣៧២. ៩៧១ ហិកតា ចេញដោយអនុក្រឹត្យ០៩ ឧសភា ២០១៦
18. សៀមប៉ាង ស្ថិតនៅទីតាំងខេត្តស្ទឹងត្រែង ដែលមានផ្ទៃក្រឡា ៦៦. ៩៣២ ហិកតា ចេញដោយអនុក្រឹត្យថ្ងៃទី០៩ ឧសភា ២០១៦
19. ភ្នំត្នោត-ភ្នំពក ស្ថិតនៅទីតាំងខេត្តព្រះវិហារ និងសៀមរាប ដែលមានផ្ទៃក្រឡា៤២.០៩៧ហិកតាចេញដោយអនុក្រឹត្យថ្ងៃទី៣១ ខែសីហា ឆ្នាំ២០៧៕

# យុវជនមួយក្រុមជ្រើសរើសតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង សម្រាប់កំសាន្តចុងសប្តាហ៍

ចាប់ពីថ្ងៃទី២៨ដល់ថ្ងៃទី៣០ ខែកក្កដានេះ យុវជនកម្ពុជាមួយក្រុមដែលមានគ្នាប្រមាណ៤០នាក់ នឹងបោះតង់រយៈពេលបីថ្ងៃនៅតំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែងដែលស្ថិតក្នុងភូមិសាស្រ្ត ខេត្តព្រះវិហារ។




**លោក សា ឌីណា** ស្ថាបនិកក្រុមដំណើរកំសាន្ត Cambodia Amazing Trip Planner ដែលជាអ្នករៀបចំការបោះតង់នេះ បានបញ្ជាក់ថា ភ្នំត្បែងគឺជាតំបន់ធម្មជាតិដ៏ស្រស់ស្អាតដែលមានទឹកធ្លាក់ ព្រៃធម្មជាតិធំល្វឹងល្វើយ និងសត្វព្រៃ រួមទាំង ជាតំបន់ប្រវត្តិសាស្រ្តដែលព្រះរាជាខ្មែរកាលពីសម័យបូរាណបានធ្វើពិធីផ្សេងៗ។ លោកជឿជាក់ថា ដំណើរកំសាន្តផ្លូវការទី១របស់លោកទៅកាន់ភ្នំត្បែងនឹងទទួលបានជោគជ័យព្រោះថាអ្នកធ្វើដំណើរទាំងអស់នឹងភ្ញាក់ផ្អើលជាមួយនឹងសម្រស់ធម្មជាតិ តាំងពីជើងភ្នំរហូតដល់កន្លែងកំសាន្តនានា ហើយលោកជឿជាក់ថា អ្នកបោះតង់ទាំងអស់នឹងនិយាយពាក្យមួយថាអស្ចារ្យ។





## ប្រាសាទសំបូរព្រៃគុកជាឃ្លាំងសម្បត្តិធម្មជាតិ ដែលបម្រើដល់ភ្ញៀវទេសចរណ៍ និងសហគមន៍





តំបន់ប្រាសាទសំបូរព្រៃគុកដែលទើបតែដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក កំពុងទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិគួរឱ្យកត់សំគាល់។ កាលពីថ្ងៃទី២១ ខែកក្កដា ភ្ញៀវទេសចរណ៍មួយក្រុមមានគ្នាប្រមាណ៥នាក់ មកពីប្រទេសបារាំង បានធ្វើដំណើរមកទស្សនាប្រសាទសំបូរព្រៃគុកក្នុងថ្ងៃវិស្សមកាលរបស់ពួកគេដោយមានមគ្គុទេសខ្មែរនិយាយភាសាបារាំងម្នាក់ចាំជួយពន្យល់ និងបកប្រែ។ ពួកគេបានដើរមើលសព្វគ្រប់ប្រសាទទាំងឡាយក្នុងតំបន់បេតិកភណ្ឌមួយនេះដែលមានបរិស្ថានខ្យល់ធម្មជាតិត្រជាក់ត្រឈឹងត្រឈៃ។ ដោយឡែក ភ្ញៀវទេចរណ៍ជាតិវិញ ក៏កំពុងសម្រុកមកទស្សនាសម្បត្តិបេតិកភណ្ឌដែលជាកេរ្តិ៍ដំណែលរបស់ដូនតាមិនចាញ់ភ្ញៀវទេសចរណ៍អន្តរជាតិឡើយ។ ក្រៅពីប្រាង្គប្រាសាទនានា តំបន់បេតិកភណ្ឌមួយនេះ សម្រស់ធម្មជាតិក៏ជាចំណុចទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកទស្សនាតំបន់វប្បធម៌ធម្មជាតិមួយនេះផងដែរ។ ដោយសារតំបន់នេះ មានសក្តានុពលផ្នែកទេសចរណ៍វប្បធម៌ធម្មជាតិ ការរក្សាធនធានធម្មជាតិក្នុងតំបន់ឱ្យនៅស្រស់បំព្រង និងប្រាង្គប្រាសាទបូរាណដែលសម្បត្តិវប្បធម៌ គឺជាកិច្ចការងារចាំបាច់បំផុតដែលក្រសួងបរិស្ថានត្រូវតែធ្វើដើម្បីបម្រើដល់ការស្រូបទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិផង និងការអភិវឌ្ឍប្រកបដោយចីរភាព។ យន្តការនឹងផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចជូនប្រជាពលរដ្ឋសហគមន៍ក្នុងតំបន់ ដោយពិតប្រាកដតាមរយៈការចំណាយរបស់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិដែលនឹងនាំដល់ការថែរក្សាបានទាំងសម្បត្តិវប្បធម៌របស់ដូនតា និងរក្សាបាននូវសម្បត្តិធនធានធម្មជាតិក្នុងតំបន់បេតិកភណ្ឌ៕

## វត្តសំពៅប្រាំស្ថិតនៅឧទ្យានជាតិព្រះមុន្នីវង្ស ភ្នំបូកគោទាក់ទងទៅនឹងរឿង ព្រះថោងនាងនាគយ៉ាងណាខ្លះទៅ

វត្តសំពៅប្រាំ គឺស្ថិតនៅទីខ្ពង់រាប នៃភ្នំបូកគោដែលសព្វ ថ្ងៃនេះរាជការ បានតាំងជាទីក្រុងទេសចរណ៍មួយយ៉ាង សំខាន់ដែលសម្រាប់យកខ្យល់អាកាសស្អាតស្អំនៅឯមាត់សមុទ្រ។ ភ្នំនេះឋិតនៅក្នុងពួកភ្នំកំចាយពីដើមនៅក្នុងឃុំ កោះតូច ស្រុកកំពត ខេត្តកំពតប៉ុន្តែសព្វថ្ងៃគេកាត់ចេញ ដោយឡែកជាបុរីមួយ ដោយមានការគ្រប់គ្រងពិសេសដាច់ចេញពី ខេត្តកំពត។ សព្វថ្ងៃទីក្រុងថ្មីនេះ បានរៀបចំជាថ្មី ឱ្យទាន់សម័យ ឯផ្លូវថ្នល់ ដែលលូនក្រវេចក្រវៀនតាមចង្កេះភ្នំកាត់ជាជ្រោះឡើងទៅខ្ពង់បុព្វតា នេះក៏បានក្រាលថ្ម ចាក់ជ័រយ៉ាងស្អាតបាត រថយន្តតូចគ្រប់ធុនបើកបរ គ្មានលំបាកទេលើកលែងតែរថយន្តតែរថយន្តធំវែងៗបើកបរពុំបានត្បិតបត់បែនពុំកើត ព្រោះផ្លូវនេះភ្ញិកភ្ញក់ពេក។





ផ្លូវឡើង នេះមានចម្ងាយចាប់តាំងពីត្រង់បែកចេញពីផ្លូវជាតិលេខ៣(ផ្លូវកំពត- វាលរិញ) ទៅមាន ៣២គ.ម ប៉ុន្តែដោយសារផ្លូវបត់បែនហើយត្រូវឡើងជាជរាបផងរថយន្តបើកពុំសូវ លឿន ប៉ុន្មានទេ។ ពីដើមខ្ពង់រាបបូកគោជាកន្លែងយកខ្យល់អាកាសសម្រាប់ជនជាតិអឺរ៉ុបដែល ជាអាណាព្យាបាលស្រុកយើងគឺ លោក ហ្វ្រង់ស្វា-បូដ្វាំង ជារេស៊ីដង់សុប៉េរយើ នៅឯប្រទេសកម្ពុជាបានចាត់កសាងហើយសម្ពោធផ្លូវការកាលពីឆ្នាំ១៩២៥។កាលពីសម័យ កសាងនោះដោយទ្រង់ថា បារាំងរៀបចំធ្វើទីសំណាក់អាស្រ័យយកជាតុត្រជាក់សម្រាប់ ពួកគេដូច្នេះ ព្រះមហាក្សត្រខ្មែរយើងក៏ព្រះអង្គទ្រង់ព្រះតំរិះដល់ព្រះពុទ្ធិសាសនាភ្លាម ដែរគឺព្រះអង្គទ្រង់ សាងអារាមមួយ ដោយមានកូនវិហារតូចមួយ នឹងចេតិយឡើងមួយដែរ។សំណង់វត្តនេះ តាំងលើដីខ្ពស់ ជាកំពូលភ្នំដ៏មានផែនថ្មធំៗ នៅពាសពេញចម្លែក ជាងគេគឺផែនថ្មជាបន្ទះៗ មានទំហំបណ្តោយប្រមាណជាជាង១០ម៉ែត្រ និងមានកំពស់ប្រហែលជិត១០ម៉ែត្រដែរ។ទ្រង់ទ្រាយផែនថ្មនេះមានភាពសំប៉ែតខ្ពស់ ទ្រទុងនៅតំរៀបគ្នាជាប្រាំសន្លឹក មានសណ្ឋានដូចក្តោងសំពៅត្រដាង។



ដោយឃើញរូបភាពនៃថ្មទាំង ប្រាំផែននេះមាន សណ្ឋានដូចសំពៅ៥ កំពុងបើកក្ដោង ហើយការកសាង ក៏ត្រូវធ្វើនៅ ជាប់ផែនថ្មនេះទៀត ទើបអ្នកផងហៅទីនេះតាមសន្មត់ថា " វត្តសំពៅប្រាំ " ។ កាលបើ បានឈ្មោះនេះហើយអ្នកផងក៏ប្រឌិតបានជារឿងព្រេងមួយឡើងដែលដកស្រង់ពី រឿង មានស្រាប់មកហើយគឺរឿងព្រះថោងនាងនាគនោះឯង ៖ ក្នុងកាលកន្លងយូរមកហើយ កាលនោះមានស្ដេចខ្មែរយើងមួយអង្គព្រះនាមព្រះថោង។

រឿងដើមនៃក្សត្រអង្គនេះគឺ ព្រះអង្គជាព្រះអង្គម្ចាស់មួយព្រះអង្គ មានការតូចព្រះទ័យនិងបិតាដែលតំរូវឱ្យព្រះអង្គ គោរពបូជាព្រះអនុជពៅ ម្ល៉ោះហើយទ្រង់យាងចាកចេញពីព្រះរាជវាំងជាមួយស្ម័គ្របក្ស ពួកចេញឆ្ងាយពីរាជវាំងទៅដល់ឆ្នេរខ្សាច់មួយមានដើមធ្លកមួយដើមដុះ នាកណ្ដាលវាល ខ្សាច់នោះ។ព្រះអង្គបញ្ឈប់ពលរេហ៍ នៅទីនោះសម្រាកព្រះកាយនៅក្រោមដើមធ្លក។ ពេលព្រលឹមស្វាងឡើងព្រះអង្គយាងមួយព្រះអង្គឯងលំហែរកាយតាម មាត់សមុទ្រកាន់ តែឆ្ងាយទៅៗ ស្រាប់តែឮសំលេង មនុស្សអ៊ូអរ ព្រះអង្គក៏យាងទៅជិត បានជួបនឹងនាង នាគដែលកំពុងនាំគិលៀងមកកំសាន្តឆ្នេរសមុទ្រនេះ។ ព្រះអង្គបានលួងលោមប្រតិព័ទ្ធ នាងនាគក៏យល់ព្រម តែសូមឱ្យព្រះអង្គ តោងកន្ទុយនាគ ដើម្បីជ្រែកទឹកទៅកាន់ឋាន នាគថ្វាយបង្គំព្រះកុជង្គនាគ ជាព្រះបិតា។ លុះព្រះអង្គ តាមព្រះនាង ទៅដល់ឋាននាគ អស់រយៈ៧ថ្ងៃ ក៏សូមលាព្រះបិតាក្មេក នាំមហេសីមកឋានមនុស្សវិញ។

កាលនោះព្រះ បាទកុជង្គនាគបានរៀបចំប្រដាប់ប្រដា ជាទ្រព្យមានតំលៃចំនួន៥សំពៅ ដើម្បីជង្ហែព្រះ រាជបុត្រមកគ្រប់គ្រងរាជ្យនៅ ឋានមនុស្សលោក។ សំពៅទាំង៥នោះ បើកក្ដោងសំដៅ មាត់សមុទ្រជាយដែនប្រទេស ហើយក៏ចូលចតតំរៀបគ្នា រើប្រដាប់ប្រដាចេញពីសំពៅ ហើយដឹកជញ្ជូនយក

ទៅរកទីណាមួយ មានទីទួលខ្ពស់ រៀបចំកសាងជា ទីក្រុងឡើង។ ឯសំពៅទាំងប្រាំនោះក៏បញ្ឈរទុក សម្រាប់ព្រះអង្គមានដំណើរទៅណាមកណា ទ្រង់គង់ ក្រសាលតាមព្រះចិន្តា។ ពលរេហ៍ទាំង៥០០ នាក់ក៏ដង្ហែព្រះថោង និងនាងនាគទៅចាប់ ស្ថាបនាទីក្រុងរាជនិវេសន៍ ទាំងអស់គ្នាទៅ នៅសល់តែ សំបកសំពៅ លុះអស់កាលជា យូរលង់ក្រោយមក ឆ្នេរសមុទ្រចេះតែស្រុតស្រកឆ្ងាយទៅៗ ដីក៏កាន់តែ ដុះខ្ពស់ឡើងៗ សំពៅទាំងប្រាំនោះក៏កឿង នៅជាប់នឹងប្រាំង ហើយយូរៗទៅក៏រឹងទៅជាថ្មលិចបាត់តួ សំពៅទៅក្នុងដីនៅសល់តែក្តោងទាំង៥ដែលគេឃើញសព្វថ្ងៃនេះ។ នេះហើយជារឿង ព្រេងដែលអ្នក ស្រុកប្រឌិតភ្ជាប់នឹងស្ថានភាពវត្តនៅលើភ្នំបូកគោ។



ប៉ុន្តែបើតាមការស្រាវ ជ្រាវវិញវត្តនេះពុំមែនជា វត្តបុរាណណាស់ ណាទេ ក៏ជាវត្តថ្មីមួយដែល ព្រះករុណាព្រះ បាទព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅប្រទេសកម្ពុជា ទ្រង់កសាងឡើងកាលពី គ.ស ១៩២៤ គឺនៅគ្រាដែលរាជការ អាណាព្យាបាលបារាំង គេស្ថាបនាទីតំបន់បូកគោធ្វើជាទីលំហែរ សម្រាប់យកខ្យល់ត្រជាក់តាមធាតុអាកាសស្រុកអ៊ឺរ៉ុប។

កាលនោះរាជការបារាំងគេបាន ថ្វាយចំពោះព្រះករុណាជាអង្គម្ចាស់ជីវិត នូវទីកន្លែងមួយ សម្រាប់ព្រះអង្គស្ថាបនាជាព្រះ ដំណាក់មួយនៅបូកគោ នោះ ដូច្នោះហើយព្រះអង្គក៏ផ្តួចផ្តើមព្រះទ័យ កសាងជាវត្តមួយ នេះឡើងដោយជ្រើសរើសយកទីទួលដែលជាប់នឹងផែនថ្ម៥សន្លឹកធំៗនោះ សង់ជា ព្រះ វិហារមួយតូចតែស្អាតស្អំ និងចេតីយមួយទៀតនៅពីមុខព្រះវិហារនេះ ហើយសន្មត់យក នាភាកិធេយ្យថា "វត្តសំពៅប្រាំ"គឺយកតាមលំនាំទីកន្លែងលើទួលនោះដែលមានសន្លឹក ផែនថ្មធំៗដូចជា ក្តោង សំពៅប្រាំផ្ទាំងឋិតនៅត្រង់នោះស្រាប់។ សព្វថ្ងៃបូកគោជាទីមនោរម្យមួយសម្រាប់ទេសចរណ៍ ធ្វើ ដំណើរទៅលំហែរសម្រាកកាយនៅគ្រប់ពេលឈប់ សម្រាកម្ល៉ោះហើយវត្តសំពៅប្រាំ ក៏ទៅជារម្យណីយដ្ឋានមួយដែលគេស្គាល់ច្រើនដែរ។*អត្ថបទរូបភាពដកស្រង់ចេញពីខ្មែរអប្សរា*

# ការអភិវឌ្ឍដោយចីរភាព

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃសក្តានុពលអភិវឌ្ឍន៍បៃតងក្នុង កម្មវិធីតម្រង់ទិសគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍បៃតង



នាព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ ឯកឧត្តម សូ ខនឫទ្ធីគុណ អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន តំណាងឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) បានអញ្ជើញចូលរួមជាអធិបតីបើក សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការវាយតម្លៃសក្តានុពលអភិវឌ្ឍន៍បៃតង ក្នុងកម្មវិធីតម្រង់ទិសគោលនយោបាយសម្រាប់ការអភិវឌ្ឍបៃតង ដែលបានសហការរៀបចំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពតាមរយៈនាយកដ្ឋានសេដ្ឋកិច្ចបៃតង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI)។ សិក្ខាសាលានេះមានគោលបំណង៖ (១). បង្ហាញនូវលទ្ធផលនៃការវិភាគទិន្នន័យ និងរៀបចំការប្រឹក្សាយោបល់ថ្នាក់ជាតិដើម្បីកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍន៍បៃតងដែលមានសក្តានុពលខ្ពស់ក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និង (២). ប្រមូលយកមតិកែលំអពីអ្នកចូលរួម និងកសាងការឯកភាពជាឯកច្ឆន្ទលើចំណុចអាទិភាព និងវិស័យសេដ្ឋកិច្ចដែលសំខាន់សម្រាប់ការអភិវឌ្ឍន៍បៃតង។ សិក្ខាសាលានៅថ្ងៃនេះបានប្រមូលផ្តុំអ្នកពាក់ព័ន្ធសំខាន់ៗមកពីក្រសួង ស្ថាប័ន ដៃគូឯកជន និងដៃគូអភិវឌ្ឍន៍ សរុបចំនួន៩០ រូប ដែលជានានូវការតំណាងដ៏ទូលំទូលាយតាមវិស័យពាក់ព័ន្ធ។




កម្មវិធីតម្រង់ទិសគោលនយោបាយសម្រាប់ការអភិវឌ្ឍបៃតងនៅកម្ពុជា ផ្តោតសំខាន់លើការពង្រឹងដំណើរការធ្វើគោលនយោបាយជាតិ និងផែនការវិនិយោគ និងតម្រង់ទិសអាទិភាពគោលនយោបាយដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលលើគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) ការចូលរួមចំណែករបស់កម្ពុជានៅក្នុងអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ព្រមទាំងគោលនយោបាយជាតិពាក់ព័ន្ធនឹងអាកាសធាតុ និងការអភិវឌ្ឍបៃតងរបស់កម្ពុជា៕

# ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានចូលរួមកិច្ចប្រជុំលើកទី១៤ ថ្នាក់រដ្ឋមន្ត្រីបរិស្ថានអាស៊ាន និងសន្និសីទភាគីកិច្ចព្រមព្រៀង ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន



នៅទីក្រុង BANDAR SERI BEGAWAN ប្រទេសប្រ៊ុយណេ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ គណៈប្រតិភូនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានចូលរួមកិច្ចប្រជុំលើកទី១៤ ថ្នាក់រដ្ឋមន្ត្រីបរិស្ថានអាស៊ាន និងសន្និសីទភាគីកិច្ចព្រមព្រៀង ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន និងកិច្ចប្រជុំពាក់ព័ន្ធ ដោយបានពិភាក្សាលើប្រធានបទចំនួន៨ ដែលស្ថិតនៅក្រោមក្របខ័ណ្ឌបរិស្ថាន៖ (១) វិស្ថនភាព ស្តីពីការបំពុលផ្សែងអ័ព្ទឆ្លងដែន (២)និរន្តរភាពបរិស្ថានទីក្រុង (៣)ការអភិរក្សជីវៈចម្រុះ (៤)ការប្រែប្រួលអាកាសធាតុ (៥)បរិស្ថានតំបន់ឆ្នេរសមុទ្រ (៦)ការងារអប់រំបរិស្ថាន (៧)ការគ្រប់គ្រងធនធានទឹក (៨)ការគ្រប់គ្រងសារធាតុគីមី និងសំណល់គ្រោះថ្នាក់។ ជាមួយគ្នានេះដែររដ្ឋមន្ត្រីបរិស្ថានអាស៊ាននឹងជួបពិភាក្សាជាមួយបណ្តាប្រទេសជាដៃគូសន្ទនាក្នុងក្របខ័ណ្ឌអាស៊ានបូកបី ដែលរួមមាន ចិន ជប៉ុន និងកូរ៉េ លើកិច្ចសហប្រតិបត្តិការវិស័យបរិស្ថាន។



ជាលទ្ធផលនៃកិច្ចប្រជុំនេះ រដ្ឋមន្ត្រីបរិស្ថានអាស៊ាន បានពិភាក្សា និងអនុម័តលើ:

១.សេចក្តីថ្លែងការរួមអាស៊ានឆ្នាំ២០១៧ស្តីពីការប្រែប្រួលអាកាសធាតុ
២.ការផ្តល់ពានរង្វាន់និរន្តរភាពបរិស្ថានទីក្រុងអាស៊ាន
៣.ផែនការការងារបរិស្ថាននិងការប្រែប្រួលអាកាសធាតុអាស៊ាន-អង្គការសហប្រជាជាតិ

៤.តួនាទីនិងភារកិច្ចរបស់ឧត្តមមន្ត្រីបរិស្ថានអាស៊ាននិងក្រុមការងារ

៥.ផែនការសកម្មភាពស្តីពីកិច្ចសហប្រតិបត្តិការវិស័យបរិស្ថានអាស៊ាន-ចិន





៦.របាយការណ៍ស្តីពីស្ថានភាពបរិស្ថានអាស៊ានលើកទី៥

៧. ការបញ្ចូលឧទ្យានចំនួនពីរដែលស្នើដោយប្រទេសឥណ្ឌូណេស៊ីទៅក្នុងឧទ្យានបេតិកភ័ណ្ឌអាស៊ាន។

ក្រោយបញ្ចប់កិច្ចប្រជុំ រដ្ឋមន្ត្រីបរិស្ថានអាស៊ានបានចូលរួមពិធីផ្តល់ពានរង្វាន់និរន្តរភាពបរិស្ថានទីក្រុងអាស៊ាន និងវិញ្ញាបនប័ត្រទទួលស្គាល់ទឹកស្អាត ដីស្អាត និងខ្យល់ស្អាត ដែលបានឆ្លងកាត់ការវាយតម្លៃ និងជ្រើសរើសដោយគណៈកម្មការដែលមានសមាសភាពពីប្រទេសជាសមាជិកអាស៊ានទាំងអស់។ ជាមួយគ្នានោះ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសជាជ័យលាភីសម្រាប់ពានរង្វាន់និរន្តរភាពបរិស្ថានទីក្រុងអាស៊ាន ខេត្តកែបនិងខេត្តពោធិសាត់ត្រូវបានផ្តល់វិញ្ញាបនប័ត្រទទួលស្គាល់ទឹកស្អាត ដែលប្រព្រឹត្តទៅនៅល្ងាចថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ នៅប្រទេសប្រ៊ុយណេ ដារុស្សាឡឹម ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាននៅទីនោះ។ ខេត្តពោធិ៍សាត់ ទទួលពានរង្វាន់អាស៊ាន ផ្នែកនិរន្តរភាពទឹកស្អាត។ ដោយឡែកខេត្តកែប ទទួលពានរង្វាន់ទីក្រុងនិរន្តរភាពបរិស្ថានអាស៊ាន។ នេះជាមោទនភាពនៃប្រជាជន និង រាជរដ្ឋាភិបាលកម្ពុជា ដែលខេត្តរបស់កម្ពុជា បានទទួលពានរង្វាន់អាស៊ានទាក់ទងនឹងវិស័យបរិស្ថាន ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ។





សូមបញ្ជាក់ថា ប្រតិភូជាន់ខ្ពស់នៃក្រសួងបរិស្ថាន រួមនឹងប្រតិភូខេត្តពោធិសាត់ និង ខេត្តកែបនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ឯកឧត្តម សាយ សំអាល់រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានចេញដំណើរទៅ

ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថានអាស៊ាន និងទទួលពានរង្វាន់អាស៊ានផ្នែកនិរន្តរភាពបរិស្ថាន និងផ្នែកនិរន្តរភាពទឹក នៅប្រទេសប្រ៊ុយណេ កាលពីយប់ថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០១៧កន្លងមកនេះ៕





## វេទិកាថ្នាក់ជាតិលើកទី២ ស្ដីពី «ការការពារ និងអភិរក្សធនធានធម្មជាតិ» នៅវិមានសន្តិភាព នៅព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧




ក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងវេទិកាថ្នាក់ជាតិលើកទ២ ស្ដីពីការការពារ និងអភិរក្សធនជានធម្មជាតិ ប្រព្រឹត្តទៅនៅវិមានសន្តិភាព រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។




**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានអោយដឹងថា ដើម្បីពង្រឹងប្រសិទ្ធភាពការងារក្នុងសមត្ថកិច្ចរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានមន្ទីរបរិស្ថានជាសេនាធិការ។ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ដែរថា ក្រសួងបរិស្ថានបានខិតខំជំរុញការអនុវត្តសារាចរណែនាំ លេខ០៥ ស.រ. ណ.ន. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីវិធានការចាំបាច់នានា ក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ ដោយសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ដើម្បីពង្រឹងការគ្រប់គ្រង ថែរក្សា និងការពារធនធានធម្មជាតិ ដោយបានចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ។



ក្នុងវេទិកាថ្នាក់ជាតិនាថ្ងៃនេះដែរ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន បានលើកឡើងថាបច្ចុប្បន្នក្រសួងបរិស្ថានបាននិងកំពុងខិតខំធ្វើការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ រួមមាន «តំបន់ស្នូលតំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍» បោះបង្គោលកំណត់ព្រំតំបន់ការពារធម្មជាតិ រៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ទប់ស្កាត់បទល្មើសធនធានធម្មជាតិ ដោះស្រាយទំនាស់ដីធ្លី សហការចុះបញ្ជីដីធ្លី និងរៀបចំផែនទីសម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ដូចជា ដីលំនៅដ្ឋាន ដីសម្បទានជនជាតិដើមភាគតិច សម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច និងតំបន់ការពារធម្មជាតិ ក៏ដូចជាសម្រាប់ការកំណត់ និងបង្កើតតំបន់ការពារធម្មជាតិថ្មីៗបន្ថែមទៀត។ ជាមួយគ្នានេះដែរ តាមរយៈយុទ្ធនាការរបស់គណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ បទល្មើសព្រៃឈើទ្រង់ទ្រាយធំនៅទូទាំងប្រទេសត្រូវបានលុបបំបាត់ទាំងស្រុង។ ទោះជាយ៉ាងណាក៏ដោយ បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយតូចមួយចំនួន ដូចជា ការលួចកាប់ឈើ និងការកាប់រុករានទន្ទ្រានយកដីរដ្ឋនៅបន្តកើតមាន ហើយការរុករក និងធ្វើអាជីវកម្មរ៉ែ ក៏ដូចជា ការប្រើប្រាស់ដីនៅក្នុងតំបន់ការពារធម្មជាតិសម្រាប់ជាមូលដ្ឋានកងទ័ព នៅតែជាបញ្ហាប្រឈម ដែលទាមទារឱ្យក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ បន្តរួមគ្នាចាត់វិធានការគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

## សម្តេចតេជោនាយករដ្ឋមន្ត្រី៖ ក្រសួងបរិស្ថាន និងភាគីពាក់ព័ន្ធ សហការអភិរក្សធនធានធម្មជាតិ ធ្វើឲ្យសង្គមមានសុខដុមរមនា

នៅក្នុងវេទិកាថ្នាក់ជាតិលើកទី២ ស្តីពី ការការពារ និងអភិរក្សធនធានធម្មជាតិ ប្រព្រឹត្តទៅនៅវិមានសន្តិភាព រាជធានីភ្នំពេញ នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍លើកឡើង តាមរយៈការគិតគូរបស់ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័ន្ទ រួមជាមួយដៃគូ បានសម្រេចសមិទ្ធផលថ្មីៗ ស្តីពីគុណភាពបរិស្ថាន ដើម្បីសម្រេចឲ្យមានចីរភាពនៃធនធានធម្មជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឱកាសនេះ សម្តេចតេជោនាយករដ្ឋមន្ត្រីបានចាត់ទុកថាភាគីពាក់ព័ន្ធទាំងជាតិ អន្តរជាតិ និងក្រសួងបរិស្ថាន មានកិច្ចសហការល្អក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ ធ្វើអោយសង្គមមានសេចក្តីសុខុដុមរមនា។







ជាមួយគ្នានេះដែរ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ការការពារ និងអភិរក្សធនធានធម្មជាតិ និងគាំពារដល់ទេសចរណ៍ គឺកម្ពុជាកំណត់ថាជាទេសចរណ៍វប្បធម៌ ដែលចូលរួមចំណែកបង្កើនចំណូល និងមុខរបរប្រជាពលរដ្ឋនៅតាមមូលដ្ឋានឲ្យកាន់តែប្រសើរ។ ការរីកចំរើននេះ ស្របជាមួយកម្ពុជាមានសុខសន្តិភាព និងមានការអភិវឌ្ឍសេដ្ឋកិច្ចខ្ពស់ផងដែរ។ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន មានប្រសាសន៍ដែរថា ទន្ទឹមនឹងការរីកចម្រើននេះ ទីប្រជុំជន បានកំពុងមានមនុស្សកើនឡើង បញ្ហាសំរាម និងបញ្ហាមួយចំនួនទៀត ដែលតម្រូវឲ្យភាគីពាក់ព័ន្ធត្រូវរួមគ្នាដោះស្រាយ។ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានជម្រុញឲ្យអាជ្ញាធរ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ ចាត់វិធានការណ៍ឲ្យតឹងរឹងលើការកាប់ព្រៃឈើ៕









# កិច្ចប្រជុំលើកទី២នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ពិនិត្យវឌ្ឍនភាព ដែលក្រុមប្រឹក្សានេះសម្រេចបាន




នាព្រឹកថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានដឹកនាំកិច្ចប្រជុំលើកទី២របស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាទាំងអស់ ជាមន្ត្រីជាន់ខ្ពស់តំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត សរុបចំនួន៧៦រូប។ អង្គប្រជុំបានត្រួតពិនិត្យវឌ្ឍនភាពដែលក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពសម្រេចបានក្នុងការគាំទ្រកិច្ចអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ក្នុងនោះរួមមានការពិនិត្យ ផ្តល់យោបល់ និងអនុម័តលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន រួមមាន សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ (Environment and Natural Resources Code) សេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ (NESAP) និងសេចក្តីព្រាងយុទ្ធសាស្ត្រវេជបូកជាតិ។





ថ្លែងក្នុងពិធីបើក **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានបញ្ជាក់ថា ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាស្ថាប័នរៀបចំគោលនយោបាយជាតិ ដែលត្រូវបានបង្កើតឡើងដោយការរួមបញ្ចូលគ្នានៃស្ថាប័នអន្តរក្រសួងដែលធ្លាប់មានចំនួន៤

គឺ ៖ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គណៈកម្មាធិការជាតិជីវសុវត្ថិភាព និងគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ធានាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌របស់ប្រទេសជាតិ។ ឯកឧត្តមរដ្ឋមន្ត្រីបាន កត់សម្គាល់អំពីកិច្ចប្រឹងប្រែងនិងសមិទ្ធផលសំខាន់ៗដែលក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពសម្រេចបាននៅក្នុងឆ្នាំ២០១៧ ដូចជា សេដ្ឋកិច្ចបៃតង ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ និងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ ទាក់ទងនឹងវេជបូក នាពេលអនាគត នៅពេលខេត្តមានសមត្ថភាពគ្រប់គ្រាន់ ក្រសួងបរិស្ថានគ្រោងនឹងផ្ទេរថវិកាពីការលក់កាបូននៅខេត្តមណ្ឌលគិរីដល់ខេត្តហើយដៃគូពាក់ព័ន្ធអាចចរចានិងធ្វើដោយផ្ទាល់ជាមួយខេត្តតែម្តង។

អំពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(ក.ជ.អ.ច.)

ត្រូវបានបង្កើតឡើងនៅខែឧសភា ឆ្នាំ២០១៥ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅធានាបាននូវតុល្យភាពរវាង សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធ៌ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.ជ.អ.ច. មានអគ្គលេខាធិការដ្ឋានមួយសម្រាប់ជាសេនាធិការ និងមានទីស្នាក់ការងារនៅក្រសួងបរិស្ថាន។អំពី សមាសភាព ក.ជ.អ.ច.សមាសភាព ក.ជ.អ.ច. មានដូច ខាងក្រោម :

-សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស

-រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន

-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធានទី១ និង

រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាអនុប្រធានទី២

- រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន ចំនួន២៧ ជាសមាជិក

- អគ្គលេខាធិការ និងអនុប្រធានប្រតិបត្តិនៃស្ថាប័នរដ្ឋ ចំនួន៦ ជាសមាជិក

- អភិបាលរាជធានី ខេត្ត ចំនួន២៥ ជាសមាជិក

- អគ្គលេខាធិការ ក.ជ.អ.ច. ជាសមាជិកអចិន្ត្រៃយ៍

អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច

អគ្គលេខាធិការដ្ឋាន មានតួនាទីនិងភារកិច្ចចាំបាច់ក្នុងការសម្របសម្រួលនិងអនុវត្តការងារប្រចាំថ្ងៃ សម្រាប់គាំទ្រដល់ការរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព។ អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានជំនាញ ចំនួន៥ :

- នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

- នាយកដ្ឋានប្រែប្រួលអាកាសធាតុ

- នាយកដ្ឋានសេដ្ឋកិច្ចបៃតង

- នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- នាយកដ្ឋានជីវៈចម្រុះ

អំពីកិច្ចប្រជុំលើកទី១

កិច្ចប្រជុំលើកទី១ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានរៀបចំឡើងនៅទីស្តីការក្រសួងបរិស្ថាន នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ក្រោមអធិបតីភាពឯកឧត្តម សាយ សំអាល់ រដ្ឋមន្រ្តីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំលើកទី១ រួមមាន ៖

- ការអនុម័តទៅលើរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា ដោយនឹងត្រូវមានអង្គប្រឹក្សាយោបល់ថ្នាក់ជាតិចំនួនពីរ គឺក្រុមឧត្តមមន្ត្រី និងគណៈកម្មាធិការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ, និងការបង្កើតក្រុមការងារថ្នាក់រាជធានីខេត្តដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត សំដៅធានាបាននូវការចូលរួមយ៉ាងសកម្មពីមន្ទីរពាក់ព័ន្ធជុំវិញខេត្តក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បន្ថែមពីលើរចនាសម្ព័ន្ធនេះ ក្រុមការងារបច្ចេកទេសចំនួន៧ នឹងត្រូវបានបង្កើត ដើម្បីសម្របសម្រួល និងគាំទ្រដល់ការរៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ និងក្របខណ្ឌគតិយុត្តិ លើកកម្ពស់ការស្រាវជ្រាវ អប់រំ និងបណ្តុះបណ្តាល ផ្លាស់ប្តូរបច្ចេកវិទ្យានិងនវានុវត្តន៍ ព្រមទាំងផ្សព្វផ្សាយលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។ ក្រុមបច្ចេកទេសទាំងនេះ នឹងផ្តោតសំខាន់លើ ៖ ការប្រែប្រួលអាកាសធាតុ, ទីក្រុងនិរន្តរភាព, ថាមពលនិរន្តរភាព, ការប្រើប្រាស់ និងផលិតកម្មនិរន្តរភាព, ជីវៈចម្រុះ ការប្រើប្រាស់និងការបែងចែកផលពីធនធានពន្ធុ និងជីវសុវត្ថិភាព, វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, និងថាមពលនុយក្លេអ៊ែរ
- ការពិនិត្យនិងពិភាក្សាទៅលើនិមិត្តសញ្ញា និងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ការកំណត់សកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០១៦-២០១៨ មានជាអាទិ៍ ការងារទីក្រុងនិរន្តរភាព ថាមពលនិរន្តរភាព ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ កិច្ចអភិរក្សជីវៈចម្រុះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបៃតង ការរៀបចំបញ្ចប់នូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថាន និងក្រមបរិស្ថាន៕



# មន្ត្រីវ័យក្មេងបរិស្ថានពីររូប ចូលវគ្គបណ្តុះបណ្តាលអន្តរជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ



ក្រសួងបរិស្ថាន បានចាត់បញ្ជូនមន្ត្រីជំនាញវ័យក្មេងចំនួន០២រូបទៅកាន់ប្រទេសចិន ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍន៍ដោយបំភាយកាបោនតិច។ ការបណ្តុះបណ្តាលនេះមានរយៈពេល២១ថ្ងៃ ពីថ្ងៃទី២៨ ខែកក្កដា រហូតដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧។

មន្ត្រីទាំងពីររូបនេះ រួមមាន លោក សាត ស៊ីតាក់ និងកញ្ញា សឿង លីលី មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ការបញ្ជូនមន្ត្រីវ័យក្មេងទៅបរទេសនេះ គឺពង្រឹងសមត្ថភាពអ្នកជំនាញការដែលបាន និងកំពុងធ្វើការទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងដើម្បីពង្រឹងសហប្រត្តិបត្តការអន្តរជាតិ លើកិច្ចការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងពិភពលោក។

សូមបញ្ជាក់ផងដែរថា វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ចំនួន២១ប្រទេស ជាពិសេសក្រុមបណ្តាប្រទេសសហប្រត្តិបត្តការត្បូង-ត្បូង (South-South Cooperation Nations)។ ក្នុងរយៈពេល ២១ថ្ងៃនេះ សិក្ខាកាមនឹងសិក្សាស្វែងយល់លើ៖ ១. ផែនការយុទ្ធសាស្រ្ត គោលនយោបាយ និងតួនាទីរបស់រដ្ឋាបាលចិនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ និងពិភពលោក ២. បទពិសោធន៍ជោគជ័យ និងករណីសិក្សាល្អៗ ក្នុងការអនុវត្តម៉ូដែលគម្រោងអភិវឌ្ឍន៍ដោយបញ្ចេញការបូនតិច ឬការវិនិយោគបៃតងក្នុងវិស័យមួយចំនួន ដូចជា វិស័យសំណង់ វិស័យថាមពល (ថាមពលកកើតឡើងវិញ និងជីវៈថាមពល) វិស័យទេសចរណ៍ និងការអភិវឌ្ឍបច្ចេកវិទ្យាបៃតង ៣. ករណីសិក្សាលើការរៀបចំផែនការក្រុងដេ៊ីម្បីឆ្លេ៊ីយបតនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ និងទី៤ បេតិកភ័ណ្ឌវប្បធម៌ដ៏ចំណាស់របស់ប្រទេសចិនយ៉ាងសម្បូរបែប ។

ក្រៅពីការពង្រឹងសមត្ថភាពមន្ត្រីវ័យក្មេងរបស់ក្រសួងបរិស្ថានដើម្បីបង្កើនប្រសិទ្ធការងារក្នុងស្ថាប័នរបស់ខ្លួន ជាពិសេសក្នុងកិច្ចការការឆ្លើយតបការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ បន្ថែមពីនេះ វគ្គបណ្តុះបណ្តាល ក៏ផ្តល់ឱកាសដល់មន្ត្រីវ័យក្មេងក្នុងការចាប់ផ្តើមបង្កើតទំនាក់នងជាមួយអ្នកជំនាញការដែលជាសិក្ខាកាមមកពីបណ្តាប្រទេសនានាក្នុងពិភពលោក ដើម្បីពង្រឹងសហប្រត្តិបត្តការរួមគ្នាឆ្ពោះសម្រេចឱ្យបានការអភិវឌ្ឍដោយចីរភាព៕



# ការគ្រប់គ្រងទិន្នន័យភូមិសាស្ត្រ ការអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន

# កិច្ចសហប្រតិបត្តិការការងារអប់រំ រវាងក្រសួងបរិស្ថាន
# និងក្រសួងអប់រំ យុវជន និងកីឡា

នៅល្ងាចថ្ងៃទី ២៤ ខែ កក្កដា ២០១៧ ក្រុមការងារ សម្របសម្រួលកិច្ចសហប្រតិបត្តិការ ការងារអប់រំ បណ្តុះបណ្តាល ជំនាញការសិក្សាស្រាវជ្រាវ រវាងក្រសួងបរិស្ថាន និង ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំប្រជុំលើកដំបូង ក្រោយពេលដែល ក្រុមការងារនេះចាប់បដិសន្ធិឡើង ក្រោមអធិបបតីភាព ឯកឧត្តម អ៊ឹម កុច រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងលោកជំទាវ ព្រុំ សុភី អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន។ កិច្ចប្រជុំលើកទី១នេះបានពិភាក្សាទៅ៖ ១) ការរៀបចំយុទ្ធសាស្ត្រសម្រាប់ក្រុមការងារ ២) បន្តកិច្ចសហការការងារ លើសកម្មភាពកាងារដែលបានអនុវត្តន៍កន្លងមក។ បន្ទាប់ពីភាគីក្រសួងទាំងពីរបានធ្វើរបាយការណ៍សមិទ្ធិផលការងារដែលក្រសួងទាំងពីរបានសហការអនុវត្តន៍ កន្លងមក អង្គប្រជុំបានបន្តពិភាក្សាលើភារកិច្ច និងតួនាទីរបស់ក្រុមការងារ និងកិច្ចសហការការងារដើម្បីប្រសិទ្ធភាពការងារបន្ត។ លទ្ធផលនៃកិច្ចប្រជុំរួមមាន៖១)បង្កើតការប្រាស្រ័យ ទាក់ទង និងប្រសិទ្ធិភាព ដឹកនាំសម្របសម្រួលរបស់ក្រុមការងារ ២) ការគិតគូរៀបចំនូវផែនការយុទ្ធសាស្ត្រសម្រាប់ក្រុមការងារ ៣) បន្តអនុវត្តន៍សាលមេត្រីបរិស្ថាន និង- សម្របសម្រួលបន្ថែម ជាមួយនឹងសកម្មភាព និងព្រឹត្តិការណ៍ផ្សេងៗ ៤) ឯកភាពចូលរួមអភិវឌ្ឍន៍កម្មវិធីសិក្សាដោយបញ្ចូលនូវបញ្ញាត្តិបរិស្ថាន ៥) ចូលរួមកំណត់ប្រធានបទ ដែលជាបញ្ហាអាទិភាពក្នុងវិស័យបរិស្ថាន សម្រាប់ការសិក្សាស្រាវជ្រាវ ដើម្បីផ្សារភ្ជាប់របកគំហើញ បែបវិទ្យាសាស្ត្រ ទៅនឹងការរៀបចំគោល នយោបាយគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ និងឆ្លើយតបទៅនឹងគោលដៅ យុទ្ធសាស្ត្រក្រសួងទាំងពីរ ។



# ការកសាងផែនទី និងផ្តល់សេវាកម្មព័ត៌មានភូមិសាស្ត្រ

នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ បានរៀបចំផែនទីតំបន់ការពារធម្មជាតិថ្មីចំនួន៨តំបន់ រួមមាន ដែនជម្រកសត្វព្រៃព្រៃឡង់ ដែនជម្រកសត្វព្រៃព្រះរកា ឧទ្យានជាតិជួរភ្នំក្រវាញភាគខាងត្បូង ឧទ្យានជាតិវីរ៉ៃសែសៀមប៉ាង ដែនជម្រកសត្វព្រៃសៀមប៉ាងខាងលិច តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ឧទ្យានជាតិសមុទ្រកោះរុង និងតំបន់ការពារបឹងព្រែកទប់ ដោយបានធ្វើការសហការជាមួយអង្គការដៃគូ សម្របសម្រួលដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ពិភាក្សាយោបល់ជាមួយនាយកដ្ឋានជំនាញ ព្រមទាំងប្រមូលទិន្នន័យមានស្រាប់ រួមផ្សំនឹងទិន្នន័យផែនទីគោលថ្មីៗដែលនាយកដ្ឋានបានកសាង និងប្រមូលដោយផ្ទាល់។ ទន្ទឹមនឹងនោះនាយកដ្ឋានបានទទួលនូវទិន្នន័យព្រៃការពារ និងព្រៃអភិរក្សចំនួន១៣តំបន់ដែលបានផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរៀបចំកសាងជាផែនទីតំបន់ការពារធម្មជាតិក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា មានតំបន់ការពារធម្មជាតិចំនួន ៤៥ ដែលមានផ្ទៃដីសរុប ៥,៩០៤,៨៨៣ ហិកតា ស្មើនឹង ៣២%នៃផ្ទៃដីប្រទេស។

| កូដ | ឈ្មោះតំបន់ការពារ | ផ្ទៃក្រឡា (ហ.ត) | កូដ | ឈ្មោះតំបន់ការពារ | ផ្ទៃក្រឡា (ហ.ត) |
|---|---|---|---|---|---|
| **ឧទ្យានជាតិ** | | | ២៤ | ព្រះរការ | ៩០,៣៦១ |
| ១ | ព្រះសុរាម្រិត-កុសមៈ (គិរីរម្យ) | ៣៥,២៣២ | ២៥ | សៀមប៉ាងខាងលិច | ៦៥,៣៨៩ |
| ២ | ព្រះមុនីវង្ស (បូកគោ) | ១៥៤,៤៥៨ | ២៦ | ឆែប | ១៩០,០២៧ |
| ៣ | កែប | ១,១៥២ | ២៧ | តាតៃ | ១៤៤,២៧៥ |
| ៤ | ព្រះសីហនុ (រាម) | ៣២,៤០១ | ២៨ | កែវសីមា | ២៩២,៦៩០ |
| ៥ | បុទុមសាគរ | ១៨៣,៤០៨ | ២៩ | ស្រែពក | ៣៧២,៩៧១ |
| ៦ | ព្រះជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន) | ៣៧,៣៧៣ | ៣០ | សៀមប៉ាង | ៦៦,៩៣២ |
| ៧ | វីរៈជ័យ | ៣៣៤,១៧៣ | **តំបន់ការពារទេសភាព** | | |
| ៨ | វីរ៉ៃសែ-សៀមប៉ាង | ៥៧,៤៦៩ | ៣១ | អង្គរ | ១០,៨០០ |
| ៩ | ក្រវាញកណ្តាល | ៤០១,៣១៣ | ៣២ | បន្ទាយឆ្មារ | ៨១,២០០ |
| ១០ | អូរយ៉ាដាវ | ១០១,៣៤៨ | ៣៣ | ព្រះវិហារ | ៥,០០០ |
| ១១ | ជួរភ្នំក្រវាញខាងត្បូង | ៤១០,៣៩២ | ៣៤ | អន្លង់ព្រីង | ២១៧ |
| ១២ | កោះរុង | ២,៥១៧ | ៣៥ | ទំនាបខាងជើងទន្លេសាប | ៣១,១៥៩ |
| **ដែនជម្រកសត្វព្រៃ** | | | ៣៦ | បឹងព្រែកល្ពៅ | ៨,៣០៥ |
| ១៣ | ភ្នំឱរ៉ាល់ | ២៥៥,០៣៦ | ៣៧ | អាងត្រពាំងថ្ម | ១២,៦៥០ |
| ១៤ | ពាមក្រសោប | ២៥,៨៩៧ | ៣៨ | បឹងព្រែកទប់ | ១៦ |
| ១៥ | ភ្នំសំកុស | ៣៣២,៥៦៦ | **តំបន់ប្រើប្រាស់ច្រើនយ៉ាង** | | |

| កូដ | ឈ្មោះតំបន់ការពារ | ផ្ទៃក្រឡា (ហ.ត) | កូដ | ឈ្មោះតំបន់ការពារ | ផ្ទៃក្រឡា (ហ.ត) |
|---|---|---|---|---|---|
| ១៦ | នោមជូនសំ | ៤០,០២១ | ៣៩ | ដងពែង | ២៧,៧០០ |
| ១៧ | គូលែន-ព្រហ្មទេព | ៤០២,៥០០ | ៤០ | សំឡូត | ៦០,០០០ |
| ១៨ | បឹងពែរ | ២៤៩,៦៩៤ | ៤១ | ទន្លេសាប | ៣១៦,២៥០ |
| ១៩ | លំផាត់ | ២៥០,០០០ | ៤២ | ពញាក្រែក | ១៩៩ |
| ២០ | ភ្នំព្រិច | ២២២,៥០០ | ៤៣ | ព្រែកទឹកសាបក្បាលឆាយ | ៥,៥២០ |
| ២១ | ណាមលៀរ | ៤៧,៥០០ | ៤៤ | តំបន់រ៉ាមសារស្ទឹងត្រែង | ១៤,៦០០ |
| ២២ | ស្នួល | ៧៥,៣៣៥ | ៤៥ | តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង | ២៤,៦៥៤ |
| ២៣ | ព្រៃឡង់ | ៤៣១,៦៨៣ | ៤៦ | តំបន់បេតិកភណ្ឌធម្មជាតិភ្នំយារាត | |
| ២៣ | | | | | |

## ផែនទីតំបន់ការពារធម្មជាតិ




ទន្ទឹមនឹងការកសាងផែនទីតំបន់ការពារធម្មជាតិទាំង២១នេះ នាយកដ្ឋានបានប្រមូល និងកសាងនូវទិន្នន័យផ្សេងៗ ដូចជា រូបភាពផ្កាយរណបដែលមានកម្រិតច្បាស់ (កម្រិតគំហើញ ១ម៉ែត្រ និង១០ម៉ែត្រ ដូចជា Google Images និង Sentinel 2 ) កម្រិតមធ្យម (កម្រិតគំហើញ ៣០ម៉ែត្រ ដូចជា Landsat 8) ផែនទីគម្របដីឆ្នាំ២០១៥ដែលបានចូលរួមសហការជាមួយគណៈកម្មការទន្លេមេគង្គជាតិកម្ពុជា និងផែនទីសម្បទានដីសេដ្ឋកិច្ចទាំងក្នុងនឹងក្រៅតំបន់ការពារធម្មជាតិ ដើម្បីប្រើប្រាស់ជាផែនទីគោល។

## ផែនទីគម្របដីឆ្នាំ២០១៥




## រូបភាពផ្កាយរណប (landsat 5, 7 and 8 : U.S. Geological Survey)




នាពេលបច្ចុប្បន្ននេះ នាយកដ្ឋាន រួមជាមួយអ្នកពាក់ព័ន្ធទាំងអស់ បាននិងកំពុងបន្តរៀបចំផែនទីរបៀងជីវៈចម្រុះ ដើម្បីកសាងបាននូវវិសាលភាពតំបន់ការពារធម្មជាតិ និងតំបន់ទេសភាពដែលរក្សាបាននូវសក្តានុពលធម្មជាតិ និងជីវៈចម្រុះ។ ទទឹមនេះ នាយកដ្ឋានក៏កំពុងកសាងផែនទីប្រព័ន្ធអេកូឡូស៊ីចម្រុះ ដោយសហការជាមួយអង្គការ UNDP ដែលបានធ្វើសិក្ខាសាលាពិគ្រោះយោបល់កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅនេះ ដោយមានការចូលរួមពីអង្គការដៃគូនានា និងក្រសួងពាក់ព័ន្ធ។ ផែនទីប្រព័ន្ធអេកូ

ឡូស៊ីចម្រុះនឹងត្រូវប្រមូលផ្តុំនូវទិន្នន័យពាក់ព័ន្ធជាច្រើន ដូចជា ទិន្នន័យស្តីពីធនធានធម្មជាតិ ទឹក ដី ជីវៈចម្រុះ ទីជម្រក និងប្រព័ន្ធអេកូឡូស៊ី រួមទាំងទិន្នន័យស្តីពីសកម្មភាពអភិវឌ្ឍន៍នានា ដើម្បីប្រើប្រាស់ និងបង្កើតនូវប្រព័ន្ធគាំទ្រសេចក្តីសម្រេចចិត្ត ជួយផ្តល់ព័ត៌មានតាមបែបវិទ្យាសាស្ត្រសម្រាប់ជានាដល់ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះប្រកបដោយចីរភាព សំដៅធានាឱ្យបាននូវសុវត្ថិភាពនៃប្រព័ន្ធអេកូឡូស៊ី និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ កិច្ចការនេះ នាយកដ្ឋានជាមួយអង្គការ UNDP ទទួលបាននូវសមិទ្ធិផលមួយជំហានហើយ ដោយប្រមូលបាននូវទិន្នន័យពាក់ព័ន្ធពីដៃគូអភិវឌ្ឍន៍នានា និងនាយកដ្ឋានកំពុងបន្តសកម្មរបស់ខ្លួនក្នុងប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធ។ ក្រៅពីនេះ នាយកដ្ឋានបានរៀបចំបង្កើតគេហទំព័រចែករំលែកទិន្នន័យបរិស្ថាន (Environmental Data Web Portal) ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ADB ព្រមទាំងសហការជាមួយអង្គការដៃគូផ្សេងៗក្នុងការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីក្នុងនាយកដ្ឋាន និងពង្រឹងសមត្ថភាពនាយកដ្ឋានផងដែរ។



# សិក្ខាសាលាស្តីពី បច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រក្នុងការគ្រប់គ្រង

នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ នៅសណ្ឋាគារឆ្នេរសុខា ខេត្តព្រះសីហនុ នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន សហការ និងសម្របសម្រួលពី កម្មវិធី SERVIR-Mekong មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយនៅអាស៊ី (ADPC) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP) បានបើកសិក្ខាសាលាស្តីពី «បច្ចេកវិទ្យាព័ត៌មានភូមិសាស្ត្រក្នុងការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ» ក្រោមអធិបតីភាព **ឯកឧត្តម សៅ សុភាព** នាយកខុទ្ទកាល័យ។



សិក្ខាសាលានេះរៀបចំឡើងដើម្បីកំណត់នូវសកម្មភាព បច្ចេកវិទ្យា និងឧបករណ៍សំខាន់ៗដែលអាចធ្វើទៅបានក្នុងការប្រមូល គ្រប់គ្រង និងចែករំលែកទិន្នន័យព័ត៌មានភូមិសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ កិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព។

**ឯកឧត្តម សៅ សុភាព** នាយកខុទ្ទកាល័យ បានថ្លែងអំណរគុណចំពោះអង្គការ USAID ប្រជាជនជប៉ុន អង្គការ UNDP, NASA, ADPC និង SERIVR-Mekong ដែលបានជួយឧបត្ថម្ភគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្ររៀបចំសិក្ខាសាលានេះ និងសម្តែងការស្វាគមន៍ចំពោះវត្តមានរបស់តំណាងអង្គភាពពាក់ព័ន្ធ តំណាងក្រុមហ៊ុន អង្គការ កម្មវិធី និងវិទ្យាស្ថានសិក្សាស្រាវជ្រាវ ដែលបានចំណាយពេលវេលាអញ្ជើញចូលរួមដើម្បីចែករំលែកបច្ចេកវិទ្យា បទពិសោធន៍ និងឧបករណ៍ប្រើប្រាស់ក្នុងការប្រមូល ផលិត ចងក្រង និងវិភាគទិន្នន័យព័ត៌មានភូមិសាស្ត្រ។ ឯកឧត្តមបានលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមដល់នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រដែលអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។ ជាមួយគ្នានេះ ឯកឧត្តម ក៏បានលើកទឹកចិត្តឱ្យគិតគូក្នុងការផ្តល់បច្ចេកវិទ្យា ជំនាញ និងឧបករណ៍ដែលអាចប្រើប្រាស់សម្រាប់អង្គភាពជំនាញក្នុងក្រសួងបរិស្ថានផងដែរ។ ឯកឧត្តមសង្ឃឹមថា អង្គភាពពាក់ព័ន្ធនៃក្រសួង និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមយ៉ាងសកម្មក្នុងការកំណត់បាននូវកិច្ចសហប្រតិបត្តិការល្អ ដើម្បី កសាងបាននូវប្រព័ន្ធចែករំលែកទិន្នន័យព័ត៌មានភូមិសាស្ត្រមួយរបស់ក្រសួងបរិស្ថាន។

# ការលើកកម្ពស់ការអប់រំនិងចំណេះដឹងបរិស្ថាន

នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន មានការរៀបចំ «វេទិកាយុវជនឆ្នើមថ្នាក់ជាតិជជែកពិភាក្សាអំពីបញ្ហាបរិស្ថាន ឆ្នាំ២០១៧» វគ្គប្រកួតជំបូង ក្រោមអធិបតីភាព **ឯកឧត្តម យុត ចាន់ដារ៉ា** អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន ដែលមានការចូលរួមពីនិស្សិត តាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនចំនួន១៤ នៅរាជធានីភ្នំពេញ និងខេត្ត និងមានអ្នកចូលរួមជាមន្ត្រីរាជការនិងថ្នាក់ដឹកនាំក្រសួងបរិស្ថាន សរុបប្រមាណ២០០នាក់។




«វេទិកាយុវជនឆ្នើមថ្នាក់ជាតិជជែកពិភាក្សាអំពីបញ្ហាបរិស្ថានឆ្នាំ២០១៧» រៀបចំឡើងដោយនាយកដ្ឋានអប់រំបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន គោលបំណងសំខាន់ ដើម្បីពង្រឹងសមត្ថភាពរបស់យុវជនក្នុងការសិក្សាស្រាវជ្រាវ រិះរកអំណះអំណាងតាមបែបវិទ្យាសាស្ត្រ សំដៅចូលរួមចំណែកកិច្ចគាំពារបរិស្ថាន និងអភិរក្សធនធានជីវៈចម្រុះ និងបន្តប្រែក្លាយកំលាំងយុវជន ឱ្យក្លាយជាចំណែកមួយនៃការលើកកម្ពស់ការយល់ដឹងអំពីកិច្ចគាំពារបរិស្ថានចូលរួមថែរក្សាបរិស្ថានស្អាត ផ្សព្វផ្សាយនូវចំណេះដឹងទាំងនេះដល់សាធារៈជនទូទៅបានយល់ដឹងនិងចូលរួមផងដែរ។




វេទិកាយុវជនឆ្នើមថ្នាក់ជាតិ បានរៀបចំពីរឆ្នាំជាប់គ្នាមកហើយ និងបាន ចូលរួមសម្របសម្រួលដឹកនាំបច្ចេកទេសដោយ គណៈកម្មការបច្ចេកទេស មន្ត្រីជាន់ខ្ពស់ នៃ អគ្គនាយក ដ្ឋានជំនាញទាំងបួនរបស់ក្រសួងបរិស្ថាន ក្នុងកំនត់ប្រធានបទនិងការដាក់ពន្ទុ។ វគ្គប្រកួតចែកជាបីវគ្គ ង (១) វគ្គប្រកួតជំបូងដើម្បីជ្រើសរើសយកនិស្សិតចំនួន០៨ ក្រុម ក្នុងចំណោមក្រុមទាំង១៤ (២) វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រដោយប្រកួតជ្រើសរើសយកនិស្សិតចំនួន០៤ក្រុម តាមរយៈប្រធានបទពិភាក្សាដែលកំណត់ដោយក្រសួងបរិស្ថាន និង(៣) វគ្គផ្តាច់ព្រ័ត្រ ដែលតម្រូវឱ្យយុវជនទាំង០៤ក្រុមធ្វើការប្រកួតប្រជែងដណ្តើមជ័យលាភី

ថ្នាក់ជាតិយុវជនឆ្នើម របស់ក្រសួងបរិស្ថាន ដោយមានការផ្តល់រង្វាន់លើកទឹកចិត្តតាមលំដាប់ដែលគណៈកម្មការបានកំណត់ ។










## យុវជនផ្សារភ្ជាប់នឹងបរិស្ថាន



អ្វីៗដូចការគ្រោងទុក យុវជនជាតិ និងអន្តរជាតិប្រមាណ ៣០០នាក់បានមកជួបជុំគ្នានៅពីមុខស្តូបជំកល់អដ្ឋិធាតុ និងបានគោរពវិញ្ញាក្ខន្ធប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតក្នុងរបបបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ស្ថិតក្នុងវត្តអំពែភ្នំ ខេត្តកំពង់ស្ពឺ មុននឹងពួកគេត្រូវបានបែងចែកសម្រាប់ការផ្សព្វផ្សាយចំណេះដឹងបរិស្ថានជូនដល់ប្អូនៗសិស្សសាលា ក្រោមអធិបតីភាព**លោកជំទាវ ងិន លីណា** អគ្គនាយកចំណេះដឹង និងព័ត៌មានបរិស្ថាន នាថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៧។ នៅពីមុខស្តូបអដ្ឋិធាតុរបស់ប្រជាជនកម្ពុជា លោកជំទាវអគ្គនាយកបានមានប្រសាសន៍ថា "ពេលនេះ សកម្មភាពនេះ របស់ប្អូនៗទាំងអស់គ្នានឹងជាកំលាំងចលករដ៏ខ្លាំងខ្លាមួយកម្រិតបន្ថែមទៀតគាំទ្រដល់យុទ្ធនាបរិស្ថានទូទាំងប្រទេសកម្ពុជា" "នៅពេលនេះយើងមាន ៣០០នាក់ ពីម្សិលមិញយើងមាន ៧០០នាក់ ឆ្នាំមុនយើងមានរាប់ពាន់នាក់ ហើយបន្តនិងមានរាប់ពាន់ រាប់ម៉ឺននាក់បន្ថែមទៀតនាបណ្តាឆ្នាំខាងមុខៗទៀត ចូលរួមក្នុងចលនានេះ" លោកជំទាវបានបន្ថែមថា "សូមប្អូនៗចាប់អារម្មណ៍អំពីសកម្មភាពប្រចាំថ្ងៃរបស់ប្អូនៗ ផ្លាស់ប្តូរទម្លាប់ បើសិនជាទម្លាប់ទាំងនោះជាផលអវិជ្ជមានមកលើបរិស្ថាន, ចាប់ផ្តើមធ្វើអនាម័យសម្អាតបរិស្ថាន, សំរាមប្លាស្ទិកតូចមួយដែលប្អូនៗរើស នឹងដើមឈើមួយដើមដែលប្អូនៗដាំនៅពេលនេះនឹងធ្វើឱ្យប្រទេសកម្ពុជាទាំងមូលស្រស់ស្អាត និងជាសុខភាព"។ សូមបញ្ជាក់ថា ក្រោមកិច្ចសម្របសម្រួលរបស់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថាន យុវជន ស.ស.យ.ក.រាជធានីភ្នំពេញ យុវជន ស.ស.យ.ក.វិស័យបរិស្ថាន យុវជនអង្គការ AIESEC និងសិស្ស-និស្សិតមកពីសកលវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ បានធ្វើដំណើរឆ្ពោះទៅមណ្ឌលដ្ឋានអំពែភ្នំ ខេត្តកំពង់ស្ពឺដើម្បីរៀបចំកម្មវិធី Green Up the City។ គោលបំណងដើម្បីផ្សារភ្ជាប់យុវជនទៅនឹងបរិស្ថាន ដើម្បីចូលរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការការពារអតិរេក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាពរបស់ប្រពលរដ្ឋមូលដ្ឋានតាមរយៈសកម្មភាព ដាំកូនដើម

ឈើ ធ្វើអនាម័យបរិស្ថាន ដាក់ធុងសំរាម បរិច្ចាគសម្ភារៈសិក្សា ព្រមទាំងមានការអប់រំ និងផ្សព្វផ្សាយពីការប្រើប្រាស់ ទុកដាក់សំរាមឱ្យមានសណ្តាប់ធ្នាប់ និងកែច្នៃសំណល់ប្លាស្ទិក ជូនដល់ក្រុមយុវជនដែលចូលរួមកម្មវិធី សិស្សសាលា ប្រជាពលរដ្ឋមូលដ្ឋាន អ្នកទេសចរណ៍ និងអាជីវករលក់ដូរផងដែរ។






## ការអប់រំបរិស្ថានក្នុងប្រព័ន្ធ និងក្រៅប្រទេស

ក្រុមគោលដៅសិស្សានុសិស្សបឋមសិក្សា ត្រូវបានចាត់ទុកជាពន្លកទំពាំងស្នងឫស្សី ជំនាន់ក្រោយក្នុងកិច្ចគាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព។ ការបញ្ជ្រាបកម្មវិធីអប់រំបរិស្ថាន ទៅក្នុងកម្មវិធីអប់រំក្នុងប្រពន្ធ័សម្រាប់កម្រិតបឋមសិក្សា ជាយន្តការអប់រំដល់កុមារា កុមារីដ៏មានប្រសិទ្ធភាព។



ទន្ទឹមនឹងសកម្មភាពការអប់រំក្នុងប្រពន្ធ័ នាយកដ្ឋានអប់រំបានខិតខំបង្កើតកម្មវិធីអប់រំក្រៅប្រពន្ធ័ ក៏ដូចជាការលើកកំពស់ការងារប្រឡងប្រណាំងការយល់ដឹង និងការអប់រំបរិស្ថាន តាមរយៈព្រិត្តិការណ៍ និងវេទិកាសំខាន់ៗ។



ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង ៨ព្រឹក នៅទីធ្លាសួនច្បារមុខ វត្តឧណ្ណាលោម មានរៀបចំពិធី «សកម្មភាព អប់រំ អនាម័យបរិស្ថាន តាមច្រាំងទន្លេ » ដែលមានប្រធានបទ« បរិស្ថានស្អាត គ្មានសំរាម គ្មានការបំពុល និងគ្មានសំណល់ប្លាស្ទិក» ក្រោមអធិបតីភាពឯកឧត្តម យុត ចាន់ដារ៉ា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជំទាវអគ្គនាយក ងិន លីណា នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន និងការចូលរួមពីយុវជនជានិសិត្ស មន្ត្រីរាជការមន្ទីរ ក្រសួង កម្មករ អាជីវករជុំវិញតំបន់នោះប្រមាណ៥០ នាក់។




នៅក្នុងកម្មវិធី ឯកឧត្តមអធិបតី បានមានប្រសាសន៍ថា បរិស្ថានសំខាន់សម្រាប់ទីក្រុង គឺបញ្ហាសំរាម និងលូរទឹកស្អុយនេះហើយ ដែលជាកង្វល់របស់ប្រជាពលរដ្ឋយើង។ ទាំងក្រសួងបរិស្ថាន មន្ទីរអាជ្ញាធររាជធានីភ្នំពេញ បានខិតខំពប្រឹងប្រែងយុទ្ធនាការ អប់រំបណ្តុះបណ្តាល ពង្រឹងការអនុវត្តច្បាប់ ការរៀបចំសកម្មភាពអនាម័យ សំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមថែរក្សាបរិស្ថានស្អាត ដោយមិនចោលសំរាមក្រៅធុង ការញែកសំរាម និងការទុកដាក់បានល្អ។ ប្អូនៗជាយុវជនត្រូវធ្វើជាគំរូ និង ជាអ្នកអប់រំបរិស្ថានដល់មិត្តភក្រ័ ដៃគូ និងក្រុមគ្រួសារ និងសហគមន៍ជុំវិញ ដើម្បីយើងទទួលបានបរិស្ថានទាំងអស់គ្នា។ជាពិសេសឯកឧត្តម បានថ្លែងអំណរគុណដល់ ម្ចាស់ជំនួយសប្បុរស លោកAnton Sutter ដែលបានស្រឡាញ់ និងចូលរួមជាមួយការថែរក្សាបបរិស្ថានកម្ពុជា និង ក្រុមហ៊ុន ស៊ិនទ្រី ដែលបានខិតខំប្រមូលសំរាមទាំងថ្ងៃ ទាំងយប់ បើយើងពុំមានពួកគាត់ទេ យើងនឹងជួបបញ្ហាសំរាម ភាពបំពុលបរិស្ថានច្រើនជាងនេះទៅទៀត។ ជាទីបញ្ចប់ កម្មវិធី បានព្រារព្ធសកម្មភាពដើររើសសំរាមរួមគ្នា តាមច្រាំងទន្លេចាប់ពី មុខវត្តឧណ្ណាលោម រហូតដល់ ព្រះបរម្យរាជវាំង ដើម្បីជាសាបង្ហាញមហាជន ឱ្យយល់ចិត្តទុកដាក់លើការ គ្រប់គ្រងសំរាមដែលខ្លួនបានបង្កើត និង កុំចោលទៅក្នុងទន្លេ ដែលជាតំបន់ទេសចរណ៍៕




# សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃការដុតសំរាមនៅទីវាលទៅលើបរិស្ថាន និងសុខភាពមនុស្ស និងវិធានការណ៍ដោះស្រាយ



ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៧ នៅសណ្ឋាគារមណ្ឌលគីរី រាជធានីភ្នំពេញបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃការដុតសំរាមនៅទីវាលទៅលើបរិស្ថាន និងសុខភាពមនុស្ស និងវិធានការណ៍ដោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ ងិន លីណា អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ព្រមទាំងមានការចូលរួមពីលោកអគ្គនាយករង ប្រធាននាយកដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ជាពិសេសក្រុមយុវជនដែលជាវាគ្មិន នៅក្នុងកម្មវិធី "វេទិកាយុវជនឆ្នើមជជែកពិភាក្សាបញ្ហាបរិស្ថានឆ្នាំ២០១៧" ដែលត្រូវជជែកពិភាក្សាលើប្រធានបទ «ទម្លាប់នៃការដុតសំណល់នៅទីវាល គួរត្រូវបញ្ឈប់»។ សិក្ខាកាមចូលរួមនៅក្នុង សិក្ខាសាលានាថ្ងៃនេះ មានចំនួនប្រមាណ៥០នាក់ អញ្ជើញមកពីសកលវិទ្យាល័យនៅតាមរាជធានីខេត្ត ចំនួន៤ រួមមាន: ១.សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ, ២. សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល, ៣. វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, និងទី៤ សាកលវិទ្យាល័យស្វាយរៀង។ គោលបំណងនៃសិក្ខាសាលាផ្សព្វផ្សាយនេះ គឺដើម្បីផ្តល់នូវពុទ្ធិបរិស្ថានថ្មីដល់សិស្សានុសិស្ស និងនិស្សិត ឱ្យបានយល់ដឹងពីសារសំខាន់នៃការប្រើប្រាស់សារធាតុគីមីតាមបទដ្ឋានបច្ចេកទេស និងការទុកដាក់សំណល់សារធាតុគីមីប្រកបដោយសុវត្ថិភាពបរិស្ថាន ជាពិសេសចូលរួមក្នុងការកាត់បន្ថយការកកើតនិងសាយភាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលកើតដោយអចេតនាចេញពីការដុតសំណល់គ្រប់ប្រភេទ ក្នុងគោលបំណងទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់របស់វាទៅលើបរិស្ថាន និងសុខភាពមនុស្ស។ បន្ថែមពីលើនេះទៀត ក្រុមយុវជនដែលជា វាគ្មិនក្នុងវេទិកាយុវជនឆ្នើមជជែកពិភាក្សាបញ្ហាបរិស្ថាន នឹងមានការយល់ដឹងបន្ថែមទៀតពីផលវិបាក នៃការដុតសំរាមនៅទីវាល ព្រមទាំងទទួលបាន

នូវព័ត៌មាន សម្រាប់ការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីរិះរកទម្លាក់ករណ៍ផ្សេងៗមកប្រើប្រាស់នៅក្នុងការ ជជែកពិភាក្សាដេញដោលគ្នាប្រកបដោយវិជ្ជាជីវៈខ្ពស់ និងមានលក្ខណៈវិទ្យាសាស្ត្រ សម្រាប់ជាការ ផ្សព្វផ្សាយចំណេះដឹងបន្តដល់អ្នកចូលរួម និងដល់សាធារណជនទូទៅក្នុងប្រទេសកម្ពុជា។ ក្រៅពីការផ្តល់ ចំណេះដឹង ក៏មានការផ្តល់ព័ត៌មានស្តីពីសកម្មភាពធំៗចំនួន៥ របស់គម្រោង «ផ្សព្វផ្សាយពីបច្ចេកវិទ្យាដ៏ ប្រសើរដែលអាចរកបាន (BAT) និងការប្រតិបត្តិបរិស្ថានដ៏ប្រសើរ (BEP) ពាក់ព័ន្ធនឹងសកម្មភាពដុត សំណល់នៅតាមទីវាលដើម្បីឆ្លើយតបទៅនឹងអនុសញ្ញាស្តុកខូមស្តីពីសារធាតុបំពុលសរីរាង្គមិនងាយ បំបែកធាតុ (POPs)»។

## កម្មវិធី "បៃតង fastival"

កម្មវិធី "បៃតង fastival" ដែលរៀបចំដោយក្រុមហ៊ុន the Idea Consultancy Co.,Ltd. នៅ the Exchange Square ដោយមានអ្នកចូលរួមប្រមាណជាង១០០ នាក់ ភាគច្រើនជាយុវជនស្ម័គ្រចិត្តលើការងារបរិស្ថាន។ ព្រឹត្តិការណ៍នេះមានការតាំងពិព័ណ៌វត្ថុសិល្បៈដែលកែច្នៃពីរបស់បោះចោល/សំរាម ផលិតផលកសិកម្មសរីរាង្គ ការចែកកូនផ្កានិងរុក្ខជាតិដាំលម្អគេហដ្ឋាន និងពិព័ណ៌សាលាកុមារដ្ឋាន។












# ការលើកទឹកចិត្ត ប្រតិបត្តិបៃតង និងមេត្រីភាពបរិស្ថាន ដើម្បីអប់រំផ្សព្វផ្សាយបរិស្ថាន



thoun sokunthy

"រួមគ្នាដើម្បីមេត្រីភាពបរិស្ថាន" គឺជាប្រធានបទមួយ នៃការប្រគំតន្ត្រីមេត្រីភាពបរិស្ថាន ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ នៅខេត្តកែប ស្ថិតក្រោមអធិបតីភាព **ឯកឧត្តម សាបូ អូហ្សាណូ** រដ្ឋលេខាធិការក្រសួងបរិស្ថាន និង **ឯកឧត្តម កែន សត្ថា** អភិបាល នៃគណៈអភិបាលខេត្តកែប លោកជំទាវ **ផិន លីណា** អគ្គនាយក នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន និងមានការចូលរួមពីអតិតបវរកញ្ញាប្រទេសជប៉ុន ចំនួន៣រូប មកពីមូលនិធិទឹកចិត្តទាំងបី ដើម្បីចូលរួមសំដែងក្នុងការចូលរួមបញ្ជ្រាបចំណេះដឹងទាក់ទងវិស័យបរិស្ថាន រួមទាំងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ យុវជន សាធារណជនប្រមាណជា៤០០នាក់។



ការប្រគំតន្ត្រីមេត្រីភាពបរិស្ថាននេះ មានការរៀបចំដោយនាយកដ្ឋានរង្វាន់ និងលើកទឹកចិត្ត នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថាន ក្នុងគោលបំណង ដើម្បីបញ្ជ្រាបការយល់ដឹងពីប្រតិបត្តិបៃតង ឬមេត្រីភាពបរិស្ថានដល់យុវជន សាធារណជន និងប្រជាសហគមន៍ លើកកម្ពស់ការចូលរួមរបស់យុវជន និងសាធារណជនឱ្យស្រលាញ់ធម្មជាតិ និងមេត្រីភាពបរិស្ថាន ក៏ដូចជាជំរុញការយល់ដឹងដល់សាធារណជន និងប្រជាសហគមន៍ ទាក់ទងទៅនឹងអត្ថប្រយោជន៍នៃធនធានធម្មជាតិ និងជីវៈចម្រុះ រួមទាំងការចូលរួមការពារ និងកិរក្សធនធានធម្មជាតិ និងការរស់នៅប្រកបដោយមេត្រីភាពបរិស្ថាន។

នាឱកាសនោះដែរ **ឯកឧត្តម សាបូ អូហ្សាណូ** រដ្ឋលេខាធិការក្រសួងបរិស្ថាន បានឱ្យដឹងថា តាមរយៈការប្រគំតន្ត្រីមេត្រីភាពបរិស្ថាននេះ នឹងជំរុញការផ្សព្វផ្សាយបន្ថែមដល់សាធារណជន និងយុវជនឲ្យចេះស្រលាញ់ ចូលចិត្តបរិស្ថាន ការចូលរួមការពារធានធានធម្មជាតិ ការអភិរក្ស ជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព ហើយប្រជាសហគមន៍ ក៏អាចទទួលបានការយល់ដឹងពីមេត្រីភាពបរិស្ថាន និងលើកកម្ពស់កម្រិតជីវភាពបន្ថែមទៀតផងដែរ ដោយក្នុងនោះការចូលរួមពី វិស័យឯកជនក៏ជាផ្នែកមួយ ក្នុងការលើកកម្ពស់ក្នុងការប្រត្តិបត្តបៃតងល្អប្រកបដោយមេត្រីភាពបរិស្ថាន ដើម្បីឱ្យការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិភាព។

គួបញ្ជាក់ថា ក្នុងការប្រគំតន្ត្រីនេះ គឺមានការបង្ហាញជូននូវល្បែងអប់រំបរិស្ថាន ការប្រគំបទចំរៀងដែលមានអត្ថន័យ ផ្សព្វផ្សាយពីទីក្រុងបៃតង បរិស្ថានផ្តើមចេញពីយើង និងការនៅអោយឆ្ងាយពីគ្រឿងញៀន។ ជាមួយគ្នានេះ ក៏មានការសំដែងបទ កែបសម្អាតកែប ដោយក្រុមអតីតបវកញ្ញានៃប្រទេសជប៉ុន មកពីមូលនិធិទឹកចិត្តទាំងបីKKC និងក្រុមសិស្សមកពីវិទ្យាល័យចរិយាវង្សផងដែរ ដើម្បីបង្ហាញពីការចូលរួមរបស់យុវជន ក្នុងការអប់រំផ្សព្វផ្សាយ ដែលមានជាច្រើនរូបភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព៕






# កម្មវិធីផ្សព្វផ្សាយ និងកាត់បន្ថយសំណល់នៅក្នុងទីប្រជុំជន ក្រុង និងកែច្នៃឡើងវិញ








នាឱកាសនោះ **ឯកឧត្តម អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួង បានមានប្រសាន៍ផងដែរថា កិច្ចគាំពារបរិស្ថាន គឺជាវិស័យអតិភាព ដែលកំពុងយកចិត្តទុកដាក់ ដោយក្នុងនោះក្នុងនោះការទុកដាក់សំរាម និងការកែច្នៃ គឺជាផ្នែកមួយជួយកាត់ន់បន្ថយកាកសំណល់ និងគ្រប់គ្រងកាកសំណល់អោយបានត្រឹមត្រូវដើម្បីទទួលបានបរិស្ថានស្អាតទាំងក្នុងទីក្រុងនិងទីប្រជុំជន ក្នុងការលើកកម្ពស់វិស័យទេសចរណ៏។ យ៉ាងណាមិញ ក្នុងកម្មវិធីនេះ ក៏មានការធ្វើបទបង្ហាញពីគម្រោងកែច្នៃសំណល់ប្លាស្ទិកឱ្យទៅជារបស់របរប្រើប្រាស់ផ្សេងៗក៏ដូចជាគ្រឿងសង្ហារឹម ការតាំងបង្ហាញផលិតផលផ្សេងៗដែលច្នៃពីសំណល់ប្លាស្ទិកដោយសិស្សានុសិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនចរិយាវង្សផងដែរ៕





## រួមគ្នាដើម្បីមេត្រីភាពបរិស្ថាន
## គឺជាកំលាំងចលករដ៏សំខាន់ក្នុងការរួមចំណែកលើកកម្ពស់កិច្ចគាំពារបរិស្ថាន

"រួមគ្នាដើម្បីមេត្រីភាពបរិស្ថាន" គឺជាប្រធានបទមួយ នៃការប្រគំតន្ត្រីមេត្រីភាពបរិស្ថាន ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី៤ ខែសីហាឆ្នាំ២០១៧ នៅ ខេត្តសៀមរាប ក្រោមអធិបតីភាព **លោកជំទាវ ព្រំ សុភី** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និង **ឯកឧត្តម គឹម ឆៃហៀង** អភិបាលរងខេត្តសៀមរាប លោកជំទាវ អគ្គនាយក នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន រួមទាំងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ មន្ត្រីឧទ្យានុរក្ស សិស្សានុសិស្ស យុវជន សាធារណជនប្រមាណជា៨០០នាក់។

ការប្រគំតន្ត្រីមេត្រីភាពបរិស្ថាននេះ គឺជាលើកទី២ ហើយសម្រាប់ឆ្នាំ២០១៧ ដែលមានការរៀបចំដោយនាយកដ្ឋានវង្វាន់ និងលើកទឹកចិត្ត នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថានក្នុងគោលបំណង ដើម្បីបញ្ជ្រាបការយល់ដឹងពីប្រតិបត្តិបៃតង ឬមេត្រីភាពបរិស្ថានដល់យុវជន សាធារណជន និងប្រជាសហគមន៍ លើកកម្ពស់ការចូលរួមរបស់យុវជន និងសាធារណជនឱ្យស្រលាញ់ធម្មជាតិ និងមេត្រីភាពបរិស្ថាន ក៏ដូចជាជំរុញការយល់ដឹងដល់សាធារណជន និងប្រជាសហគមន៍ ទាក់ទងទៅនឹងអត្ថប្រយោជន៍នៃធនធានធម្មជាតិ និងជីវៈចម្រុះ រួមទាំងការចូលរួមការពារ និងភិរក្សធនធានធម្មជាតិ និងការរស់នៅប្រកបដោយមេត្រីភាពបរិស្ថាន។

នាឱកាសនោះដែរ **លោកជំទាវ ព្រំ សុភី** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន បានឱ្យដឹងថា តាមរយៈការប្រគំតន្ត្រីមេត្រីភាពបរិស្ថាននេះ នឹងជំរុញការផ្សព្វផ្សាយបន្ថែមដល់សាធារណជន និងយុវជនឲ្យចេះស្រលាញ់ ចូលចិត្តបរិស្ថាន ការចូលរួមការពារធានធានធម្មជាតិ ការអភិរក្ស ជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព ហើយប្រជាសហគមន៍ ក៏អាចទទួលបានការយល់ដឹងពីមេត្រីភាពបរិស្ថាន និងលើកកម្ពស់កម្រិតជីវភាពបន្ថែមទៀតផងដែរ ដោយក្នុងនោះការចូលរួមពី វិស័យឯកជនក៏ជាផ្នែកមួយ ក្នុងការលើកកម្ពស់ក្នុងការប្រត្តិបត្តបៃតងល្អប្រកបដោយមេត្រីភាពបរិស្ថាន ដើម្បីឱ្យការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិភាព។



គូសបញ្ជាក់ថា ក្នុងការប្រគំតន្ត្រីនេះ គឺមានការបង្ហាញជូននូវការប្រគំបទចំរៀង ដែលមានអត្ថន័យផ្សព្វផ្សាយពីទីក្រុងបៃតង មេត្រីភាពបរិស្ថានផ្តើមចេញពីយើង និងមានការសំដែងបទចំរៀងអប់រំបរិស្ថាន ដោយសិស្ស សាលាបឋមសិក្សាវត្តបូព៌ ផងដែរ។ ក្នុងព្រឹត្តិការណ៍ នៃការប្រគំតន្ត្រីនេះ ក៏មានការដាក់បង្ហាញពីផលិតផល ដែលបានមកពីការកែច្នៃសំរាម ដែលមានដូចជា កាបូប រូបចម្លាក់ និងរូបសត្វ ជាដើម ដើម្បីបង្ហាញពីការចូលរួមរបស់យុវជន ក្នុងការអប់រំផ្សព្វផ្សាយ ដែលមានជាច្រើនរូបភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការស្រឡាញ់វប្បធម៌។ ជាមួយគ្នានេះ ក៏មានការចែកជូននូវវិញ្ញាណប័នប័ត្រ ដល់អ្នកដែលប្រតិបត្តិករមេត្រីភាពបរិស្ថានបានល្អផងដែរ៕



## ពង្រឹងការងារសហប្រតិបត្តិការលើផ្នែកចំណេះដឹង និងព័ត៌មានបរិស្ថាន

អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន សហការជាមួយគណៈកម្មការបវរកញ្ញាខ្មែរអាមេរិកាំង ដៃគូគាំទ្រ និងឧបត្ថម្ភនានា បានរៀបចំទទួលបដិសណ្ឋារកិច្ចដំណើរទស្សនកិច្ច «សប្បុរសធម៌ដើម្បីបរិស្ថាន និងទេសចរណ៍» របស់បវរកញ្ញាខ្មែរអាមេរិកាំង និងបវរកញ្ញាពិភពលោក ដែលបានមកធ្វើទស្សននៅប្រទេសកម្ពុជា កាលពី ថ្ងៃទី២៥ ខែកុម្ភៈ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៧។ ដំណើរទស្សនកិច្ចនេះមានគោលបំណងគាំទ្រដល់ការងារអប់រំ និងផ្សព្វផ្សាយបរិស្ថានតាមរយៈសកម្មភាពមួយចំនួននៅរាជធានីភ្នំពេញខេត្តសៀមរាប និងខេត្តព្រះសីហនុ។

អគ្គនាយកដ្ឋាន បានសហកាជាមួយជាមួយក្រសួងទេសចរណ៍ និងដៃគូគាំទ្រឧបត្ថម្ភនានារៀបចំព្រឹត្តិ ការណ៍តន្ត្រីសប្បុរសធម៌ដើម្បីបរិស្ថាន និងទេសចរណ៍ ក្នុងគោលបំណងការប្រគុំតន្ត្រីនេះមានគោល បំណងដើម្បី១)ផ្តល់នូវការយល់ដឹងពីគុណតម្លៃនៃបរិស្ថាន និងបណ្តុះស្មារតីសាធារណជនឱ្យស្រឡាញ់គាំទ្រ និងចូលរួមក្នុងសកម្មភាពគាំពារបរិស្ថានដែលផ្តោតសំខាន់ទៅលើការគ្រប់គ្រងសំណល់រឹងរាវ ២)លើកតម្កើងការអនុវត្តបៃតង ៣)ប្រមូលថវិកាសប្បុរសធម៌ដើម្បីទ្រទ្រង់ «មូលនិធិធុងអប់រំបរិស្ថាន»។ ដើម្បីសម្រេចបាននូវគោលនយោបាយរបស់ក្រសួងបរិស្ថាន ក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព និងការអភិវឌ្ឍ ដោយចីរភាពអគ្គនាយកដ្ឋានចំណេះដឹង និង




ព័ត៌មានបរិស្ថាន មានទិសដៅបន្តក្នុងការលើកកម្ពស់ការងារអប់រំបរិស្ថាន ក្នុងគោលបំណងផ្លាស់ប្តូរផ្នត់គំនិត និងការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមនៅក្នុងវិស័យបរិស្ថាន ។ ដើម្បីឆ្លើយតបទៅនឹងទិសដៅខាងលើ អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន បានរៀបចំសកម្មភាពជាយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- បន្តអនុវត្តនិងលើកកម្ពស់ចលនាអនុវត្តសាលាមេត្រីបរិស្ថានទាំងក្នុង សាលារៀន លំនៅដ្ឋាន វត្តអារាម និងសហគមន៍ដើម្បីប្រែក្លាយគ្រឹះស្ថានសិក្សា ទីអារាម និងសហគមន៍ទាំងនេះទទួលបានបរិស្ថានបៃតង និង ប្រតិបត្តិបរិស្ថានល្អ។

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា ដើម្បីធ្វើបច្ចុប្បន្នភាព និងបញ្ជ្រាបកម្មវិធីសិក្សាបរិស្ថានគ្រប់ភូមិសិក្សា និងចលនាប្រឡងប្រណាំងអនុវត្តកម្មវិធី "សាលាមេត្រីបរិស្ថាន"នៅគ្រប់ភូមិសិក្សាខេត្តក្រុងទូទាំងប្រទេស។
- បង្កើនកម្មវិធីអប់រំក្រៅប្រពន្ធ័ដល់ក្រុមគោលដៅ និង ជម្រុញវេទិកាយុវជនថ្នើមថ្នាក់ជាតិ ពិភាក្សាអំពីបញ្ហាបរិស្ថាន ការប្រឡងប្រណាំងគូរគំនូរ និពន្ធកំណាព្យដែលទាក់ទងវិស័យបរិស្ថាន សំដៅលើកកម្ពស់ការយល់ដឹងការប្រើប្រាស់ធនធានធម្មជាតិ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងកាកសំណល់
- ពង្រឹងនិងបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីអប់រំបរិស្ថាន ទាំងបរិមាណ និងគុណភាព តាម រយៈការរៀបចំវគ្គបណ្តុះបណ្តាលជំនាញបរិស្ថានដល់មន្ត្រីបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ និងពង្រឹងចំណេះដឹង បរិស្ថានដល់គ្រូ និងសាស្ត្រាចារ្យ នៅសាលាគរុកោសល្យ និងវិក្រឹត្យការមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីឈានទៅសម្រេចបាននូវការសាងសមត្ថភាពបរិស្ថាននៅទូទាំងប្រទេស។



# ការផ្ទេរបទពិសោធន៍មន្ត្រីវ័យក្មេងរបស់ក្រសួងបរិស្ថានចំនួន៥រូប





មន្ត្រីវ័យក្មេងរបស់ក្រសួងបរិស្ថានចំនួន៥រូបដែលបានទៅសិក្សា និងដកស្រង់បទពិសោធន៍ក្នុងវគ្គបណ្តុះបណ្តាលកាសាអង់គ្លេសពាក់ព័ន្ធនឹងប្រធានបទ Strengthening Resilience រយៈពេល ៦ខែ នៅប្រទេសនូវែលហ្សេឡង់ បានរៀបចំកម្មវិធីចែករំលែកចំណេះដឹង បទពិសោធន៍ និងជំនាញរបស់ខ្លួន នៅរសៀលថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងបរិស្ថាន ក្រោមអធិបតី **ឯកឧត្តម យុត ចាន់ដារ៉ា** និងក្រុមការងារ ស.ស.យ.ក វិស័យបរិស្ថាន។ មន្ត្រីវ័យក្មេងទាំង៥រូបនេះគឺ ទី១ **ម៉ែម ច័ន្ទដារ៉ា** ជាមន្ត្រីនាយកដ្ឋានអធិការកិច្ច និងពង្រឹងច្បាប់ ទី២ **កញ្ញា សៀង សុធារី** ជាមន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអប់រំបរិស្ថាន ទី៣**លោក អាំង ហៃផេង** មន្ត្រីមន្ទីរពិសោធន៍ ទី៤ **លោក ស្រេង ចន្ថា** មន្ត្រីបច្ចេកទេស អធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ ទី៥**អ្នកនាង សាន ដាណា** មន្ត្រីនាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង។

មន្ត្រីទាំង៥រូបនេះ ត្រូវបានក្រសួងបញ្ជូនទៅសិក្សា និងដកស្រង់បទពិសោធន៍នៅប្រទេសនូវែលហ្សេឡង់ស្តីពីការពង្រឹងភាពស៊ាំ (Strengthening Resilience)រយៈពេល៦ខែ។ ក្នុងកម្មវិធីចែករំលែកបទពិសោធន៍នេះ មន្ត្រីវ័យក្មេងទាំង៥រូប បានចែករំលែកបីចំនុចសំខាន់ មកបង្ហាញ គឺរបៀបនៃការដាក់ពាក្យដើម្បីទទួលបានអាហារូបករណ៍ កម្មវិធីដែលបានសិក្សារៀនសូត្រ និងកម្មវិធីអាហារូបករណ៍ផ្សេងទៀត ដែលមន្ត្រីវ័យក្មេងក្រសួងបរិស្ថានបានដាក់ ពាក្យស្នើសុំកន្លងមក និងបានចែករំលែកចំណេះដឹងមួយចំនួនដែលទាក់ទងនឹងវិស័យបរិស្ថានផងដែរ។



# ចំណេះដឹងទូទៅ

# ជីវិត និង សង្គម

## រឿងដ៏គួរឲ្យភ្ញាក់ផ្អើល! ទៅស្រែប្រទះឃើញក្រឡបុរាណមួយ រួចក៏យកមកផ្ទះ ស្រាប់តែមានរឿងអកុសលហេតុនឹកស្មានមិនដល់...(នៅខ្មែរយើងតែម្តង ហើយជារឿងពិត)

អ្នកភូមិនគរក្រៅ ស្ម័គ្រចិត្តប្រគល់ក្រឡបុរាណដែលជីកបាន បន្ទាប់ពីរក្សាទុកអស់រយៈពេល ៣ខែ អ៊ំស្រី សាប គួន អាយុ ៦៨ឆ្នាំ ជាពលរដ្ឋនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប។

កាលពី ៣ខែមុន គាត់បានប្រទះឃើញក្រឡមួយខណៈកំពុងឆាយដីដើម្បីដាំពោតដែលមានទីតាំងនៅខាងជើងផ្ទះជិតប្រាសាទទន្លេស្ងួត។ តាមការរៀបរាប់របស់អ៊ំស្រីបានឲ្យដឹងថា ពេលឃើញក្រឡដំបូងគឺមិនហ៊ានគាស់យកទេ ព្រោះខ្លាចជាក្រឡដាក់ឆ្អឹងខ្មោច (តាមជំនឿ) ហើយក៏មិនដឹងថាក្រឡនោះជារបស់មានតម្លៃ ជារបស់បុរាណអីដែរ ទើបហៅកូនប្រុសឲ្យមកជីកយក។

ពេលជីកបាន ដោយគិតថា ជារបស់អពមង្គល គាត់ក៏មិនហ៊ានយកទៅដាក់នៅលើផ្ទះ ឬយកទៅដាក់អំបិលប្រហុកអីដែរ ខ្លាចម្ចាស់គេប្រកាន់នាំគ្រោះចង្រៃដល់ខ្លួន និងគ្រួសារ ក៏ដាក់ពាសវាលពាសកាលក្នុងបរិវេណដីគាត់ ដោយគ្មានការថែរក្សាត្រឹមត្រូវ។អ៊ំស្រីបន្តទៀតថា គាត់គ្មានបំណងលាក់ទុកវត្ថុបុរាណនេះទុកឡើយ ហើយក៏មិនមានបំណងលក់ដូរអីដែរ បើទោះបីមានគេមកចរចាពីរបីដងក៏ដោយ ក៏គាត់មិនបានប្រាប់ថា គាត់មានក្រឡបុរាណដែរ ដោយបង្ហាញក្រឡផ្សេងទៀត តែគេមិនយកព្រោះមិនមែនរបស់មានតម្លៃ ហើយអ៊ំស្រីក៏មិនដែលនិយាយរឿងរ៉ាវនេះប្រាប់អ្នកណាម្នាក់ដែរ។

លុះទុកបានប្រហែល ១ខែ គាត់ក៏ចាប់ផ្តើមធ្លាក់ខ្លួនឈឺមើលអស់លុយជាច្រើន លុះទៅបួលគ្រូខ្មែរមើល ក៏ត្រូវគេទាយថា គាត់មានរបស់បុរាណរក្សាទុក លុះមកដល់ផ្ទះ ក៏ឃើញក្រឡដែលខ្លួនជីកបាន ទើបគាត់កាន់តែមិនសូវខ្វល់ខ្វាយក្នុងការថែរក្សា។ ក្រោយមកពេលមានការកំណាយនៅទន្លេស្ងួត គាត់ក៏ធ្លោយមាត់ប្រាប់ដល់កម្មករម្នាក់ដែលធ្វើការនៅទីនោះ ហើយកម្មករនោះក៏បានប្រាប់ទៅខាងអាជ្ញាធរជាតិអប្សរាទើបបែករឿងនេះទៅ។ ក្រោយការពន្យល់ពីហេតុផលជាច្រើនទាក់ទងនឹងច្បាប់ និងការចូលរួមថែរក្សាមរតកបេតិកភណ្ឌជាតិ រួមនឹងការមើលមិនឃើញពីតម្លៃនៃវត្ថុបុរាណនេះដដែល គាត់ក៏បានស្ម័គ្រចិត្តប្រគល់ក្រឡបុរាណនេះជូនអាជ្ញាធរជាតិអប្សរាដើម្បីប្រគល់ឲ្យសារមន្ទីរនរោត្តមសីហនុ-អង្គរជាអ្នករក្សាទុកកាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១៧។ក្នុងនោះដើម្បីជាការលើកទឹកចិត្ត អាជ្ញាធរជាតិអប្សរាក៏បានប្រគល់ថវិកាចំនួន ២០០,០០០រៀល ដល់អ៊ំស្រីផងដែរ។ ទាក់ទងនឹងក្រឡបុរាណនេះដែរ តាមការបញ្ជាក់ពីលោកបណ្ឌិត អ៊ា ដារិទ្ធិ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ មានជំនាញផ្នែកភាជន៍ បានឲ្យដឹងថា ក្រឡនេះធ្វើអំពីដីដុត សម្រាប់ដាក់វត្ថុច្រើនប្រភេទដូចជា អំបិល ស្ករ ប្រហុក និងវត្ថុរាវផ្សេងៗទាក់ទងជីវិតប្រចាំថ្ងៃ។






ក្រឡនេះផលិតនៅស្រុកខ្មែរ ចន្លោះសតវត្សទី ១១ ទៅ ១៥ នៃគ.ស។ តាមរយៈក្រឡនេះ វាបានបង្ហាញពីទំនាក់ទំនងមួយរវាងមនុស្សសម័យមុន និងបច្ចុប្បន្នដែលនៅតែមានប្រើក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

តាំងនាមឲ្យអាជ្ញាធរជាតិអប្សរា លោកបណ្ឌិតក៏សូមថ្លែងអំណរគុណដល់អ៊ំស្រីដែលរួមចំណែកក្នុងការស្រឡាញ់បេតិកភណ្ឌជាតិ និងបានប្រគល់ក្រឡនេះឲ្យក្រុមការងាររក្សាទុក ព្រមទាំងសិក្សាពីប្រវត្តិរបស់វាផងបន្ត ហើយក៏សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលរើសបានរបស់បុរាណទាំងអស់ សូមកុំលក់បន្តកុំរក្សាទុកដោយខុសច្បាប់ព្រោះវត្ថុបុរាណមួយ បង្ហាញពីសម័យកាលនិងប្រវត្តិសាស្ត្រមួយរបស់ជាតិខ្មែរ៕




## រកឃើញហ្វូស៊ីលគ្រំ ខ្យង និងងាវសមុទ្រនៅដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពដែលអាចមានអាយុរាប់លានឆ្នាំ



ដុំហ្វូស៊ីលខ្យង គ្រំ និងងាវដែលយកចេញពីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព។ រូបភាព៖ សុភាព

កាលពីពេលថ្មីៗកន្លងទៅនេះ ក្រុមស្រាវជ្រាវនៃនាយកដ្ឋានបេតិកភណ្ឌនៃក្រសួងបរិស្ថានបានរកឃើញហ្វូស៊ីល ខ្យង គ្រំ និងងាវសមុទ្រក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ខេត្តព្រះវិហារដែលអាចមានអាយុរាប់លានឆ្នាំ។

លោកលឹម វណ្ណចន្ទ័ អនុប្រធានការិយាល័យអប់រំផ្សព្វផ្សាយនៃក្រសួងបរិស្ថាន លើកឡើងថា "តាមរយៈនៃការរកឃើញនេះ ក្រុមបច្ចេកទេសអាចសន្និដ្ឋានថាប្រទេសកម្ពុជាអាចធ្លាប់ជាបាទសមុទ្រ ហើយទីទួលនោះអាចជាកន្លែងដែលកាលពីមុនមានការចាក់បង្គរងាវ គ្រំ ឬខ្យង។ បើតាមការសិក្សាទំរាំបានក្លាយជាថ្មយ៉ាងដូចនេះ គឺវាត្រូវការឆ្លងកាត់ពេលវេលារាប់លានឆ្នាំ"។ ដោយសារតែកង្វះអ្នកជំនាញហ្វូស៊ីលនេះនៅមិនអាចវាស់អាយុកាលពិតប្រាកដ នៅឡើយទេ ប៉ុន្តែលោកអាចត្រឹមសន្និដ្ឋានបានថា ហ្វូស៊ីលនេះមានអាយុមិនតិចជាងរាប់លានឆ្នាំនោះទេ។

ដុំហ្វូស៊ីលទាំងនោះមានរាងជាដុំថ្មដែលមានផ្គុំទៅដោយងាវសមុទ្រ ងាវ ឬក៏គ្រំដែលត្រូវបានរកឃើញនៅលើទួល មួយក្នុងកន្លែងក្នុងភូមិសាស្ត្រនៃដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព។ លោក លឹម វណ្ណច័ន្ទ បានរំពឹងថា ប្រសិនទីតាំងនេះតំបន់ដែលរកឃើញហ្វូស៊ីលត្រូវបានសិក្សាធ្វើកំណាយនោះ វានឹងនាំទៅដល់ការស្វែងយល់ពីការចំណាស់នៃទឹកដីរបស់កម្ពុជា ហើយអាចស្វែងយល់ពីប្រភេទសត្វដែលមានប្រវត្តិក្នុងប្រទេសកម្ពុជា។

លោកសង្កត់ធ្ងន់ថា ហ្វូស៊ីលទាំងនេះ គឺនឹងអាចក្លាយជារបស់បេតិកភណ្ឌសម្រាប់ការសិកស្រាវជ្រាវយ៉ាងសំខាន់បំផុតមួយ៕

លោកលឹម វណ្ណច័ន្ទ អនុប្រធានការិយាល័យអប់រំផ្សព្វផ្សាយនៃក្រសួងបរិស្ថាន។ រូបថត៖ សុភាព





ដុំហ្វូស៊ីលខ្យង គ្រំ និងងាវដែលយកចេញពីដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព។ រូបភាព៖ សុភាព

# ប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

## ទូក ឆ្លាក់រូបសត្វ "ម្ករ" របស់ខ្មែរមានឥទ្ធិពលលើវប្បធម៌ថៃ តើសត្វ "ម្ករ" ជាអ្វីបានលេបសត្វនាគ,គ្រុឌ ឬ ទេពផ្សេងៗ មានប្រភពមកពីណា ?

ខ្មែរយើងមានវប្បធម៌នៃការប្រើប្រាស់ទូកនេះយូរអង្វែង ណាស់មកហើយ គឺមុនពួកឥណ្ឌាចូលស្រុកមកទៀត គឺតាមរយៈទឹកដីភូមិសាស្ត្រ ដែលសំបូរទៅដោយព្រែក ស្ទឹង បឹង ទន្លេ សមុទ្រ នេះ ដែលតម្រូវឲ្យខ្មែរចេះប្រើប្រាស់ទូកសម្រាប់ជាមធ្យោបាយធ្វើដំណើរ រហូតមកដល់ពេលបច្ចុប្បន្នក៏ការប្រើប្រាស់ទូករបស់ខ្មែរនៅតែមាន សារៈសំខាន់សម្រាប់ប្រើនៅក្នុងការនេសាទ និងការធ្វើដំណើររបស់អ្នកស្រុកនៅតាមមាត់ស្ទឹងទន្លេ ឬអ្នកនៅលើភូមិបណ្តែតទឹក ។




ប្រសិនបើយើងងាកទៅមើលភស្តុតាងអំពីការប្រើប្រាស់ទូក យើងឃើញមានចម្លាក់ទូកវែងនៅលើស្គរមហោរធឹក នៅក្នុងសិល្បៈសម័យដុងសឺន ដែលមានអាយុកាល ពីរ ទៅបី សតវត្ស មុនគ្រឹស្តសករាជ ទូកនោះមានចំណុះទូក ឬដៃចង្វារប្រហែល ១០ នាក់ ដែលនៅលើក្បាលទូកក៏មានការតុបតែងដូចជារូបសត្វអ្វីមួយ ។ ផុតពីរូបនោះ ទាល់តែចូលមកដល់សម័យសិល្បៈរចនាប័ទ្មបាពួន ទើបយើងឃើញមានវត្តមានទូកវែងមួយទៀត នៅលើផ្ដែរប្រាសាទភ្នំរូង នៅខេត្តបុរីរម្យ ប្រទេសថៃ ចូលមកដល់រចនាប័ទ្មអង្គរ យើងឃើញមានចម្លាក់ទូកមួយចំនួនតូច ក្នុងនោះក៏មានរូបទូកធំពីរ ដែលអ្នកប្រវត្តិសាស្ត្រសន្និដ្ឋានថាជារូបទូកក្នុងសិល្បៈមនភូមា មិនមែនសិល្បៈខ្មែរទេ ។



មកដល់សម័យបាយ័ន មានចម្លាក់ជាច្រើនបង្ហាញពីរូបទូក ទាំងក្នុងទម្រង់សាសនា និងប្រើប្រាស់ក្នុងសង្គ្រាមជើងទឹករវាងខ្មែរ ចាម ដែលនៅក្នុងចម្លាក់ប្រាសាទបាយ័ន ប្រសិនបើយើងរាប់ដៃចង្វារតែម្ខាងៗ យើងឃើញថាទូកចាម មានដៃចង្វារមួយចំហៀងប្រហែល ១៥ នាក់ ដូច្នេះទូកចាមគួរមានប្រវែងប្រហែលពី ១២ ទៅ ១៥ ម៉ែត្រ ដោយឡែកទូកខ្មែរ ឃើញមានចំនួនដៃចង្វារមួយចំហៀងៗខុសៗគ្នាគឺចាប់ពី ១០, ១២, ១៤, ១៥, ១៨ និងរហូតទៅដល់ ២២ ដែលមានន័យថា ទូកខ្មែរមានប្រវែងប្រហែលពី ១០ ម៉ែត្រ ទៅជាង ២០ម៉ែត្រ គឺមានប្រវែងមិនខុសគ្នាប៉ុន្មានពីទូកង. ទូកម្នងសម័យបច្ចុប្បន្ន ដែលមានចំណុះទូកពីជាង ២០នាក់ ទៅ ៤០នាក់នោះទេ ឯកសារមួយបកស្រាយដោយលោកបណ្ឌិតមីសែល ត្រាណេ ក៏បានលើកឡើងដែរថាទូកខ្មែរសម័យបាយ័នមានប្រវែងជាង ២០ម៉ែត្រ និងមានទទឹងធំបំផុតជាង ១ម៉ែត្រ ។ ចំណុចគួរឲ្យចាប់អារម្មណ៍មួយនៅក្នុងសិល្បៈឆ្លាក់លើតួទូកនៅ សម័យបាយ័ន គឺទូកភាគច្រើនមានរូបម្កុរ អាចជារូបម្កុរខ្ចាក់គ្រុឌ ខ្ចាក់នាគកល្បៈ ដោយមានរូបព្រះក្រឹស្ណៈចាប់ហែកនាគកល្បៈជាដើម ឬមានទូកមួយចំនួនដែលមានតែរូបម្កុរតែប៉ុណ្ណោះ ។ វត្តមាននៃទូករូបម្កុរនេះ យើងឃើញមាននៅក្នុងរូបថតសម័យបារាំងមួយសន្លឹក ដែលប្រហែលជាថតនៅក្នុងពិធីបណ្ដែតព្រះអង្គារ (សំណល់ពីការបូជាព្រះសព) របស់ព្រះបាទនរោត្តម ឬក៏ព្រះបាទស៊ីសុវត្ថិ ហើយនៅក្រោយពិធីបូជាព្រះសពរបស់អតីតមហាក្សត្រនរោត្តម សីហនុ ក៏មានការរៀបចំជារូបទូកម្កុរខ្ចាក់នាគ សម្រាប់ពិធីបណ្ដែតព្រះអង្គារនេះដែរ ។



ប្រសិនបើយើងងាកនៅមើលប្រទេសជិតខាង គឺប្រទេសថៃ នៅក្នុងក្បួនទូកព្រះទីនាំង នៃក្បួនព្យូហយាត្រាជលមគ្គ ដែលមានទូកអុំ ជាច្រើន នៅក្នុងនោះមានទូកមួយគូ មានឈ្មោះចាប់ផ្ដើមដោយពាក្យថា ឯកជ័យ (เอกชัย) ដែលទូកនេះមានចំណុះដៃចង្វារប្រហែល ៤០នាក់ នៅពេលខ្លះទូកមួយគូនេះមានតួនាទីជួយអូសព្រះទីនាំងសំខាន់ (ប្រហែលជាព្រះទីនាំងសុវណ្ណហង្ស) ។ រូបរាងរបស់ទូកព្រះរាជទ្រព្យ របស់មហាក្សត្រថៃនេះ មានរូបរាងប្រហាក់ប្រហែលគ្នាទៅនឹងទូកខ្មែរ មួយចំនួននៅលើចម្លាក់នៃប្រាសាទបាយ័ន ។ ខ្ញុំធ្លាប់អានសៀវភៅ និរាសនគរវត្ត របស់សម្ដេចតម្រង់រាជានុភាព ជាបុត្រារបស់ស្ដេចមកុដ្ឋ រាមាទី ៤ នឹងត្រូវបានជនជាតិថៃ ចាត់ទុកជាបិតានៃប្រវត្តិសាស្ត្រថៃ ទ្រង់បានមកទស្សនាប្រទេសខ្មែរ ពីរទៅបីដង តាំងពីសម័យព្រះបាទស៊ីសុវត្ថិ ដោយនៅក្នុងសៀវភៅនិរាសនគរវត្ត

នោះ មានការបរិយាយថាទ្រង់បានសង្កេតឃើញថាទូករបស់ខ្មែរ ទោះជាធំ ឬតូចយ៉ាងម៉េចក៏ដោយ ក៏ទូកនោះមានការបិតទូក ដូចគ្នាទៅនឹង ទូកព្រះទីនាំងនៅប្រទេសថៃ ហើយទ្រង់សន្និដ្ឋានថាទូកព្រះទីនាំងថៃ គួរតែទទួលឥទ្ធិពលពីខ្មែរ ព្រោះថាទូកថៃ តូចៗ មានលក្ខណៈ នៃការបិតទូកខុសពីខ្មែរ។ ទូកថៃតូចៗ មានការបិតដោយយកបន្ទះក្តារ នៅពីក្រោមរាងបួនជ្រុងទ្រវែង ហើយទើបមានការបិតក្តារបញ្ឈាកពីចំហៀង និងពីក្បាល ពីកន្សៃ ដោយឡែកទូកខ្មែរទាំងតូច ទាំងធំ ទាំងវែង ទាំងខ្លី មានការនិយមបិតជាទម្រង់ខ្នងក្រពើ គឺកោងហើយទ្រវែង គឺមានជម្រៅជ្រៅជាងទូកថៃតូចៗ ដោយមានការបិតក្តារជាមុំទេរតាមឆ្អឹងទូក ដោយដាក់បន្ទះក្តារឲ្យស៊ីគ្នា ហើយនិយមធ្វើឲ្យមានក្បាលទូក និងកន្សៃទូក។សូមបន្ថែមបន្តិចអំពីម្ករម្ករគឺជាសត្វនៅក្នុងទេវកថាព្រហ្មញ្ញសាសនា សម្រាប់ភាសាហិណ្ឌីបច្ចុប្បន្នពាក្យថាម្ករ គឺសត្វក្រពើ ខ្មែរស្គាល់ម្ករនេះយូរមកហើយ ដែលយើងឃើញវត្តមានរបស់ម្ករនេះនៅក្នុងសិល្បៈខ្មែរតាំងពីសម័យមុនអង្គរ រហូតមកដល់សិល្បៈប្រពៃណីយ៍សម័យបច្ចុប្បន្នក៏នៅតែមានវត្តមាន ។



រឿងតំណាលថាម្ករ គឺកើតចេញពីសក់ខ្មៅ ១ សសៃរបស់ព្រះនាងគង្គា ដែលបានធ្លាក់មកលើផែនដីកើតបានជាម្ករ ពេលម្ករកើតមក វាបានលេបសត្វ និងទេព ទាំងឡាយនៅលើផែនដី រហូតដល់ព្រះសិវៈចុះមកបង្រ្កាប ហើយទើបបង្គាប់ម្ករខ្ជាក់សត្វ និងទេពនិករទាំងឡាយចេញមកវិញ ដោយក្នុងនោះនៅក្នុងសិល្បៈខ្មែរ ឃើញមានរូបម្ករខ្ជាក់នាគ ខ្ជាក់គ្រុឌ ខ្ជាក់គោ ចំណែកសិល្បៈឥណ្ឌូនេស៊ី និងឡានណានៅភាគខាងជើងថៃ ឃើញមានរូបម្ករខ្ជាក់ទេពប្រណម្យទៀត ។ *អត្ថបទរូបភាពដកស្រង់ចេញពីខ្មែរអប្សរា*



## អស្ចារ្យ ! ចិនរកឃើញវិធីដាំដុះស្រូវប្រើទឹកសមុទ្រ និង ដាំស្រូវអត់ទឹក និង បង្កើតពូជស្រូវយក្សកម្ពស់ ២ ម៉ែត្រផ្តល់ទិន្នផល ១៥ តោនក្នុងមួយហិកតា

ចិនបញ្ចេញគម្រោងផលិតស្រូវបានទិន្នផលច្រើននៅលើដីស្រែស្ងួត មិនសូវមានទឹកជោគជាំកាលពីថ្មីៗនេះ។ គម្រោងថ្មីនេះត្រូវបានគេសាកល្បងនៅខេត្ត Hebei ហើយទិន្នផលស្រូវដែលគេអាចផលិតបាននោះមានទំហំដល់ទៅជាង ៦តោន ទោះមិនសូវមានទឹកស្រោចស្រពគ្រប់គ្រាន់ក្តី។



គម្រោងស្រាវជ្រាវប្រភេទស្រូវដែលអាចដាំដុះលើដីស្ងួតមិនសូវមាន ទឹកស្រោចស្រពច្រើន តែបានផលខ្ពស់នោះ ត្រូវបានគេបញ្ចេញជាផ្លូវការហើយនៅប្រទេសចិន។ គម្រោងនេះត្រូវបានអនុវត្តដោយជោគជ័យកន្លងមកនៅខេត្តភាគខាងជើង Hebei ហើយវាត្រូវបានស្រាវជ្រាវឡើងដោយកំពូលអ្នកជំនាញបង្កាត់ពូជស្រូវលោក Yuan Longping។សារព័ត៌មានរដ្ឋចិន People's Daily បានផ្សាយថា ក្រោយសម្រេចជោគជ័យក្នុងការសាកល្បងគម្រោងស្រាវជ្រាវប្រភេទស្រូវនេះ គេអាចចាប់ផ្តើមដាំដុះស្រូវនៅតំបន់ដែលជួបភាពរាំងស្ងួតនៅភាគខាង ជើងបាន។



ជាធម្មតាស្រូវត្រូវការទឹកច្រើនដើម្បីលូតលាស់។ ដូច្នេះហើយ នៅពេលដែលស្រូវនេះត្រូវបានគេស្រាវជ្រាវនិងសាកល្បងដោយជោគជ័យ វាក៏ជួយឲ្យកសិករចិនមានវិធីសាស្ត្រថ្មី និងមានលទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈមជាពិសេសបង្កើនចំណូល និងកាត់បន្ថយភាពក្រីក្របានរហ័សដែរ។វាក៏ជួយឲ្យកសិករសន្សំសំចៃទឹកសម្រាប់ស្រោចស្រពដំណាំ និងអាចផ្តល់អត្ថប្រយោជន៍ច្រើនទៀតដល់កសករផងដែរ។ បើតាមសារព័ត៌មានចិនខាងលើដដែល ស្រូវប្រភេទថ្មីនេះមានតម្លៃ ៤ យ័ន ឬ ០,៦ ដុល្លារក្នុងមួយគីឡូក្រាមប៉ុណ្ណោះ។




ក្រៅពីប្រភេទពូជស្រូវដាំដុះមិនត្រូវការទឹកច្រើន ចិនក៏ស្រាវជ្រាវបានប្រភេទស្រូវដែលអាចដាំដុះដោយប្រើប្រាស់ ទឹកសមុទ្រផងដែរ។ ប្រភេទពូជស្រូវនេះអាចផ្តល់ទិន្នផលប្រហែល ៧,៥តោន ក្នុងមួយហិកតា ហើយនៅក្នុងរយៈពេលពី ៥ ទៅ ៨ឆ្នាំខាងមុខទៀត ចិននឹងអាចប្រើប្រាស់ដីទំហំ ១៥០ លានហិកតា សម្រាប់ដាំដុះស្រូវដែលប្រើប្រាស់ទឹកសមុទ្រ។ បន្ថែមពីនេះទៀត ចិនក៏ស្រាវជ្រាវបានប្រភេទពូជស្រូវយក្សដែលអាចផ្តល់ទិន្នផលខ្ពស់ រហូតដល់ ១៥តោនក្នុងមួយហិកតា។ ស្រូវនេះមានកម្ពស់ជាង ២ម៉ែត្រ និងអាចផ្តល់ជម្រកឲ្យត្រី បានសុខសាន្ត និងមិនមានផលប៉ះពាល់ចំពោះទឹកឡើយ។ សូមបញ្ជាក់ថា ស្រូវអង្ករជាប្រភេទអាហារមូលដ្ឋានរបស់ប្រជាជនចិន ហើយវាមានប្រវត្តិនៅចិនយូរអង្វែងមកហើយ។ បច្ចុប្បន្នការដាំដុះស្រូវនេះធ្វើឡើងលើផ្ទៃដីមួយភាគបួននៃផ្ទៃដី សម្រាប់ដំណាំទូទាំងប្រទេសចិនទាំងមូល។ *ប្រភពបានមកពី ខ្មែរអេប្យាវ*

## ទឹកកកនៅអង់តាក់ទិចបានរលាយដល់កម្រិតមិនធ្លាប់មាន



ផ្ទាំងទឹកកកនៅតំបន់អង់តាក់ទិចដែលកំពុងរលាយមិនធ្លាប់មាន។ រូបភាពtheguardian

- ទឹកកកនៅទ្វីបអង់តាក់ទិចបានធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងឆ្នាំនេះ ប៉ុន្តែអ្នកជំនាញមិនទាន់អាចបញ្ជាក់ច្បាស់លាស់ថាជាប់ពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ។ អ្នកជំនាញឧតុនិយមនិងអ្នកវិទ្យាសាស្ត្រជាង ៦០ នាក់មកពីជុំវិញពិភពលោកកំពុងរៀបចំកិច្ចប្រជុំរយៈពេលមួយសប្តាហ៍ដើម្បីយល់ពីការផ្លាស់ប្តូរទឹកកកសមុទ្រនៅលើទ្វីបទឹកកក។
- សូមរំលឹកថា កម្រិតគ្របដណ្តប់នៃទឹកកកបានថយចុះមកនៅត្រឹមតែជាង២គីឡូម៉ែត្រការ៉េប៉ុណ្ណោះ កាលពីខែមីនា ហើយវាជាចំនួនថយចុះគួរឱ្យកត់សំគាល់បំផុតមួយតាំងពីឆ្នាំ១៩៧៩មក ខណៈដែលកាលពី៣ឆ្នាំមុនកម្រិតគ្របដណ្តប់មានរហូតដល់ជាង២០គូឡូម៉ែត្រការ៉េ។
- អ្នកជំនាញការស្រាវជ្រាវនៅទ្វីបអង់តាក់ទិច បានលើកឡើងពីមូលហេតុដែលធ្វើឱ្យទឹកកកនៅតំបន់បូល រលាយគឺដោយសារតែកម្រិតកំដៅបានកើនឡើងដែលធ្វើឱ្យកម្រិតនៃការរលាយបានកើនឡើងដំណាលគ្នាដែរ ប៉ុន្តែពួកអ្នកវិទ្យាសាស្ត្រនៅទ្វីបអង់តាកមិនទាន់ហ៊ានបញ្ជាក់ថាការរលាយទឹកកនៅតំបន់អង់តាក់ទិចនេះដោយសារតែមូលហេតុការប្រែប្រួលអាកាសធាតុ ឬក៏យ៉ាងណានោះទេ៕
- ប្រភព៖https://www.theguardian.com/world/2017/sep/26/antarctic-sea-ice-levels-hit-record-low-but-experts-are-not-sure-why

# ការបំពុលក្នុងខ្យល់ និងទឹក សម្លាប់មនុស្ស ៩លាននាក់ នៅក្នុងពិភពលោក

ដោយ ឈាង បុប្ផា



នៅទីក្រុងប៉េកាំង ប្រជាជនពាក់ម៉ាស់ ដើម្បីការពារកុំស្រូបផ្សែងពុល REUTERS/Jason Lee

នៅឆ្នាំ ២០១៥ ផ្សែងពុលបរិយាកាស ការបំពុលក្នុងទឹក និងការបំពុលបង្កដោយសារសារធាតុគីមី ជាដើមហេតុ ធ្វើមនុស្ស៩លាននាក់ នៅក្នុងពិភពលោក ស្លាប់មុនអាយុ។ នេះបើតាមរបាយការណ៍របស់គណៈកម្មការអង់គ្លេស ដែលទស្សនាវដ្តីឈ្មោះ The lancetបេញផ្សាយនៅថ្ងៃសុក្រនេះ។ តាមរបាយការណ៍ អ្នកស្លាប់ដោយសារផ្សែងពុល និងទឹកមានជាតិពុល មានចំនួនច្រើនជាងចំនួនអ្នកដែលស្លាប់ដោយសារតែជម្ងឺអេដស៍ របេង នឹងគ្រុនចាញ់ ដល់ទៅបីដង។



ខ្យល់ពុលបរិយាកាស និងសារធាតុពុលក្នុងទឹកបានសម្លាប់មនុស្ស៩លាននាក់ នៅក្នុងពិភពលោក។ អាចនិយាយបានថា មនុស្សម្នាក់ក្នុងចំណោម៦នាក់ ដែលស្លាប់នៅក្នុងពិភពលោក គឺស្លាប់ដោយសារការបំពុល នៅក្នុងបរិយាកាស និងក្នុងទឹក។

របាយការណ៍ចេញផ្សាយនៅថ្ងៃនេះ ជាលទ្ធផលនៃការស្រាវជ្រាវរយៈពេល២ឆ្នាំ របស់គណៈកម្មការអង់គ្លេសមួយ ដែលបានសហការជាមួយ អង្គការខាងសុខភាព និងបរិស្ថាន រួមជាមួយនឹងអ្នកជំនាញប្រមាណ៤០នាក់ នៅក្នុងពិភពលោក។ មានចំណងជើងថា ការបំពុល សុខភាព និងផែនដី របាយការណ៍នេះត្រូវបានចេញផ្សាយ ដោយទស្សនាវដ្តីសុខភាពដ៏ល្បីឈ្មោះមួយរបស់អង់គ្លេស ឈ្មោះ The Lancet។ របាយការណ៍នេះ ផ្តោតសំខាន់ទៅលើការបំពុលបរិយាកាស និងទឹក ដែលជាដើមហេតុធ្វើឲ្យមនុស្ស៩លាននាក់ នៅក្នុងពិភពលោក ស្លាប់ នៅឆ្នាំ ២០១៥។ ចំនួនមនុស្សស្លាប់ដោយសារការបំពុលបរិយាកាស និងទឹក ស្មើនឹងបីដងនៃចំនួន មនុស្សដែលស្លាប់ដោយសារជម្ងឺអេដស៍ គ្រុនចាញ់ និងរបេងទៅទៀត។ មានន័យថា ចំនួនមនុស្សដែលស្លាប់ដោយសារជម្ងឺអេដស៍ របេង និងគ្រុនចាញ់ បូកចូលគ្នា ក៏នៅតែតិចជាងចំនួនមនុស្សដែលស្លាប់ដោយសារខ្យល់ពុលបរិយាកាស និងទឹកដែរ។




ជារួម ខ្យល់ពុលបរិយាកាស ទាំងក្នុង និងនៅក្រៅផ្ទះ បានសម្លាប់មនុស្សច្រើនជាងគេ គឺ ដល់ទៅ ៦លាន ៥សែននាក់ នៅក្នុងពិភពលោក នៅឆ្នាំ ២០១៥។ ទឹកដែលមានសារជាតុពុល ទឹកមានមេក្រុប ដែលអាចបង្កឲ្យមានជម្ងឺរលាកបំពង់រំលាយអាហារ បានសម្លាប់មនុស្ស១លាន ៨សែននាក់។ ចំណែកមនុស្ស៨សែននាក់ផ្សេងទៀត ស្លាប់ ដោយសារការបំពុលទាក់ទងនឹងសារជាតុគីមី និងជាតិពុល នៅកន្លែងធ្វើការ ដូចជានៅក្នុងអណ្តូងរ៉ែ ជាដើម។




ផ្សែងពុលបរិយាកាស ដែលជាដើមហេតុបង្កឲ្យមានជម្ងឺ មិនឆ្លង ដូចជាជម្ងឺគាំងបេះដូង មហារីកសួត គ្រោះថ្នាក់ដាច់សរសៃឈាម ឬជម្ងឺរលាកទងសួតរាំរ៉ៃ ដែលបានសម្លាប់មនុស្ស៦លាន ៥សែននាក់។ នៅក្នុងផ្សែងពុលបរិយាកាស ដូចជាឧស្ម័នអូហ្សូន ឬឧស្ម័នកាបូនិក គឺមានសំបូរទៅដោយសារ

សារធាតុល្អិតផ្ទារ ដែលមានទំហំតូចជាងសរសៃសក់ដល់ទៅ ១០ ដង ឬមានទំហំប៉ុនបាក់តេរី ដែលគេមិនអាចមើលឃើញនឹងភ្នែក។ សារធាតុល្អិតផ្ទារនេះ មាននៅក្នុងឧស្ម័នពុល ដូចជាផ្សែងរថយន្ត ផ្សែងចេញពីរោងចក្រឧស្សាហកម្ម ដែលដុតធ្យូងថ្ម។ សូម្បីផ្សែងអុសដែលដុតចេញពីចង្រ្កានបាយ ឬចង្រ្កានសម្រាប់កំដៅនៅក្នុងប្រទេសមានអាកាសធាតុត្រជាក់ខ្លាំង ក្តី ក៏មានសារធាតុល្អិតផ្ទារ ដែលអាចចូលទៅបំផ្លាញ សួត និងធ្វើឲ្យមនុស្សស្លាប់ដោយសាររោគគាំងបេះដូងបានដែរ។






ប្រជាជនក្រីក្រ មានប្រាក់ចំណូលទាបដែលរងគ្រោះមុនគេដោយសារខ្យល់ពុលបរិយាកាសការបំពុលបរិយាកាស មាននៅសឹងគ្រប់ប្រទេស មិនថា នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ ឬប្រទេសអភិវឌ្ឍ។ ប៉ុន្តែ អ្វីដែលសោកស្តាយ គឺថា មានតែប្រទេសដែលកំពុងអភិវឌ្ឍដែលត្រូវខាតបង់ រងគ្រោះខ្លាំងជាងគេ។ អ្នកសរសេររបាយការណ៍របស់គណៈកម្មការThe Lancet បានលើកឡើងពីបរិស្ថានអយុត្តិធម៌ ព្រោះថា ៩២ភាគរយនៃចំនួនមនុស្សដែលស្លាប់ ដោយសារការផ្សែងពុល ទឹកមានជាតិពុល មានរស់នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប។ ឧទាហរណ៍ ពាក់កណ្តាលទៅហើយ នៃមនុស្សដែលស្លាប់មុនអាយុនៅឆ្នាំ ២០១៥ ដោយសារខ្យល់ពុល និងទឹកពុល គឺជាប្រជាជនរស់នៅប្រទេសឥណ្ឌា និងចិន។ ឥណ្ឌា ចិន ស្ថិតនៅជួរមុខជាមួយប្រទេសកេនយ៉ា ប៉ាគីស្ថាន និងម៉ាដាហ្គាស្កា ដែលនៅទីនោះ មនុស្សម្នាក់ ក្នុងចំណោម៤នាក់ ដែលស្លាប់ នៅឆ្នាំ ២០១៥ គឺស្លាប់ដោយសារតែផ្សែពុល ទឹកពុល ឬសារធាតុគីមីនោះឯង។ អ្នកដែលស្លាប់មុនអាយុទាំងនោះ ភាគច្រើនគឺក្រុមមនុស្សក្រីក្រ តោកយ៉ាក ដែលរស់នៅ ឆ្ងាយដាច់ពីគេឯង។ គេបានលើកយកករណីរបស់ជនរងគ្រោះ ដែលធ្លាប់រស់នៅក្បែរចំណតរថយន្តក្រុង ក្នុងទីក្រុងញូវយ៉ក។ នៅទីនោះ ពួកគេស្រូបយកផ្សែងពុល ចេញពីម៉ាស៊ីនរថយន្តក្រុងពេញៗសួតជារៀងរាល់ថ្ងៃ។





ជារួមគេបានវាយតម្លៃថា ការស្លាប់មុនអាយុ ហើយនិងជម្ងឺរ៉ាំរ៉ៃរបស់មនុស្ស ដែលបង្កឡើងដោយសារការបំពុលបរិយាកាស ហើយនិងទឹកមិនស្អាតបានធ្វើឲ្យ គេខាតបង់ថវិកាដល់ទៅ ៤៣ន់ ៦រយ ពាន់លានដុល្លារ នៅក្នុងពិភពលោក។ អ្វីដែលអ្នកសរសេររបាយការណ៍ចង់ទាញចំណាប់អារម្មណ៍គឺថា ការបាត់បង់ជីវិត ដោយសារការបំពុលនៅក្នុងខ្យល់ និងទឹក ធ្វើឲ្យប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ចពិភពលោក ប៉ុន្តែ រហូតមកដល់ពេលនេះ ពិភពលោក នៅមិនទាន់មានវិធានការម៉ត់ចត់ណាមួយ ដើម្បីឆ្លើយតបនឹងបញ្ហានេះនៅឡើយទេ។ តាមរយៈរបាយការណ៍នេះ ដែលគេឃើញ តួលេខដ៏ព្រឺក្បាល នៃមនុស្សដែលស្លាប់ដោយសារផ្សែងពុលបរិយាកាស គណៈកម្មការសង្ឃឹមចង់ឲ្យសហគមន៍អន្តរជាតិចេញជាវិធានការរួមមួយ ថ្នាក់អន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាខ្យល់ពុលបរិយាកាស និងទឹកមានសារជាតុពុល នៅក្នុងពិភពលោក៕

## អាមេរិកកែច្នៃតិចជាងគេ ខណៈដែលចិន និងអឺរ៉ុបបានកែច្នៃច្រើន
## បញ្ហាសំរាមមិនមែនមានតែកម្ពុជានោះទេ

សំរាមប្លាស្ទិកគឺជារឿងរួមលើសកលលោកដែលប្រទេសនីមួយៗបានជួបប្រទះ និងកំពុងដោះស្រាយ បញ្ហាប្រឈមទាំងនេះ។ គិតមកដល់ពេលនេះ សម្ភារៈប្លាស្ទិកប្រមាណ៨.៣ ពាន់លានតោន ត្រូវបានផលិតដើម្បីប្រើប្រាស់នៅលើពិភពលោក។ នេះបើតាមការបញ្ជាក់ពីអ្នកវិទ្យាសាស្ត្រសហរដ្ឋអាមេរិក ដែលបានបូកសរុប។

ទម្ងន់៨.៣លានតោននេះគឺធ្ងន់ស្មើនឹងអគារធំៗនៅសហរដ្ឋអាមេរិក ២ម៉ឺន៥ពាន់នៅក្នុងទីក្រុងញូយ៉ករបស់អាមេរិក ឬក៏ទម្ងន់នេះស្មើនឹងសត្វដំរីធំៗចំនួន១ពាន់ក្បាល។ ថង់ប្លាស្ទិកទាំងអស់គឺត្រូវបានប្រើប្រាស់រយៈពេលខ្លីតែប៉ុណ្ណោះមុនពេលដែលបោះចោល។ បើតាមការបញ្ជាក់ពីអ្នកស្រាវជ្រាវរបស់អាមេរិក ផលិតផលប្លាស្ទិកប្រមាណ៨០% ត្រូវបានដឹកទៅបោះចោលនៅកន្លែងចាក់សំរាម និងកន្លែងផ្សេងទៀត ដែលរួមមានទាំងមហាសមុទ្រផងដែរ។ យ៉ាងណាក៏ដោយជាមួយនឹងចំនួននៃសំរាមប្លាស្ទិកដ៏ច្រើនសន្ធឹកសន្ធាប់នេះ អ្នកវិទ្យាសាស្ត្រអាមេរិកបានបង្ហាញឆ្នាំ២០១៤ដោយបញ្ជាក់ថា ក្នុងចំណោមសំរាមប្លាស្ទិករបស់ខ្លួនទាំងអស់ សហរដ្ឋអាមេរិក បានកែច្នៃត្រឹមតែ៩%តែប៉ុណ្ណោះ ខណៈដែលប្រទេសចិនបានកែច្នៃបាន២៥% ដោយឡែកសហភាពអឺរ៉ុបទាំងមូលបានកែច្នៃបាន៣០%នៃសំរាមរបស់ខ្លួន។

ក្នុងរយៈ១៣ឆ្នាំចុងក្រោយនេះ ប្លាស្ទិកជាង៤ពាន់លានតោនត្រូវបានផលិត ខណៈដែលចំនួននៃសំរាមប្លាស្ទិកនឹងកើនដល់១២ពាន់លានតោននៅឆ្នាំ២០៥០។










### សកម្មភាពងាយៗដើម្បីជួយការពារការបំផ្លាញធម្មជាតិដែលយើងទាំងអស់គ្នាអាចធ្វើបាន

ការកែច្នៃសំណល់ប្លាស្ទិក ការប្រមូលសំរាមនិងទុកដាក់ឱយបានត្រឹមត្រូវ ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ៕










សាកលវិទ្យាល័យភូមិន្ទកសិកម្ម
ផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយ
ដង្កូវហ្វាស្យូឡា
ពេញវ័យនៅក្នុងថ្លើម
វដ្តជីវិត
ដង្កូវថ្លើមហ្វាស្យូឡា
Metacercarias ពោងភ្ជាប់ខ្លួន
លើស្មៅក្នុងទម្រង់ជាគីស្ត
ស៊ុតបរាសិត ហ្វាស្យូឡា
(Fasciola ) ស្ថិតនៅ
ក្នុងលាមក ដែលបញ្ចេញមកមជ្ឈដ្ឋាន
ខាងក្រៅ(៨ ទៅ ១២ សប្តាហ៍បន្ទាប់ពីឆ្លង)
ស៊ុតញាស់ក្នុងសីតុណ្ហភាព
សមស្រប (លើសពី ១០ អង្សាសេ)
ក្លាយជាដង្កូវ Miracidium (១០ ទៅ ១២ ថ្ងៃ)
Miracidium ជុះកន្ទុយលូតលាស់
ក្លាយជា Cercaria អាស្រ័យដោយ
សីតុណ្ហភាពអំណោយផល
ឬសមស្រប (៥ ទៅ ៧ សប្តាហ៍)
រយៈពេលដែលងាយប្រឈម
Miracidium លូតលាស់លើខ្យង
ដែលរួមផ្សំដោយសីតុណ្ហភាព និងសំណើមសមស្រប
Edited by:
Division of Research and Extension (DRE) of Royal University of Agriculture (RUA), Cambodia

# ការបញ្ជ្រាបយេនឌ័រ និងកុមារក្នុងវិស័យបរិស្ថាន






សិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យបរិស្ថាន ឆ្នាំ២០១៦-២០២០ នៅទីរួមខេត្តក្រចេះ ចាប់ពីថ្ងៃទី១១ ដល់ទី១៣ ខែកញ្ញា ឆ្នាំ២០១៧ដែលរៀបចំឡើងដោយក្រុមការងារបច្ចេកទេសយេនឌ័រ នៃក្រសួងបរិស្ថាន សហការជាមួយមន្ទីរបរិស្ថានខេត្តក្រចេះ និងក្រោមការជួយឧបត្ថមពី Generating Accessing and Using Information and Knowledge Related to the 3Rio Convention។ សិក្ខាសាលា នេះបានរៀបចំឡើងក្នុងគោលបំណង៖

១-ចែករំលែកបន្ថែមនូវចំណេះដឹងស្តីពីទស្សនទានយេនឌ័រ និងសារៈសំខាន់ ព្រមទាំងភាពចាំបាច់ក្នុងដំណើការអភិវឌ្ឍ

២-បង្កើន និងពង្រឹងសម្ថភាព និងទំនុកចិត្តរបស់សិក្ខាកាមក្នុងការចូលរួមអនុវត្តការងារយេនឌ័រ

៣-ពង្រឹងសម្ថភាពសិក្ខាកាមក្នុងការវិភាគយេនឌ័រក្នុងកិច្ចការងារប្រចាំថ្ងៃ

សិក្ខាសាលានេះមានការចូលរួមពី មន្ត្រីនៃក្រសួងបរិស្ថាន ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញដែលអញ្ជើញមកពីមន្ទីរសុខាភិបាល មន្ទីរកសិកម្ម មន្ទីរធម្មការ មន្ទីរអភិវឌ្ឍន៍ មន្ទីរប្រៃសនីយ៍ មន្ទីរកិច្ចការនារី មន្ទីរសាធារណៈការ មន្ទីរធនធានទឹក មន្ទីររ៉ែ និងថាមពល មន្ទីរពាណិជ្ជកម្ម មន្ទីរផែនការ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអ្នកចូលរួមសរុបចំនួន៦៧នាក់ (ស្ត្រីចំនួន៤៥នាក់)។



សិក្ខាសាលា នេះបានរៀបចំឡើងក្នុងគោលបំណង៖

១-ចែករំលែកបន្ថែមនូវចំណេះដឹងស្តីពីទស្សនទានយេនឌ័រ និងសារៈសំខាន់ ព្រមទាំងភាពចាំបាច់ក្នុងដំណើរការអភិវឌ្ឍ

២-បង្កើន និងពង្រឹងសម្ថភាព និងទំនុកចិត្តរបស់សិក្ខាកាមក្នុងការចូលរួមអនុវត្តការងារយេនឌ័រ

៣-ពង្រឹងសម្ថភាពសិក្ខាកាមក្នុងការវិភាគយេនឌ័រក្នុងកិច្ចការងារប្រចាំថ្ងៃ

សិក្ខាសាលានេះមានការចូលរួមពី មន្ត្រីនៃក្រសួងបរិស្ថាន ក្រុមការងារបច្ចេកទេសយេនឌ័រនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញដែលអញ្ជើញមកពីមន្ទីរសុខាភិបាល មន្ទីរកសិកម្ម មន្ទីរធម្មការ មន្ទីរអភិវឌ្ឍន៍ មន្ទីរប្រៃសនីយ៍ មន្ទីរកិច្ចការនារី មន្ទីរសាធារណៈការ មន្ទីរធនធានទឹក មន្ទីររ៉ែ និងថាមពល មន្ទីរពាណិជ្ជកម្ម មន្ទីរផែនការ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអ្នកចូលរួមសរុបចំនួន៦៧នាក់ (ស្ត្រីចំនួន៤៥នាក់)។







នាយកដ្ឋានបានបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យបរិស្ថានឆ្នាំ២០១៦-២០២០ នៅខេត្តសៀមរាប

- រៀបចំបង្កើតក្រុមការងារជនបង្គោលនៅថ្នាក់រាជធានី-ខេត្ត
- រៀបចំវគ្គផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីការគាំពារ អភិវឌ្ឍកុមារតូច និងការអប់រំផ្សព្វផ្សាយ ដល់កុមារនិងមាតាបិតាអំពីបរិស្ថាននិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅ

សហគមន៍តំបន់ការពារធម្មជាតិជប់តាសុខនៃឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំគូលែន» ខេត្ត សៀមរាប

- បោះពុម្ពផ្ទាំងអប់រំស្តីពីបរិស្ថានបានចំនួន១០០ផ្ទាំង
- បានរៀបចំពិធីផ្សព្វផ្សាយដល់កុមារ និងមាតាបិតា អំពីបរិស្ថាន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងពិធីប្រគល់អណ្តូងទឹក និងដាំដើមឈើនៅស្រុកព្រះស្តេច ខេត្តព្រៃវែង
- រៀបចំពិធីអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១មិថុនា ក្រោមប្រធានបទ លើកកម្ពស់ការចូលរួមរបស់កុមារ ដើម្បីអភិវឌ្ឍសង្គម និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងនិងពលកម្មកុមារ។

# ការប្រកួតរូបភាពគំនូរបរិស្ថាន



ចំណងជើង៖ សោភ័ណភាពនៃបរិស្ថាន
ឈ្មោះ៖ កញ្ញា ឡុង វ៉ាន់សឿន ភេទ ស្រី អាយុ ១៤ឆ្នាំ
មកពី៖ អង្គការដើម្បីភាពញញឹមនៃកុមារ
គូរក្នុងឆ្នាំ៖ ២០១២

Title: Environmental Beauty
Name: Ms. Long Vannoeum, Female, 14 years old
From: Pour un Sourire d' enfant
Drawn in Year: 2012

Cambodia Climate Change Alliance (CCCA)



ចំណងជើង៖ រួមគ្នាកាត់បន្ថយការប្រែប្រួលអាកាសធាតុ
ឈ្មោះ៖ លោក អ៊ឹម ពិសី ភេទ ប្រុស អាយុ ២១ឆ្នាំ
មកពី៖ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
គូរក្នុងឆ្នាំ៖ ២០១២

Title: Together to Mitigate Climate Change
Name: Mr. Im Pesey, Male, 21 years old
From: The Royal University of Fine Arts
Drawn in Year: 2012

Cambodia Climate Change Alliance (CCCA)



| | | |
|---|---|---|
| ចំណងជើង៖ ភពដ៏អស្ចារ្យ | Title: The Wonderful Planet | Cambodia Climate Change Alliance (CCCA) |
| ឈ្មោះ៖ លោក សារិទ្ធ ចំរើន ភេទ (ប្រុស) អាយុ ២២ឆ្នាំ | Name: Mr. Sarith Chomroeun, Male, 22 years old | |
| មកពី៖ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | From: The Royal University of Fine Arts | |
| គូរក្នុងឆ្នាំ៖ ២០១២ | Drawn in Year: 2012 | |



| | | |
|---|---|---|
| ចំណងជើង៖ រួមសាមគ្គីគ្នាការពារ និងអភិរក្សធនធានព្រៃឈើ | Title: Unite to Protect and Conserve Forest Resources | Cambodia Climate Change Alliance (CCCA) |
| ឈ្មោះ៖ កញ្ញា ឡេង ប៊្រីនាថ ភេទ (ស្រី) អាយុ ២៤ ឆ្នាំ | Name: Ms. Leng Breyneath, Female, 24 years old | |
| មកពី៖ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | From: The Royal University of Fine Arts | |
| គូរក្នុងឆ្នាំ៖ ២០១២ | Drawn in Year: 2012 | |



ចំណងជើង: រួមគ្នាដើម្បីបរិស្ថានស្អាត
ឈ្មោះ: កញ្ញា ជួន សោភ័ណ្ឌមេត្រី ភេទ ស្រី អាយុ ២០ឆ្នាំ
មកពី: សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
គូរក្នុងឆ្នាំ: ២០១២

Title: Together for Clean Environment
Name: Ms. Chuon Sophommeroth, Female, 20 years old
From: The Royal University of Fine Arts
Drawn in Year: 2012

Cambodia Climate Change Alliance (CCCA)



ចំណងជើង: ផ្លាស់ប្តូរឥរិយាបថ និងរបៀបរស់នៅដើម្បីជីវិតប្រសើរ
ឈ្មោះ: កញ្ញា វីរ៉ាន់ មុនីកា ភេទ ស្រី អាយុ ២១ឆ្នាំ
មកពី: សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
គូរក្នុងឆ្នាំ: ២០១២

Title: Change Behavior and the Way of Living
Name: Ms. Vyran Monica, Female, 21 years old
From: The Royal University of Fine Arts
Drawn in Year: 2012

Cambodia Climate Change Alliance (CCCA)